# ស្តង់ដារនៃការធ្វើកោសល្យវិច័យផ្ទាល់មាត់

## ការបញ្ជាក់ និងការកំណត់មូលហេតុនៃការស្លាប់

HMN
LONDON SCHOOL OF HYGIENE & TROPICAL MEDICINE
INDEPTH Network
USAID FROM THE AMERICAN PEOPLE
MEASURE Evaluation
World Health Organization

WHO Library Cataloguing-in-Publication Data

Verbal autopsy standards : ascertaining and attributing cause of death.

1.Autopsy - methods. 2.Questionnaires - standards. 3.Interviews - standards. 4.Cause of death. 5.International classification of diseases. 6.Death certificates. 7.Data collection - methods. 8.Mortality. I.World Health Organization.

ISBN 978 92 4 154721 5 (NLM classification: WA 900)

**© អង្គការសុខភាពពិភពលោក ២០០៧**

រក្សាសិទ្ធិគ្រប់យ៉ាង។ ការបោះពុម្ពផ្សាយរបស់អង្គការសុខភាពពិភពលោក អាចរកបាននៅផ្នែកផ្សព្វផ្សាយទីផ្សារ និងចែកចាយ អង្គការសុខភាពពិភពលោក 20 Avenue Appia, 1211 Geneva 27, Switzerland (tel: +41 22 791 2476; fax: +41 22 791 4857; email: *bookorders@who.int*)។ ការស្នើសុំការអនុញ្ញាត ដើម្បីផលិតឡើងវិញ ឬ បកប្រែ រាល់ការបោះពុម្ពផ្សាយរបស់អង្គការសុខភាពពិភពលោក-ទោះសំរាប់លក់ ឬ សំរាប់ចែកចាយមិនយកកំរៃ-ត្រូវស្នើទៅការបោះពុម្ពផ្សាយតាមអាស័យដ្ឋានខាងលើ (fax: +41 22 791 4806; email: permissions@who.int) ។

ការរៀបចំ និងការបង្ហាញសំភារៈនៅក្នុងការបោះពុម្ពនេះ មិនបង្ហាញពីមតិយោបល់ណាមួយរបស់អង្គការសុខភាពពិភពលោក ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ ពាក់ព័ន្ធនឹងការកំណត់ព្រំដែនឡើយ។ បន្ទាត់ដាច់នៅលើផែនទីតំណាងព្រំដែនប្រហាក់ប្រហែល ដែលអាចមិនទាន់មានការឯកភាពទាំងស្រុង។

ការបង្ហាញពីក្រុមហ៊ុនណាមួយ ឬផលិតផលរបស់រោងចក្រផលិតណាមួយមិនមានន័យថា ក្រុមហ៊ុន ឬ រោងចក្រនេះ ទទួលបាននូវការគាំទ្រដោយអង្គការសុខភាពពិភពលោក ជាងអ្នកដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលមិនបានបង្ហាញនោះឡើយ។ អាចមានកំហុសឆ្គង និងការខ្វះខាតឈ្មោះផលិតផលត្រូវបានបង្ហាញដោយអក្សរធំខាងដើម។

អង្គការសុខភាពពិភពលោកបានប្រកាន់យកនូវការប្រុងប្រយ័ត្នទាំងអស់ក្នុងការផ្ទៀងផ្ទាត់ ពត៌មានដែលមាននៅក្នុងការបោះពុម្ពនេះ។ ប៉ុន្តែឯកសារបោះពុម្ពនេះត្រូវបានចែកចាយ ដោយមិនមានការធានាប្រភេទណាមួយឡើយ ទោះជាបានបញ្ជាក់ ឬមិនបានបញ្ជាក់ក្តី។ ការទទួលខុសត្រូវក្នុងការបកស្រាយ និងប្រើប្រាស់ឋិតលើអ្នកអាន។ អង្គការសុខភាពពិភពលោកនឹងមិនទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយណាដែលកើតចេញពីការប្រើប្រាស់វាឡើយ។

Printed in France

**បោះពុម្ពដោយអង្គការសុខភាពពិភពលោកឆ្នាំ ២០០៧ ក្រោមចំណងជើងថា " Verbal Autopsy Standard: Ascertaining and attributing cause of death "**

**© អង្គការសុខភាពពិភពលោក ២០០៧**

**អគ្គនាយកអង្គការសុខភាពពិភពលោក បានផ្តល់សិទ្ធិបកប្រែជាភាសាខ្មែរដល់វិទ្យាស្ថានជាតិសុខភាពសាធារណៈដែលជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះសំណៅជាភាសាខ្មែរ។**

# មាតិកា


**១. ការរៀបចំស្តង់ដារនៃការធ្វើកោសល្យវិច័យផ្ទាល់មាត់ ៤**

**១.១. គោលបំណង និងមាតិកា ៤**

**១.២. សេចក្តីត្រូវការសំរាប់ការធ្វើអោយស្តង់ដារនូវវិធីសាស្រ្តកោសល្យវិច័យផ្ទាល់មាត់ ៥**

**១.៣ ឯកសារយោង ៧**

២. កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ជាស្តង់ដារអន្តរជាតិ ៩

**២.១. សេចក្តីផ្តើម ៩**

**២.២. កំរងសំណួរស្តង់ដារនៃកោសល្យវិច័យផ្ទាល់មាត់ ៩**

២.២.១ រូបធាតុរួម ៩

២.២.២ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ១: ការស្លាប់របស់កុមារអាយុក្រោមបួនសប្តាហ៍ ១០

២.២.៣ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ២: ការស្លាប់របស់កុមារអាយុ៤សប្តាហ៍ទៅ១៤ឆ្នាំ ១០

២.២.៤ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ៣: ការស្លាប់របស់មនុស្សអាយុចាប់ពី ១៥ឆ្នាំឡើងទៅ ១១

២.៣ អ្នកឆ្លើយដែលសមស្រប និងរយៈកាលរំលឹក ១១

**២.៤ គោលការណ៍ណែនាំអំពីការបង្កើត ការបកប្រែ និងការសំរបយកទៅតាមកន្លែង ១១**

**២.៥ ឯកសារយោង ១២**

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ស្តង់ដារអន្តរជាតិ ១ ១៣

មរណៈភាពទារកអាយុតិចជាង ៤ សប្តាហ៍ ១៣

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ស្តង់ដារអន្តរជាតិ ២ មរណៈភាពកុមារអាយុ៤សប្តាហ៍ទៅ១៤ឆ្នាំ ៣៦

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ស្តង់ដារអន្តរជាតិ ៣ ៦១

មរណៈភាពមនុស្សអាយុ ១៥ឆ្នាំ ឡើងទៅ ៦១

**អធិប្បាយទៅលើសំណួរជាក់លាក់: ៩៥**

**អធិប្បាយអ្វីផ្សេងៗទៀត: ៩៥**

**៣. អនុវត្តន៍ ICD-១០ ពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ ៩៦**

**៣.១ គោលបំណង ៩៦**

**៣.២ ទិដ្ឋភាពទូទៅ ៩៧**

៣.២.១ សេចក្តីផ្តើមពីពតិមានមរណភាព ៩៧

៣.២.២ ប្រភពនៃពតិមានមរណភាព ៩៧

៣.២.៣ ការធ្វើកោសល្យវិច័យផ្ទាល់មាត់ ៩៨

៣.២.៤ មូលហេតុនៃការស្លាប់ ៩៨

**៣.៣ ការណែនាំ** **១០០**
៣.៣.១ ការកំណត់មូលហេតុនៃការស្លាប់ក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់ ១០០
៣.៣.២ ទំរង់ជាអន្តរជាតិនៃលិខិតវេជ្ជសាស្ត្រសំរាប់បញ្ជាក់មូលហេតុនៃការស្លាប់ ១០២
**៣.៤ វចនាសម្ព័ន្ធ និងគោលការណ៍របស់ ICD-១០** **១០៦**
៣.៤.១. ទិដ្ឋភាពទូទៅនៃការចាត់ថ្នាក់ **ICD-១០** ១០៦
៣.៤.២. តារាងបញ្ជី ១០៧
៣.៤.៣. លិបិក្រមតាមលំដាប់តួអក្សរ ១១៤
៣.៤.៤ ជ្រើសរើសមូលហេតុផ្ទាល់នៃការស្លាប់ ១១៦
**៣.៥ ការប្រើប្រាស់ទិន្នន័យ** **១២៤**
**៣.៦ ការសំងាត់** **១២៥**
**៣.៧ ប្រភពពត៌មានបន្ថែមទៀត** **១២៥**
៣.៧.១ ការផ្លាស់ប្តូរ និង បច្ចុប្បន្នភាព ចំពោះ **ICD-១០** ១២៥
៣.៧.២ ពត៌មានអំពី **ICD** ១២៦
៣.៧.៣ តារាងការសំរេចចិត្ត ១២៦
៣.៧.៤ ការពិនិត្យមើលជាទូទៅអំពីឱកាសនៃការបណ្តុះបណ្តាល ១២៦
៣.៧.៥ វេទិកាសាធារណៈអំពីមរណៈភាព ១២៦
**៣.៨ កូដី ជឌុ នៅក្នុងកោសល្យវិច័យផ្ទាល់មាត់-ករណីពិសេសៗ** **១២៦**
៣.៨.១ ដោះស្រាយជាមួយនឹងមូលហេតុច្រើន ១២៧
៣.៨.២ មូលហេតុពិសេសផ្សេងទៀត ១២៨
**៣.៩ តារាងទាក់ទងរវាង បញ្ជីកោសល្យវិច័យផ្ទាល់មាត់ខ្លី និង កូដ ICD-១០** **១៣៦**

# ១. ការរៀបចំស្តង់ដារនៃការធ្វើកោសល្យវិច័យផ្ទាល់មាត់

## ១.១. គោលបំណង និងមាតិកា

គោលបំណងនៃកូនសៀវភៅនេះគឺចង់ផ្សព្វផ្សាយស្តង់ដារនៃការប្រមូលទិន្នន័យ និងធនធានចាត់តាំងសំរាប់ការធ្វើកោសលវិច័យ មូលហេតុមរណភាព និងផ្តល់នូវការណែនាំទូទៅសំរាប់ការប្រើប្រាស់ធនធានទាំងនេះ។

ធនធានទាំងនេះរួមមានៈ

- កំរងសំណួរកោសលវិច័យផ្ទាល់មាត់សំរាប់ក្រុមអាយុបី (ក្រោមបួនសប្តាហ៍ បួនសប្តាហ៍ទៅ14ឆ្នាំ និង15ឆ្នាំឡើង) (ភាគ2)។
- សំបុត្របញ្ជាក់មូលហេតុមរណៈភាព និងគោលការណ៏ណែនាំពីកូដ សំរាប់ប្រើចំពោះ*ចំណាត់ថ្នាក់ស្ថិតិជាលក្ខណៈអន្តរជាតិនៃជំងឺ និងបញ្ហាសុខភាពដែលទាក់ទង*។ ការកែសំរួលលើកទី10 (ICD-10) [1] ចំពោះការធ្វើកោសល្យវិច័យផ្ទាល់មាត់ (ភាគ3 ផ្នែក 3.2-3.8)។ និង
- បញ្ជីមូលហេតុមរណៈភាព សំរាប់ការធ្វើកោសលវិច័យផ្ទាល់មាត់ ជាមួយនឹងកូដ ICD-10 ដែលទាក់ទង (”តារាងទាក់ទង” ភាគ3 ផ្នែកទី 3.9)។

សៀវភៅនេះ និងធនធានដែលវាមាន គឺជាផលិតផលរួមធ្លុងតែមួយនៃការខិតខំប្រឹងប្រែងបីឆ្នាំរបស់ក្រុមអ្នកជំនាញការ ដែលដឹកនាំដោយអង្គការសុខភាពពិភពលោក (WHO) រួមមានអ្នកស្រាវជ្រាវ អ្នកប្រើប្រាស់ និងអ្នករួមចំណែកផ្សេងៗទៀត ក្រោមកិច្ចឧបត្ថម្ភរបស់ Health Metrics Network (HMN)។ ពួកគេមានបំណងបំរើអោយសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់និងអ្នកផលិតនានានូវពតិមានអំពីមរណៈភាពរួមមានអ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និងប្រធានកម្មវិធី និងអ្នកវាយតំលៃ។ ដើម្បីអោយធនធានទាំងនេះអាចប្រើប្រាស់បានយ៉ាងងាយ និងយ៉ាងទូលំទូលាយដែលអាចធ្វើទៅបាន គេនឹងបោះពុម្ពវានៅក្នុងគេហ៏ទំព័ររបស់ WHO និងនៅក្នុងទំរង់ដែលអាចបោះពុម្ពចេញបាន ហើយនឹងរួមបញ្ចូលទៅក្នុងគេហ៏ទំព័ររបស់ HMN និងក្នុងកញ្ចប់ធនធានសំរាប់ពង្រឹងប្រពន្ធ័ស្ថិតិជីវៈថ្នាក់ជាតិដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗនេះ។ ដោយហេតុថាការបោះពុម្ពជាភាសាថ្មីៗនឹងមាន ឧបករណ៏ទាំងនេះនឹងត្រូវដាក់នៅក្នុងផ្នែកសាធារណៈ ដោយមាន WHO ជាឃ្លាំងសំរាប់ការបកប្រែដ៏ម៉ត់ចត់ និងសំភារៈបកត្រលប់មកវិញ ដែលត្រូវនឹងបែបបទជាស្តង់ដារដែលមានបោះពុម្ពនៅទីនេះ។ ក្រុមអ្នកជំនាញការអំពីការធ្វើកោសល្យវិច័យផ្ទាល់មាត់ បានពិនិត្យមើល ពិភាក្សា និងធ្វើអោយប្រសើរជាប្រពន្ធ័ នូវបណ្តុំបទពិសោធន៏ និងភស្តុតាងពីកំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ និងនិតិវិធី ដែលគេប្រើប្រាស់យ៉ាងទូលំទូលាយនិងសុក្រឹត្យ ។ ការនេះ អោយផលជាកំរងសំណួរស្តង់ដារសំរាប់ការធ្វើកោសល្យវិច័យផ្ទាល់មាត់ នៅលើក្រុមអាយុបី។ លើសពីនេះទៅទៀត ក្រុមអ្នកជំនាញការ បានឈានដល់កិច្ចព្រមព្រៀងលើការប្រើប្រាស់វិធីសាស្រ្តស្តង់ដារ សំរាប់បញ្ជាក់ដាក់កូដ និងធ្វើតារាងមូលហេតុមរណៈភាព ពីកោសល្យវិច័យផ្ទាល់មាត់ស្របទៅតាមនិតិវិធី ICD-10។ ការអនុវត្តន៏នូវឧបករណ៏ស្តង់ដារនេះ នឹងធ្វើអោយកាន់តែមានភាពស៊ីគ្នានិងភាពអាចប្រៀបធៀបគ្នាទៅវិញទៅមកបាននូវកោសល្យវិច័យដែលទាញចេញពីទិន្នន័យមរណៈភាព តារាងទំនាក់ទំនងអនុញ្ញាតិអោយមានការប្រើប្រាស់យ៉ាងងាយនូវ ICD-10។ វាក៏អនុញ្ញាតិអោយ មានការចាត់តាំងលំដាប់ក្រុមមួយ/អនុក្រុម សំរាប់មូលហេតុមរណៈភាព ដែលទាក់ទងទៅនឹងកូដ ICD-10 ប្រសិនបើមូលហេតុ ស្លាប់ជាក់លាក់ណាមួយមិនអាចចាត់បានពីព្រោះពតិមានពីកោសល្យវិច័យផ្ទាល់មាត់មិនគ្រប់គ្រាន់។ នៅពេលដែលមានពតិមានច្រើនទៀត ICD-10 ពេញលេញនឹងត្រូវប្រើសំរាប់ដាក់កូដ (មើលផ្នែក ៣.៩ នៃភាគ ៣ សំរាប់ការពន្យល់គោលបំណង និងការប្រើប្រាស់តារាងទំនាក់ទំនងនេះ)។

## ១.២. សេចក្តីត្រូវការសំរាប់ការធ្វើអោយស្តង់ដារនូវវិធីសាស្ត្រកោសល្យវិច័យផ្ទាល់មាត់

ភាពកំរនូវទិន្នន័យដែលអាចអោយជឿជាក់បាន អំពីកំរិតនិងមូលហេតុនៃការស្លាប់សំរាប់អ្នករស់នៅក្នុងតំបន់ក្រីក្រលើពិភពលោក បានបន្តកំណត់ព្រំដែននូវកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងនូវមូលដ្ឋានភស្តុតាងរឹងមាំសំរាប់គោលនយោបាយសុខាភិបាលការធ្វើផែនការ ការអភិបាលនិងវាយតំលៃ។ នៅកន្លែងដែលមរណៈភាពភាគច្រើននៅតែកើតមាននៅនឹងផ្ទះ និងនៅកន្លែងដែលប្រពន្ធ័ចុះបញ្ជីស៊ីវិល មិនដំណើរការ វាមានសំណាងតិចតួចណាស់ដែលមរណៈភាពកើតឡើងឆ្ងាយពីអាគារសុខាភិបាល ត្រូវបានគេកត់ត្រាដោយទុកអោយភាពឯកឯងបញ្ជាក់ពីមូលហេតុនៃការស្លាប់។ ជាដំណោះស្រាយមួយចំណែកទៅនឹងបញ្ហានេះ កោសល្យវិច័យផ្ទាល់មាត់ បានក្លាយទៅជាប្រភពបឋមសំរាប់ពតិមានអំពីមូលហេតុមរណៈភាព នៅក្នុងប្រជាជនដែលខ្វះការចុះបញ្ជីជីវៈ និងលិខិតបញ្ជាក់វេជ្ជសាស្ត្រ។ កោសល្យវិច័យផ្ទាល់មាត់គឺជាការសំភាសន៍ដែលធ្វើឡើងជាមួយនឹងសមាជិកគ្រួសារ ឬអ្នកថែទាំអ្នកស្លាប់ ដោយប្រើប្រាស់កំរងសំណួររៀបចំជាស្រេចដើម្បីយកការណ៍រោគសញ្ញានិងបណ្តុំរោគសញ្ញា និងពតិមានដ៏ទៃទៀតដែលទាក់ទង ដែលអាចប្រើបាននៅពេលក្រោយមកក្នុងការចាត់នូវមូលហេតុកើតមាននៅពីក្រោមការស្លាប់។ កោសល្យវិច័យផ្ទាល់មាត់គឺជាឧបករណ៍សុខភាពសាធារណៈ ដ៏ចាំបាច់សំរាប់ទទួលបាននូវការប៉ាន់ស្មានដោយផ្ទាល់សមស្របនៃរចនាសម្ពន្ធ័មូលហេតុនៃការស្លាប់នៅក្នុងសហគមន៍មួយ ឬកំរិតប្រជាជន បើទោះជាវាមិនមែនជាវិធីសាស្ត្រច្បាស់លាស់សំរាប់កំណត់មូលហេតុស្លាប់ចំពោះកំរិតបុគ្គល។

ពីរទសវត្សរកន្លងមកបានមើលឃើញពីការរីកសាយនូវផលប្រយោជន៍ ក៏ដូចជាការស្រាវជ្រាវនិងការអភិវឌ្ឍន៍ ក្នុងគ្រប់ទិដ្ឋភាពនៃដំណើរការកោសល្យវិច័យផ្ទាល់មាត់ ដោយរាប់ទាំងប្រពន្ធ័ប្រមូលទិន្នន័យដែលការធ្វើកោសល្យវិច័យត្រូវបានធ្វើឡើង (ឧទា. ទីតាំងឃ្លាំមើលពីប្រជាសាស្ត្រ តំណាងអង្កេត ឬទីតាំងឃ្លាំមើលប្រពន្ធ័ចុះឈ្មោះ ជំរឿន ឬការអង្កេតគ្រួសារ)។ មាតិកាកំរងសំណួរ និងទំរង់។ ការអនុវត្តទៅលើក្រុមអាយុផ្សេងៗ។ របៀបចាត់មូលហេតុស្លាប់។ ការដាក់កូដនិងធ្វើតារាងមូលហេតុនៃការស្លាប់ទៅតាមក្បួន ICD-10។ និងបញ្ហាវិខាននៃភាពសុក្រឹត្យ [3]។ ជាលទ្ធផល ទិន្នន័យមូលហេតុជាក់លាក់របស់មរណភាព បានក្លាយទៅជាមានសំរាប់ប្រជាជនទាំងមូលដែលបើមិនដូច្នេះទេនឹងមិនមានអ្វីមួយឡើយ។

គេប្រើកោសល្យវិច័យផ្ទាល់មាត់ក្នុងផ្លូវបីធំៗ។ ទីមួយ គេប្រើវាជាបឋមជាឧបករណ៍ស្រាវជ្រាវក្នុងបរិបថនៃការសិក្សាតទៅមុខ ការស្រាវជ្រាវអន្តរាគមន៍ ឬការសិក្សាបែបអេពីដេមីសាស្ត្រ ជាទូទៅនៅលើកុមារ ឬដើម្បីកំណត់មូលហេតុមរណៈភាពរបស់មាតា។ ទីពីរ វាក្លាយជាប្រភពស្ថិតិមូលហេតុស្លាប់ ដើម្បីបំពេញតំរូវការនៃការប៉ាន់ប្រមាណបន្ទុកជំងឺនៅកំរិតប្រជាជនទាំងមូល ដែលត្រូវប្រើនៅក្នុងគោលនយោបាយ ការធ្វើផែនការ កំណត់នូវអាទិភាព និងកំណត់នូវចំណុចគោល (Benchmarking) (ដូចនៅក្នុង ការសិក្សាពីបន្ទុកនៃជំងឺ ជាសកល [4])។ ទីបី ទិន្នន័យដែលទាញចេញពីកោសល្យវិច័យផ្ទាល់មាត់បានទទួលការទទួលស្គាល់កាន់តែច្រើន ថាជាប្រភពស្ថិតិមូលហេតុស្លាប់ ដែលគេប្រើសំរាប់ការតាមមើលការវិវឌ្ឍន៍ និងការវាយតំលៃអ្វីដែលដើរ និងអ្វីដែលមិនដើរ។

ដោយមានការទាក់ទងយ៉ាងខ្លាំងជាមួយនឹងកម្មវិធីស្រាវជ្រាវជាក់លាក់ វាមានការសំរបសំរួលតិចតួចណាស់ក្នុងចំណោមអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យកោសល្យវិច័យផ្ទាល់មាត់ និងបើទោះជាមានការប៉ុនប៉ងក្នុងការជំរុញឧបករណ៍ស្តង់ដារ ក៏ដោយ [5-7] អ្នកដែលសកម្មនៅក្នុងរឿងនេះ មិនបានទោរទន់ទៅរកគោលដៅរួមលើការអនុវត្តល្អបំផុតនោះឡើយ។ ការរចនានៃកំរងសំណួរកោសល្យវិច័យជំនាន់ទីមួយ និងជំនាន់ទីពីរ ជាឧទាហរណ៍ ធ្វើទៅតាមយ៉ាងធំធេង នូវតំរូវការរបស់អ្នកស្រាវជ្រាវ និងសំណួរជាក់លាក់ដែលនឹងត្រូវឆ្លើយ។ យ៉ាងហោចណាស់ ដំបូងបំផុត មិនមានពាក់ពន្ធ័នឹងការកំណត់អាទិភាពឡើយ ក្នុងការធានានូវភាពអាចប្រៀបធៀបបាននៃ

សំណុំទិន្នន័យពីប្រទេសមួយទៅប្រទេសមួយ។ លើសពីនេះទៀតតំលៃនិងភាពស្មុគស្មាញនៃសុពលភាពរបស់កោសល្យវិច័យផ្ទាល់មាត់ភាពមានក៏រិតកំណត់ដែលជាប់ជាមួយនឹងពិធីសារសុពលភាព និងកង្វះនូវការសិក្សាប្រៀបធៀបសុពលភាពនៃកំរងសំណួរដដែលនៅក្នុងពហុប្រទេស បានបន្សល់ទុកអោយអ្នកប្រើប្រាស់កោសល្យវិច័យផ្ទាល់មាត់ ដោយគ្មានករណីវិទ្យាសាស្ត្រទុកសំរាប់សំរបយកជា "ស្តង់ដារ " ដាច់ដោយឡែកណាមួយឡើយ។ ជាងនេះទៅទៀត មានទំនោរក្នុងការផ្លាស់ប្តូរពីទំរង់មុនៗនិងកំរងសំណួរ ឬដោយសាមញ្ញគឺចាប់ផ្តើមពីការអេះ។ វាគួរអោយកត់សំគាល់ផងដែរថា មានការប៉ុនប៉ងមួយចំនួនដើម្បីបោះពុម្ពផ្សាយ ចងក្រងឯកសារ និងជួយគាំទ្រសំរាប់យុទ្ធសាស្ត្រដែលធ្វើអោយស្តង់ដាររួចហើយ ចំពោះការចាត់មូលហេតុមរណៈភាព នៅក្នុងកោសល្យវិច័យផ្ទាល់មាត់ [8-12]។ នេះគឺជាសមាសភាពដ៏សំខាន់បំផុតនៃដំណើរការនៃការអនុវត្តវិធីសាស្ត្រកោសល្យវិច័យផ្ទាល់មាត់ ហើយក៏ដូចដែលយើងពិភាក្សាខាងក្រោម ត្រូវតែទៅជាមួយគ្នានឹងការធ្វើអោយទៅជាស្តង់ដារនូវឧបករណ៏ប្រមូលទិន្នន័យ ដើម្បីធានានូវការផលិតនូវទិន្នន័យដែលអាចប្រៀបធៀបបាន។ ក្នុងរយៈពេល ៥ ទៅ ៧ ឆ្នាំកន្លងមកនេះ សារៈសំខាន់នៃទិន្នន័យដែលទាញចេញពីកោសល្យវិច័យផ្ទាល់មាត់ជាប្រភពស្ថិតិលទ្ធផលសុខាភិបាលដែលអាចប្រៀបធៀបបាន មានការកើនឡើងយ៉ាងរហ័ស ដែលបានធ្វើអោយមានការចាំបាច់ក្នុងការធ្វើអោយទៅជាស្តង់ដារនូវយុទ្ធសាស្ត្រទាំងអស់អោយកាន់តែល្អឡើង។ ឧទាហរណ៏ ការវិភាគជាន់ខ្ពស់ (Meta-analysis) ពីសំណុំទិន្នន័យនៃកោសល្យវិច័យផ្ទាល់មាត់ដែលមានស្រាប់ ត្រូវបានគេប៉ុនប៉ងធ្វើឡើងដើម្បីដាក់ចេញនូវ "កំណត់គោល " នានា ជាសកលសំរាប់បន្ទុកមរណៈភាពក្នុងចំណោមកុមារដែលបណ្តាលមកពីជំងឺផ្សេងៗ [13-17]។ ដោយសារតែខ្វះនិតិវិធីជាស្តង់ដារនៃការប្រមូលទិន្នន័យ និងការកំណត់មូលហេតុមរណៈភាព និង ការរៀបចំតារាង ការប្រៀបធៀបប្រភពពតិមានដ៏មានតំលៃទាំងនេះ យ៉ាងណាក៏ដោយ នៅមានក៏រិតកំណត់យ៉ាងខ្លាំង។ ការវាយតំលៃភាពស៊ីគ្នានៃទិន្នន័យ និងភាពអាចជឿជាក់បាន នៅមានឧបសគ្គច្រើនណាស់ដោយសារតែកង្វះខាតសំណុំទិន្នន័យសាធារណៈខ្លួនឯង [18] ដោយកង្វះខាតការសិក្សាសុពលភាពដ៏ម៉ត់ចត់ និងដោយមានបញ្ហាជាញឹកញាប់នៃគំរូអង្កេតតូច ឬមិនតំណាងអោយ។

ក្នុងពេលជាមួយគ្នានោះ មានតំរូវការដ៏ធំធេងសំរាប់ការវាស់វែងដោយផ្ទាល់នូវលទ្ធផល ដើម្បីតាមមើលពីការវិវឌ្ឍន៏ ពីការឈានដល់ទិសដៅការអភិវឌ្ឍន៏សហសវត្សរ៏ និងវាយតំលៃកម្មវិធីនានាក្នុងការទប់ស្កាត់ជំងឺ និង ការផ្តួចផ្តើមកម្មវិធីសុខាភិបាលជាសកលធំៗ -រាប់ទាំងអន្តរាគមន៏ដែលមានបំណងកាត់បន្ថយការស្លាប់ដោយសារជំងឺឬលក្ខខណ្ឌជាក់លាក់នានា។ នៅកន្លែងដែលការគ្របដណ្តប់នៃសំបុត្រមរណៈភាពខ្ពស់ និងតំណាង ហើយគុណភាពឯកសារវេជ្ជសាស្ត្រ ខ្ពស់និងប្រាកដ ការចុះបញ្ជីស៊ីវិលនិងឯកសារសុខាភិបាលគឺជាប្រភពទិន្នន័យដែលគេចូលចិត្ត ក្នុងការគណនាអាំងឌីកាទ័រទាំងនេះ។ ក្នុងតថភាពគឺសំរាប់អ្នកក្រ ជាញឹកញាប់គឺប្រជាជននៅជនបទដែលអន្តរាគមន៏ និងគោលនយោបាយថ្មីៗ ត្រូវរៀបចំឡើងសំរាប់កាត់បន្ថយមរណៈភាពសំរាប់ពួកគេ ជាញឹកញាប់បណ្តាលមកពីជំងឺ ឬលក្ខខណ្ឌជាក់លាក់នានា-កោសល្យវិច័យផ្ទាល់មាត់សំរាប់រាល់ការខ្វះខាតរបស់វា នៅតែស្ថិតនៅជាជំរើសក្នុងការអនុវត្តសំរាប់វាស់វែងក៏រិតនានា និងទំនោរក្នុងមូលហេតុជាក់លាក់ [2]។

ចុងក្រោយបំផុត ទស្សវត្សរ៏នៃកំណែទំរង់វិស័យសុខាភិបាល បានដាក់តំលៃខ្ពស់ទៅលើការធ្វើផែនការ " ផ្អែកលើភស្តុតាង " និងកំណត់អាទិភាព-ជាញឹកញាប់នៅលំដាប់បន្ទាប់ពីថ្នាក់ជាតិ។ ទិន្នន័យពីមរណៈភាព (ជាញឹកញាប់បង្កើតមកពីកោសល្យវិច័យផ្ទាល់មាត់) បាន និងកំពុងជាធនធានដាក់ចូលយ៉ាងសំខាន់ទៅក្នុងដំណើរការទាំងនេះ [19]។ ទិន្នន័យទាំងនេះធ្វើអោយកញ្ចប់អន្តរាគមន៏ថ្នាក់ជាតិ និងស្រុកផ្អែកទៅលើភស្តុតាងដែលល្អប្រសើរ។ តំរូវចំពោះការសំរេចជាឯកច្ឆន័ទៅលើសំណុំស្នូលនៃស្តង់ដារបច្ចេកទេស និងទៅលើសេចក្តីណែនាំសំរាប់កោសល្យវិច័យផ្ទាល់មាត់ ជាមួយនឹងការគាំទ្រទូលំទូលាយរបស់វា និងការសំរបយកគឺជាកិច្ចការបន្ទាន់។ ខណៈដែលមានសំណួរជាច្រើនអំពីភាពជាក់លាក់របស់កោសល្យវិច័យផ្ទាល់មាត់សំរាប់វាយតំលៃមូលហេតុស្លាប់ខ្លះនោះ វាមានការលំបាកណាស់ក្នុង

ការនិយាយពន្លើសអំពីផលប្រយោជន៍ដែលទទួលបានដោយការប្រើប្រាស់របៀបកោសល្យវិច័យផ្ទាល់មាត់ជាស្តង់ដារ ក្នុងការទទួលបាននូវតំណាងស្ថិតិមរណៈភាព នៅក្នុងប្រទេសនានាដែលមានប្រពន្ធ័ចុះបញ្ជីជីវៈមិនទាន់សមស្រប ។

វិធីសាស្ត្រកោសល្យវិច័យផ្ទាល់មាត់នានានៅតែកំពុងវិវឌ្ឍន៍ ។ វិសយ័ជាច្រើននៃការស្រាវជ្រាវដែលសកម្ម និងសំខាន់នៅក្នុងកោសល្យវិច័យផ្ទាល់មាត់នៅតែមាន ។ ទាំងនេះរួមទាំងប្រធានបទទាំងឡាយដូចជា ការពង្រីកអោយកាន់តែទូលំទូលាយថែមទៀតនូវកំរងសំណួរ និងវិធីសាស្ត្រស្ថិតិសំរាប់វាយចាត់មូលហេតុស្លាប់បានមកពីកោសល្យវិច័យផ្ទាល់មាត់ដែរ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាថាទិន្នន័យអំពីមរណៈភាពដោយមូលហេតុជាក់លាក់យកចេញពីកោសល្យវិច័យផ្ទាល់មាត់ នៅឆ្នាំបន្ទាប់នឹងមានផលប្រយោជន៍ដ៏ធំធេងចំពោះអ្នកដែលផលិតវា ក៏ដូចជាចំពោះអ្នកដែលប្រើប្រាស់វា ក្នុងគោលបំណងប្រៀបធៀបគេជំរុញថា ធនធានជាស្តង់ដារថ្មីនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះសំរាប់កិច្ចខិតខំប្រមូលទិន្នន័យកោសល្យវិច័យផ្ទាល់មាត់នៅទីណាដែលអាចធ្វើទៅបាន ។

## ១.៣ ឯកសារយោង


1. *International statistical classification of diseases and related health problems*, tenth revision, 2nd ed. Geneva, World Health Organization, 2005.

2. Soleman N, Chandramohan D, Shibuya K. Verbal autopsy: current practices and challenges. *Bulletin of the World Health Organization*, 2006, 84:239–245.

3. Fauveau V. Assessing probable causes of death without death registration or certificates: a new science? *Bulletin of the World Health Organization*, 2006, 84:246–247.

4. Murray CJL, Lopez AD, eds. *The global burden of disease*. Boston, Harvard School of Public Health on behalf of the World Health Organization and the World Bank, 1996.

5. Anker M et al. *A standard verbal autopsy method for investigating causes of death in infants and children*. Geneva, World Health Organization, 1999 (WHO/CDS/CSR/ISR/99.4; http://whqlibdoc.who.int/hq/1999/WHO_CDS_CSR_ISR_99.4.pdf, accessed 23 July 2007).

6. INDEPTH Network. INDEPTH Standardized Verbal Autopsy questionnaire. Revised August 2003 (http://www.indepth-network.org/core_documents/indepthtools.htm).

7. Setel PW et al. Proposed core verbal autopsy procedures for use in sample vital registration, with comparative findings from validation studies in China and Tanzania. *PLoS Medicine*, 2006, 3:e268.

8. Reeves BC, Quigly M. A review of data-derived methods for assigning causes of death from verbal autopsy data. *International Journal of Epidemiology*, 1997, 26:1080–1096.

9. Quigley MA, Chandramohan D, Rodrigues LC. Diagnostic accuracy of physician review, expert algorithms and data-derived algorithms in adult verbal autopsies. *International Journal of Epidemiology*, 1999, 28:1081–1087.

10. Boulle A, Chandramohan D, Weller P. A case study of using artificial neural networks for classifying cause of death from verbal autopsy. *International Journal of Epidemiology*, 2001, 30:515-20.

11. Byass P, Huong DL, Minh HV. A probabilistic approach to interpreting verbal autopsies: methodology and preliminary validation in Vietnam. *Scandinavian Journal of Public Health*, 2003, 31 (Suppl.62):32–37.

12. Kalter HD et al. Validation of caregiver interviews to diagnose common causes of severe neonatal illness. *Paediatric Perinatal Epidemiology*, 1999, 13:99–113.

13. Williams BG et al. Estimates of world-wide distribution of child deaths from acute respiratory infections. *Lancet (Infectious Diseases)*, 2002, 2:25–32.

14. Morris SS, Black RE, Tomaskovic L. Predicting the distribution of under-five deaths by cause in countries without adequate vital registration systems. *International Journal of Epidemiology*, 2003, 32:1041–1051.

15. Black RE, Morris SS, Bryce J. Where and why are 10 million children dying every year? *Lancet*, 2003, 361:2226–2234.

16. Korenromp EL et al. Measurement of trends in childhood malaria mortality in Africa: an assessment of progress toward targets based on verbal autopsy. *Lancet Infectious Diseases*, 2003, 3:349–358.

17. Adjuik M et al. Cause-specific mortality rates in sub-Saharan Africa and Bangladesh. *Bulletin of the World Health Organization*, 2006, 84:181–188.

18. Chandramohan D et al. Editorial: ethical issues in the application of verbal autopsies in mortality surveillance systems. *Tropical Medicine and International Health*, 2005, 10:1087–1089.

19. Kapiriri L, Norheim OF, Heggenhougen K. Using burden of disease information for health planning in developing countries: the experience from Uganda. *Social Science and Medicine*, 2003, 56:2433–2441.
1. Development of verbal autopsy standards

20. Murray CJL, et al. Validation of the symptom pattern method for analyzing verbal autopsy data. *PLoS Medicine.* In ressp .

# ២. កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ជាស្តង់ដារអន្តរជាតិ

## ២.១. សេចក្តីផ្តើម

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ជាស្តង់ដារអន្តរជាតិទាំងបី មានបំណងបំរើសេចក្តីត្រូវការនៃពហុអ្នកប្រើប្រាស់និងអ្នកផលិតនូវពតិមានមរណៈភាព រាប់ទាំងអ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសកម្មភាពតាមដាននិងវាយតំលៃ។ កំរងសំណួរទាំងនេះគឺជាផលិតផលដែលបានមកពីការពិនិត្យមើលឡើងវិញ យ៉ាងម៉ត់ចត់របស់អ្នកជំនាញការទៅលើរាល់កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ដែលកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនាពេលបច្ចុប្បន្ន និងជាពិសេសរាល់កំរងសំណួរដែលបានផ្តល់សុពលភាពរួចហើយ (ឧទា. [1–4])។

វាជាការសំខាន់ដែលត្រូវដឹងថា កោសល្យវិច័យផ្ទាល់មាត់ មិនអាចធ្វើអោយប្រាកដនូវមូលហេតុស្លាប់ទេ។ លើសពីនេះទៅទៀតដូចដែលការសិក្សាសុពលភាពជាច្រើនបានបង្ហាញ កោសល្យវិច័យផ្ទាល់មាត់មិនបានធ្វើឡើងស្មើៗគ្នាសំរាប់រាល់មូលហេតុដែលវាអាចបញ្ជាក់នោះទេ។ ដោយគិតពីចំណុចខ្វះខាតនេះ កំរងសំណួរស្តង់ដារ ត្រូវបានរៀបចំឡើងនៅក្នុងមធ្យោបាយដើម្បី :

- ធ្វើការបញ្ជាក់និងដើម្បីរៀបកូដ ICD-10
- ធ្វើអោយប្រាកដនូវរាល់ មូលហេតុស្លាប់ ដែលអាចបានមកជាមួយនឹងភាពត្រឹមត្រូវសមស្រប ពីការសំភាសន៏កោសល្យវិច័យផ្ទាល់មាត់ដែលមានការរៀបចំបានល្អ (ចូរមើលតារាងដែលទាក់ទងនៅភាគ3 ផ្នែកទី3.9)។

ក្រុមជំនាញការដែលជាអ្នកពិនិត្យមើល បានឈានដល់ការព្រមព្រៀងទៅលើកំរងសំណួរជាស្តង់ដារដែលនាំអោយមានការបន្ថែមអថេរនៃប្រធានបទដែលគេចាប់អារម្មណ៏ (ឧទា.កត្តាបង្ក) នៅពេលដែលចាំបាច់។ នៅពេលដែលការកើនឡើងនៃកំរងសំណួរស្តង់ដារនេះមិនចាំបាច់ជំរុញនោះ(ចូរមើល “Guidelines on augmentation, translation and local adaptation” ខាងក្រោម)ក៏ដូចជាស្តង់ដារអថេរដែលត្រូវបានដាក់បញ្ចូល ការបញ្ជាក់មូលហេតុស្លាប់ត្រឹមត្រូវ និងរបៀបដាក់កូដត្រូវបានប្រើប្រាស់ វាគួរតែអាចបង្កើតបាននូវទិន្នន័យដែលអាចប្រៀបធៀបបាន ទៅតាមពេលវេលារវាងប្រជាជននានា។

## ២.២. កំរងសំណួរស្តង់ដារនៃកោសល្យវិច័យផ្ទាល់មាត់

### ២.២.១ រូបធាតុរួម

រាល់កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ស្តង់ដារ មានទាំងពីរ គឺរូបធាតុរួម និងផ្នែកនានា (ឬម៉ូឌុលនានា) ដែលសមស្របសំរាប់ ទាំងអាយុ និងភេទ របស់អ្នកស្លាប់។ រូបធាតុរួម រួមមាន ម៉ូឌុល "ពតិមានទូទៅ" និងសំណួរនានាដែលទាក់ទងនឹងមូលហេតុស្លាប់មួយចំនួន និងរោគសញ្ញានិងបណ្តុំរោគសញ្ញាទូទៅមួយចំនួន។ ម៉ូឌុល "ពតិមានទូទៅ" - នៅទំព័រដំបូងនៃកំរងសំណួរនិមួយៗ - មានអត្តសញ្ញាណសំខាន់ៗ និងពតិមានពីសង្គមប្រជាសាស្រ្ត។ នៅកន្លែងសំរាប់ទិន្នន័យដែលចាំបាច់សំរាប់ចាត់ចែងទំរង់ដែលបំពេញរួចហើយ។ គេអោយយោបល់អំពីមាតិកាជាស្តង់ដែលបញ្ជាក់ និងកត់ត្រា:

- លេខសំគាល់ ( ID )តែមួយ លេខសំរាប់ត្រួតពិនិត្យ ឬសំរាប់យោង សំរាប់កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ដែលបំពេញចប់សព្វគ្រប់ហើយ

- ថ្ងៃខែឆ្នាំ ទីកន្លែងនិងពេលវេលាដែលសំភាសន៍ និងបញ្ជាក់អ្នកធ្វើសំភាសន៍
- លក្ខណៈសំខាន់ៗរបស់អ្នកឆ្លើយ
- ពេល កន្លែង និង ថ្ងៃខែឆ្នាំស្លាប់
- ឈ្មោះ ភេទ និង អាយុរបស់អ្នកស្លាប់
- មូលហេតុមរណៈភាព និងព្រឹត្តិការណ៍ដែលឈានដល់ស្លាប់ អាស្រយ័ទៅតាមអ្នកឆ្លើយ

ម៉ូឌុលកំរងសំណួរស្តង់ដារដ៏ទៃទៀត រួមមានៈ

- ប្រវត្តិលក្ខខណ្ឌ័សុខភាពពីមុនមកដែលដឹង (របស់អ្នកស្លាប់ ឬរបស់ម្តាយអ្នកស្លាប់)
- ប្រវត្តិរបួស ឬ គ្រោះថ្នាក់
- ការព្យាបាល និងសេវាំសុខាភិបាលដែលប្រើក្នុងអំឡុងពេលឈឺចុងក្រោយបំផុត
- ទិន្នន័យដែលទាញចេញពីសំបុត្រមរណៈភាព ការពិនិត្យផ្ទៃពោះ ឬបណ្ណ័សុខភាពគ្លីនិករបស់ម្តាយនិងកុមារ ឬរបាយការណ៍វេជ្ជសាស្រ្តដ៏ទៃទៀត និងឯកសារភស្តុតាងដែលទាក់ទងនានានៅនឹងគ្រួសារ

ម៉ូឌុលទាំងនេះ ដោយមានការលើកលែងតិចតួច វាដូចគ្នាទាំងអស់ពីកំរងសំណួរស្តង់ដារមួយទៅកំរងសំណួរស្តង់ដារមួយ នៃកំរងសំណួរស្តង់ដារទាំងបី។ ម៉ូឌុលនៃកំរងសំណួរនិមួយៗដែលផ្ទុកទៅដោយពតិមានសំខាន់ៗសំរាប់ការបញ្ជាក់មូលហេតុស្លាប់មានបញ្ជីត្រួតពិនិត្យមួយដើម្បីកត់សំគាល់"រោគសញ្ញា និងបណ្តុំរោគសញ្ញាដែលគេសំគាល់ឃើញក្នុងអំឡុងពេលឈឺចុងក្រោយ" ។

ជាមួយនឹងការលើកលែងនៃសំណួរអំពីរបួសនិងគ្រោះថ្នាក់ និងសំណួរមួយចំនួនអំពីរោគសញ្ញានិងបណ្តុំរោគសញ្ញាប្រពន្ធ័ទូទៅ (ឧទា. គ្រុនក្តៅ ឬរោគសញ្ញានិងបណ្តុំរោគសញ្ញាពោះវៀន) សំណួរដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យរោគសញ្ញានិងបណ្តុំរោគសញ្ញាប្រែប្រួលអាស្រយ័ទៅលើអាយុ ឬភេទរបស់អ្នកស្លាប់។

## ២.២.២ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ១: ការស្លាប់របស់កុមារអាយុក្រោមបួនសប្តាហ៍

គោលបំណងរបស់កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ១ គឺបែងចែងរវាងការស្លាប់កើត ការស្លាប់នៅដើមអាយុដំបូងរបស់ទារក និងការស្លាប់នៅចុងអាយុរបស់ទារក និងដើម្បីកំណត់មូលហេតុនៃព្រឹត្តិការណ៍ជុំវិញកំណើត និងមរណៈភាព។ បន្ថែមពីលើបញ្ជីត្រួតពិនិត្យ"រោគសញ្ញា និងបណ្តុំរោគសញ្ញាដែលគេសំគាល់ឃើញក្នុងអំឡុងពេលឈឺចុងក្រោយ" កំរងសំណួរផ្ទុកទៅដោយសំណួរយ៉ាងច្រើន ដែលពាក់ពន្ធ័នឹងប្រវត្តិពពោះ ការសំរាល លក្ខខណ្ឌ័ទារកក្រោយពេលកើតមកភ្លាម និងសុខភាពរបស់មាតា និងកត្តាពាក់ពន្ធ័។

## ២.២.៣ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ២: ការស្លាប់របស់កុមារអាយុ៤សប្តាហ៍ទៅ១៤ឆ្នាំ

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ២ រៀបរៀងឡើងដើម្បីបញ្ជាក់មូលហេតុធំៗនៃការស្លាប់របស់ទារកក្រោយ28ថ្ងៃនៃការសំរាល (គឺថាចាប់ផ្តើមពីសប្តាហ៏ទីបួននៃជីវិត) ក៏ដូចជាមូលហេតុនៃការស្លាប់ដែលអាចឃើញមានក្នុងរយៈពេលឆ្លងកាត់ ១៤ឆ្នាំ។ កំរងសំណួរបញ្ចូលគ្រប់ម៉ូឌុលស្តង់ដារទាំងអស់ដែលរៀបរាប់ខាងលើ និងម៉ូឌុលសំរាប់កុមារ ៤សប្តាហ៏ទៅ ១១ខែ។

## ២.២.៤ កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ៣: ការស្លាប់របស់មនុស្សអាយុចាប់ពី ១៥ឆ្នាំឡើងទៅ

កំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ ៣ រៀបរៀងឡើងដើម្បីបញ្ជាក់មូលហេតុធំៗនៃការស្លាប់របស់មនុស្សជំទង់ និងមនុស្សពេញវ័យ (គឺថាចាប់ពីអាយុ ១៥ឆ្នាំ) ដោយរាប់ទាំងការស្លាប់ទាក់ទងនឹងការមានផ្ទៃពោះ និងកំណើតកូន។ កំរងសំណួររាប់បញ្ចូលយ៉ាងច្រើននូវម៉ូឌុលមួយសំរាប់ការស្លាប់របស់ស្ត្រី។ កំរងសំណួរ 3 ក៏រាប់បញ្ចូលផងដែរនូវកត្តាគ្រោះថ្នាក់នៃការប្រព្រឹត្ត (ឧទា. ផឹកស្រា និង ជក់បារី)។

## ២.៣ អ្នកឆ្លើយដែលសមស្រប និងរយ:កាលរំលឹក

អ្នកឆ្លើយដែលផ្តល់ពតិមានអំពីអ្នកស្លាប់ និងអនុញ្ញាតិអោយអ្នកសំភាសន៍បំពេញចប់សព្វគ្រប់នូវកំរងសំណួរ កោសល្យវិច័យផ្ទាល់មាត់គួរតែជាអ្នកថែទាំផ្ទាល់ (ជាទូទៅ ជាសមាជិកគ្រួសារ) ដែលនៅជាមួយនឹងអ្នកស្លាប់ក្នុងអំឡុងពេលឈានទៅរកការស្លាប់។ មនុស្សនេះ គឺសមនឹងផ្តល់នូវរោគសញ្ញានិងបណ្តុំរោគសញ្ញាដែលអាចជឿជាក់និងត្រឹមត្រូវបំផុត។ វាមិនមែនជារឿងមិនធម្មតានោះទេ សំរាប់អ្នកឆ្លើយនឹងសំណួរកោសល្យវិច័យផ្ទាល់មាត់ ត្រូវការជំនួយពីអ្នកក្នុងផ្ទះឬសមាជិកគ្រួសារឯទៀត ក្នុងការឆ្លើយនឹងសំណួរ។

ការសាកសួរកោសល្យវិច័យផ្ទាល់មាត់ ដែលធ្វើឡើងជាផ្នែកនៃការចុះបញ្ជីតទៅមុខ ឬសកម្មភាពឃ្លាំមើល គួរតែធ្វើឡើងអោយបានឆាប់តាមតែការអនុវត្តទៅបាន ក្រោយពីទទួលបាននូវរបាយការណ៍ពីព្រឹត្តិការណ៍ តែក្រោយពីរយ:ពេលមរណ:ទុក្ខបច្ចុប្បន្នបានកន្លងទៅ។ នៅពេលដែលកោសល្យវិច័យផ្ទាល់មាត់ត្រូវបានបញ្ចូលទៅក្នុងការអង្កេតគ្រួសារតាមបែប Cross-sectional នោះ ការរំលឹកនូវហេតុការណ៍ដែលលើសពីមួយឆ្នាំគួរតែធ្វើឡើងដោយប្រយត្ន័ប្រយែង។ រយ:ពេលនឹកឡើងវិញខ្លីគឺជាការប្រសើរ និងត្រូវការការស្រាវជ្រាវច្រើនទៀតទៅលើប្រសិទ្ធភាពនៃការនឹកឡើងវិញនូវព្រឹត្តិការណ៍ ដែលមានរយ:ពេលលើសពី ១២ខែអំពីភាពត្រឹមត្រូវរបស់កោសល្យវិច័យផ្ទាល់មាត់។

## ២.៤ គោលការណ៍ណែនាំអំពីការបន្ថែម ការបកប្រែ និងការសំរបយកទៅតាមកន្លែង

កំរងសំណួរស្តង់ដារអន្តរជាតិនៃកោសល្យវិច័យផ្ទាល់មាត់ គួរលើកឡើងអំពីមូលហេតុស្លាប់ធំៗ នៅក្នុងប្រជាជនភាគច្រើន ដែលការប្រើកោសល្យវិច័យផ្ទាល់មាត់នៅទីនោះ ជាមធ្យោបាយចាំបាច់សំរាប់ទទួលបានពតិមាននៃការស្លាប់។ ការកែសំរួលបញ្ជីត្រួតពិនិត្យ "រោគសញ្ញា និង បណ្តុំរោគសញ្ញាដែលគេសំគាល់ឃើញក្នុងអំឡុងពេលឈឺចុងក្រោយ" នៃកំរងសំណួរស្តង់ដារ គួរតែធ្វើឡើងដោយប្រយត្ន័ប្រយែង ពីព្រោះការកែតំរូវច្រើន អាចនឹងសម្រុះសម្រួលនូវភាពអាចប្រៀបធៀបបានរបស់ទិន្នន័យកោសល្យវិច័យផ្ទាល់មាត់រវាងប្រជាជននានា។

ជាពិសេស ការបន្ថែមសំណួរថ្មីៗអំពីជំងឺពិសេសៗដែលគេចង់ដឹង អាចនឹងធ្វើអោយលំអៀងលទ្ធផល ប្រសិនបើចំនួនពតិមានមិនតុល្យភាពគ្នា ហើយមានតែអំពីលក្ខ័ខណ្ឌមួយ ក្នុងដំណើរការចាត់មូលហេតុស្លាប់។ ប្រសិនបើចាំបាច់មែនទែន ការកែសំរួល គួរតែរៀបចំទុកជាឯកសារយ៉ាងប្រយ័ត្នប្រយែង និងបែងចែងពីម៉ូឌុលកំរងសំណួរស្តង់ដារ និងអថេរ។ នេះអាចជាករណី ប្រសិនបើមានការលេចឡើង ឬក៏មានសារ:សំខាន់នៅនឹងកន្លែង នូវមូលហេតុស្លាប់ដែលមិនទាន់មានសំណួរនៅក្នុងកំរងសំណួរកោសល្យវិច័យផ្ទាល់មាត់ស្តង់ដារ។

ក្នុងកាលទេសៈបែបនេះ គួរតែស្វែងរកគំរូទ្ទានពី WHO ដើម្បីធ្វើការកែសំរួល។ ជាទូទៅ គឺមានតែការផ្លាស់ប្តូរពាក្យនៃអថេរដែលមានហើយប៉ុណ្ណោះដែលគួរកែសំរួល ក្នុងគោលបំណងបង្កើនការយល់ដឹងគ្រប់ជ្រុងជ្រោយទៅតាមកន្លែង ឬដើម្បីធានាវប្បធម៌នៃការទទួលយកនៃ សំណួរនានា។

ឧទាហរណ៍នៃការកែសំរួល ដែលដូចជាមិនប៉ះពាល់ដល់ការដែលអាចប្រៀបធៀបបាននៃលទ្ធផល មានជាអាទិ៍:

- បន្ថែមសំណួរ ឬម៉ូឌុលអំពីលក្ខណៈរបស់គ្រួសារ និងកត្តាបង្កគ្រោះថ្នាក់ ដែលជាបរិយាកាសឬដែលជាការប្រព្រឹត្តិ។
- បន្ថែម ឬប្តូរសំណួរអំពីការប្រើប្រាស់សេវាសុខភាព ឬអន្តរាគមន៍សុខាភិបាល ពិសេសណាមួយ។

ឧទាហរណ៍នៃការកែសំរួលដែលអាចប៉ះពាល់ដល់ភាពដែលអាចប្រៀបធៀបបានរបស់លទ្ធផល មានដូចជា:

- ផ្លាស់ប្តូរ ឬបន្ថែមទៅក្នុងប្រភេទចំលើយ នៅក្នុងបញ្ជីត្រួតពិនិត្យ នៃ "រោគសញ្ញា និង បណ្តុំរោគសញ្ញា ដែលគេសំគាល់ឃើញក្នុងអំឡុងពេលឈឺចុងក្រោយ" ។
- បន្ថែមសំណួរថ្មីៗអំពីជំងឺនានាដែលខ្លួនចាប់ជាពិសេស (ឧទា.គ្រុនចាញ់ HIV/AIDS ជំងឺរាគ)។

## ២.៥ ឯកសារយោង

1. Anker M et al. *A standard verbal autopsy method for investigating causes of death in infants and children.* Geneva, World Health Organization, 1999 (WHO/CDS/CSR/ISR/99.4; http://whqlibdoc.who.int/hq/1999/WHO_CDS_CSR_ISR_99.4.pdf, accessed 23 July 2007).

2. Chandramohan D et al. Verbal autopsies for adult deaths: their development and validation in a multi-centre study. *Tropical Medicine and International Health,* 1998, 3:436–446.

3. Setel PW et al. Validity of verbal autopsy procedures for determining cause of death in Tanzania. *Tropical Medicine and International Health,* 2006, 11:608–703.

4. Yang G et al. Validation of verbal autopsy procedures for adult deaths in China. *International Journal of Epidemiology,* 2006, 35:741–748.

# គំរូសំណួរគោលស្រាវជ្រាវផ្ទាល់មាត់ ស្តង់ដារអន្តរជាតិ ១

## មរណៈភាពទារកអាយុតិចជាង ៤ សប្តាហ៍

លេខសំគាល់/ត្រួតពិនិត្យ/យោង □□□□□□

**ផ្នែក1.1 ការចុះទៅសួរសុខទុករបស់អ្នកសំភាសន៍**

| | 1 | 2 | 3 | ការចុះ |
|---|---|---|---|---|
| ថ្ងៃ | ______ | ______ | ______ | ថ្ងៃ |
| | | | | ខែ |
| | | | | ឆ្នាំ |
| ឈ្មោះអ្នកសំភាសន៍ | ______ | ______ | ______ | លេខអ្ន |
| លទ្ធផល* | □ | □ | □ | លទ្ធផ |
| ការចុះទៅបន្ទាប់: ថ្ងៃ | ______ | ______ | | ចំនួនចុះ |
| ម៉ោង | ______ | ______ | | |

1 ចប់សព្វគ្រប់ 2 មិននៅផ្ទះ 3 លើកពេល 4 បដិសេធ 5 ចប់ដោយផ្នែក 6 មិនជួបអ្នកផ្តល់ចំលើយសមស្រប 7 ផ្សេងទៀត បញ្ជាក់ ------------------

| អ្នកអភិបាល | អ្នកពិនិត្យនៅនឹងកន្លែង | អ្នកពិនិត្យនេ |
|---|---|---|
| ឈ្មោះ ------------------□□ | ឈ្មោះ ---------------□□ | បញ្ចូលដោយ |
| ថ្ងៃ: ------------------□□ | ថ្ងៃ: --------------- □□ | ការិយាល័យ |
| | | □□ |
| | | □□ |

ឈ្មោះកន្លែង ----------------------------------------

អាស័យដ្ឋាន/ទិសទៅរកផ្ទះ ---------------------------------------------------------------

---------------------------------------------------------------------------------

ផ្នែក 1.2 ពតិមានប្រជាសាស្ត្របន្ថែម

(សំរាប់ប្រើនៅក្នុងការចុះបញ្ជីជីវៈដោយប្រើតំណាងអង្កេត ឬទីឃ្លាំមើលប្រជាសាស្ត្រ)

តំបន់/ខេត្ត---------------

កន្លែង ---------------------------------------

លេខផ្ទះ --------------------------------------

ឈ្មោះអ្នកធានា --------------------------------

ស្ថានភាពទីលំនៅរបស់អ្នកស្លាប់---------------------

តំបន់/ខេត្ត--------------- □

កន្លែង ----------------- □

លេខផ្ទះ ---- □

រស់នៅកន្លែងដែលកំពុងអង្កេត--------

1

សពនាំមកកប់នៅផ្ទះ ------------

| | |
|---|---|
| | 2<br>មកផ្ទះពេលដែលឈឺ--------------<br>3 |

គំរូការយល់ព្រមផ្តល់ពតិមាន

ជំរាបសួរ ខ្ញុំឈ្មោះ ---------------ហើយខ្ញុំធ្វើការអោយ (ឈ្មោះភ្នាក់ងារ)។ យើងប្រមូលពតិមានអំពីមូលហេតុស្លាប់នៅក្នុងសហគមន៍។ យើងខ្ញុំមានការកោតសរសើយ៉ាងខ្លាំងចំពោះការចូលរួមរបស់អ្នកនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ យើងខ្ញុំចង់សាកសួរលោក អ្នកអំពីកាលៈទេសៈដែលនាំទៅរកការស្លាប់របស់អ្នកស្លាប់។ ពតិមានអ្វីក៏ដោយដែលអ្នកផ្តល់អោយនឹងត្រូវរក្សា ការសំងាត់យ៉ាងម៉ឹង ម៉ាត់។ មិនមានពតិមានដែលកំណត់អត្តសញ្ញាណអ្នក ឬអ្នកស្លាប់ នឹងត្រូវបញ្ចេញអោយទៅនរណាម្នាក់ ខាងក្រៅពីការប្រមូលទិន្នន័យ នេះឡើយ។ ការចូលរួមនៅក្នុងការអង្កេតនេះគឺធ្វើឡើងដោយស្មគ្រ័ចិត្ត ហើយអ្នកអាចជ្រើសរើស មិនឆ្លើយនឹងសំណួរណាមួយ ឬសំណួរទាំងអស់។ អ្នកអាចនឹងបញ្ឈប់កិច្ចសំភាសន៍តែម្តងនៅពេលណាក៏បានដោយមិនមានផលវិបាកអ្វីទាំងអស់។ តែយ៉ាងណាក៏ ដោយ យើងខ្ញុំសង្ឃឹមថា អ្នកនឹងចូលរួមក្នុងការអង្កេតនេះ ដោយហេតុថា លទ្ធផលនឹងជួយដល់រដ្ឋាភិបាលធ្វើអោយប្រសើរឡើងនូវសេវានានាសំរាប់ប្រជាជន។

មកទល់នឹងពេលនេះ តើអ្នកមានចង់សួរខ្ញុំអំពីគោលបំណង ឬមាតិកានៃការសំភាសន៍នេះដែរឬទេ?

តើខ្ញុំអាចចាប់ផ្តើមការសំភាសន៍បានហើយឬនៅពេលនេះ?

ហត្ថលេខាអ្នកសំភាសន៍ ------------------- ថ្ងៃ ខែ ---------------------

អ្នកផ្តល់ចំលើយ យល់ព្រមអោយសំភាសន៍ ---1 ↓ អ្នកផ្តល់ចំលើយមិនអនុញ្ញាតអោយសំភាសន៍ ---2 ⟶ ចប់

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 2. ពត៌មានជាមូលដ្ឋាន អំពីអ្នកឆ្លើយ** | | | |
| 201 | កត់ត្រា ពេលចាប់ផ្តើមសំភាសន៍ | ម៉ោង ------------- □□<br>នាទី -------------- □□ | |
| 202 | ឈ្មោះអ្នកឆ្លើយ | ---------------------------<br>(ឈ្មោះ) | |
| 203 | តើអ្នកមានទំនាក់ទំនងអ្វីនឹងអ្នកស្លាប់? | ឪពុក---------------------- 1<br>ម្តាយ--------------------- 2<br>បងប្អូន-------------------- 4<br>សាច់ញាតិដ៏ទៃទៀត------------ 6<br>(បញ្ជាក់)<br>គ្មានទំនាក់ទំនង--------------- 8 | |
| 204 | តើអ្នករស់នៅជាមួយអ្នកស្លាប់ ក្នុងអំឡុងពេលដែលឈានទៅរកមរណៈភាពរបស់គាត់ឬ? | បាទ/ចាស់------------------- 1<br>ទេ----------------------- 2 | |
| **ផ្នែក 3. ពត៌មានអំពីអ្នកស្លាប់ និង ថ្ងៃ ខែ/ទីកន្លែង ស្លាប់** | | | |
| 301 | តើអ្នកស្លាប់ឈ្មោះអ្វី | ---------------------------<br>(ឈ្មោះ) | |
| 302 | តើអ្នកស្លាប់ស្រី ឬប្រុស | ស្រី----------------------- 1<br>ប្រុស--------------------- 2 | |
| 303 | តើអ្នកស្លាប់កើតពេលណា?<br>**កត់ត្រា '98' បើមិនដឹងថ្ងៃ ឬខែ**<br>**កត់ត្រា '9998' បើមិនដឹងឆ្នាំ** | ថ្ងៃ-------------- □□<br>ខែ-------------- □□<br>ឆ្នាំ------------- □□□□ | |
| 304 | តើអ្នកស្លាប់មានអាយុប៉ុន្មានពេលដែលគាត់ស្លាប់ | អាយុជាថ្ងៃ-------------- □□ | |
| 305 | តើគាត់ស្លាប់ពេលណា?<br>**កត់ត្រា '98' បើមិនដឹងថ្ងៃ ឬខែ**<br>**កត់ត្រា '9998' បើមិនដឹងឆ្នាំ** | ថ្ងៃ-------------- □□<br>ខែ-------------- □□<br>ឆ្នាំ------------- □□□□ | |
| 306 | តើគាត់ស្លាប់នៅឯណា? | មន្ទីរពេទ្យ-------------------- 1<br>កន្លែងពេទ្យផ្សេងទៀត----------- 2<br>នៅផ្ទះ--------------------- 4<br>ផ្សេងទៀត------------------- 6<br>(បញ្ជាក់)<br>មិនដឹង --------------------- 8 | |

**ផ្នែក 4. អ្នកឆ្លើយរ៉ាប់រងជំងឺ/ព្រឹត្តិការណ៍ ឈានទៅមរណៈភាព**

| | |
|---|---|
| 401 | តើអ្នកអាចប្រាប់ខ្ញុំអំពីជំងឺ/ព្រឹត្តិការណ៍ដែលបណ្តាល អោយគាត់ស្លាប់ បានដែរឬទេ?<br>------------------------------------------------------------------------<br>------------------------------------------------------------------------<br>------------------------------------------------------------------------<br>------------------------------------------------------------------------<br>------------------------------------------------------------------------ |
| 402 | មូលហេតុស្លាប់ ទី1 បើតាមអ្នកឆ្លើយ<br>------------------------------------------------------------------------ |
| 403 | មូលហេតុស្លាប់ ទី2 បើតាមអ្នកឆ្លើយ<br>------------------------------------------------------------------------ |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 5. ប្រវត្តិពរពោះ** | | | |
| 501 | ខ្ញុំចង់សួរអ្នកនូវសំណួរខ្លះដែលទាក់ទងនឹងម្តាយ និង បណ្តុំរោគសញ្ញាដែលស្លាប់មាន/បានបង្ហាញ ពេលកើត និងមួយរយៈខ្លីក្រោយកើត។ សំណួរខ្លះនៃសំណួរទាំងនេះ នឹងមិន ទាក់ទងផ្ទាល់នឹងការស្លាប់របស់ទារកទេ។ សូមអ្នកអត់អោនខ្ញុំដោយខន្តី និង ឆ្លើយនូវរាល់សំណួរ។ ចំលើយទាំងនេះនឹងជួយយើងខ្ញុំទទួលបាននូវភាពច្បាស់លាស់នូវរាល់បណ្តុំរោគសញ្ញាទាំងអស់ដែលអ្នកស្លាប់មាន។ | | |
| 502 | តើមានការសំរាលប៉ុន្មាន រាប់ទាំងស្លាប់កើត ដែលម្តាយមាន មុននឹងកើតទារកនេះ? | ចំនួនសំរាល/ស្លាប់កើត-------- ☐☐<br>មិនដឹង-------------------- 98 | |
| 503 | តើផ្ទៃពោះប៉ុន្មានខែពេលដែលទារកកើត? | ខែ--------------------- ☐☐<br>មិនដឹង-------------------- 98 | |
| 504 | តើផ្ទៃពោះចប់មុនពេលដែលរំពឹងទុកឬ? | បាទ/ចាស់----------------- 1<br>ទេ----------------------- 2<br>មិនដឹង--------------------- 8 | <br>→ 508<br>→ 508 |
| 505 | តើប៉ុន្មានសប្តាហ៍មុនពេលរំពឹងទុក ដែលត្រូវសំរាល? | សប្តាហ៍----------------- ☐☐<br>មិនដឹង-------------------- 98 | |
| 506 | តើក្នុងរយៈពេលមានផ្ទៃពោះ តើស្ត្រីជាម្តាយមានឈឺចាប់ពីជំងឺណាមួយដែលដឹង ដូចខាងក្រោមនេះដែរទេ ?<br>1. សំពាធឈាមខ្ពស់?<br>2. ជំងឺបេះដូង?<br>3. ទឹកនោមផ្អែម?<br>4. ឆ្កួតជ្រូក/ប្រកាច់<br>5. តើគាត់មានឈឺជំងឺដែលបានធ្វើរោគវិនិច្ឆ័យផ្សេងទៀតដែរឬទេ? | មាន មិនមាន មិនដឹង<br>សំពាធឈាមខ្ពស់ 1 2 8<br>ជំងឺបេះដូង 1 2 8<br>ទឹកនោមផ្អែម 1 2 8<br>ឆ្កួតជ្រូក/ប្រកាច់ 1 2 8<br>ផ្សេងទៀត 1 2 8<br>----------------------------<br>(បញ្ជាក់) | |

| | | | |
|---|---|---|---|
| 507 | ក្នុងរយៈពេលបីខែចុងក្រោយនៃផ្ទៃពោះ តើស្ត្រីជាម្តាយមានឈឺជំងឺណាមួយដូចខាងក្រោមនេះដែរទេ ?<br>1. ហូរឈាមតាមទ្វារ?<br>2. ទ្វារមាសហូរទឹកមានក្លិន?<br>3. មុខហើម?<br>4. ឈឺក្បាល?<br>5. ស្រវាំងភ្នែក?<br>6. ប្រកាច់?<br>7. ជំងឺដែលមានគ្រុន?<br>8. ឈឺពោះខ្លាំង ដែលមិនមែនឈឺពោះសំរាល?<br>9. ស្លេកស្លាំងនិងហត់ ( មានទាំងពីរ)<br>10.តើមានឈឺជំងឺផ្សេងទៀតដែរឬទេ? | មាន មិនមាន មិនដឹង<br>ហូរឈាមតាមទ្វារ 1 2 8<br>ទ្វារមាសហូរទឹកមានក្លិន 1 2 8<br>មុខហើម 1 2 8<br>ឈឺក្បាល 1 2 8<br>ស្រវាំងភ្នែក 1 2 8<br>ប្រកាច់ 1 2 8<br>ឈឺគ្រុន 1 2 8<br>ឈឺពោះខ្លាំង ដែលមិនមែនឈឺពោះសំរាល 1 2 8<br>ស្លេកស្លាំងនិងហត់ ( មានទាំងពីរ) 1 2 8<br>ផ្សេងទៀត 1 2 8<br>------------------------------<br>( បញ្ជាក់) | |
| 508 | តើទារកនេះកើតមកតែមួយ ឬភ្លោះ? | តែមួយ-------------------- 1<br>ភ្លោះ--------------------- 2<br>បីឬច្រើន ------------------- 3<br>មិនដឹង---------------------- 8 | → 601<br><br><br>→ 601 |
| 509 | លំដាប់កំណើតទារកដែលស្លាប់? | ទីមួយ-------------------- 1<br>ទីពីរ---------------------- 2<br>ទីបី ឬលើស----------------- 3<br>មិនដឹង-------------------- 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 6. ប្រវត្តិសំរាល** | | | |
| 601 | តើទារកនេះកើតនៅឯណា? | មន្ទីរពេទ្យ------------------ 1<br>កន្លែងសុខាភិបាលផ្សេងទៀត------ 2<br>ផ្ទះ ---- ------------------ 3<br>ផ្សេងទៀត ----------------- 6<br>(បញ្ជាក់)<br>មិនដឹង --------------------- 8 | |
| 602 | តើនរណាជាអ្នកបង្កើតទារក? | វេជ្ជបណ្ឌិត------------------ 1<br>គិលានុដ្ឋាក/ឆ្មប -------------- 2<br>ឆ្មបបុរាណ ------------------ 3<br>សាច់ញាតិ ----------------- 4<br>ដោយស្ត្រីខ្លួនឯង ------------- 5<br>ផ្សេងទៀត ----------------- 6<br>(បញ្ជាក់)<br>មិនដឹង --------------------- 8 | |
| 603 | បែកទឹកភ្លោះពេលណា? | មុនពេលសំរាល--------------- 1<br>ពេលសំរាល ------------- ---- 2<br>មិនដឹង ---------------- ----- 8 | |
| 604 | តើទារកកើតប៉ុន្មានម៉ោងក្រោយបែកទឹកភ្លោះ? | តិចជាង 24ម៉ោង ------------- 1<br>24 ម៉ោង ឬលើស--------- ---- 2<br>មិនដឹង ---------------- ----- 8 | |
| 605 | តើទឹកភ្លោះមានក្លិនស្អុយ? | បាទ --------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------- ----- 8 | |
| 606 | តើទារកឈប់កំរើកនៅក្នុងស្បូន? | បាទ --------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------- ----- 8 | <br>→ 608<br>→ 608 |
| 607 | តើនៅពេលណាដែលទារកឈប់កំរើកក្នុងស្បូន? | មុនពេលសំរាល--------------- 1<br>ពេលសំរាល ------------- ---- 2<br>មិនដឹង ---------------- ----- 8 | |
| 608 | តើឆ្មបមានស្តាប់សំលេងបេះដូងទារកដែរឬទេ ក្នុងអំឡុងពេលសំរាល? | បាទ --------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------- ----- 8 | <br>→ 610<br>→ 610 |
| 609 | តើមានសំលេងបេះដូងទារកដែរឬទេ? | បាទ --------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------- ----- 8 | |
| 610 | តើមានធ្លាក់ឈាមខ្លាំងដែរឬទេ នៅថ្ងៃដែលការសំរាល ចាប់ផ្តើម? | បាទ --------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------- ----- 8 | |

| | | | |
|---|---|---|---|
| 611 | តើស្ត្រីជាម្តាយមានគ្រុនក្តៅដែរឬទេ នៅថ្ងៃដែលការសំរាល ចាប់ផ្តើម? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង ---------------------- 8 | |
| 612 | តើការឈឺចាប់ពេលសំរាលមានរយៈពេលយូរប៉ុណ្ណា? | តិចជាង 12ម៉ោង ------------- 1<br>12-23 ម៉ោង ----------- ---- 2<br>24 ម៉ោងឬលើស ------------- 3<br>មិនដឹង ---------------- ---- 8 | |
| 613 | វាជាការ សំរាលតាមផ្លូវក្រោមធម្មតាឬ ? | បាទ ---------------------- 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------- ----- 8 | → 615<br><br>→ 615 |
| 614 | តើវាជាការសំរាលប្រភេទណា? | ដោយចាប់ដង្កៀប/បូម--------- 1<br>វះយកកូន - ----------- ---- 2<br>ផ្សេងទៀត---- ------------- 6<br>(បញ្ជាក់)<br>មិនដឹង ---------------- ---- 8 | |
| 615 | តើផ្នែកណានៃទារកចេញមកមុន? | ក្បាល -------------------- 1<br>គូទ ---- - ----------- ---- 2<br>ជើង ---- --- ------------- 3<br>ដៃ ------------------------ 4<br>ផ្សេងទៀត ----------------- 6<br>(បញ្ជាក់)<br>មិនដឹង ---------------- ---- 8 | |
| 616 | តើទងផ្ចិតចេញមកមុន ទារកកើតឬ? | បាទ ---------------------- 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------- ----- 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ |
|---|---|---|
| **ផ្នែក 7. លក្ខណ្ឌរបស់ទារកភ្លាមក្រោយពេលកើត** | | |
| 701 | នៅពេលកើត តើទំហំទារកដូចម្តេច? | តូចជាងធម្មតា--------------- 1<br>ធម្មតា -------------------- 2<br>ធំជាងធម្មតា ---------------- 3<br>មិនដឹង -------------------- 8 |
| 702 | តើកូនកើតមិនគ្រប់ខែឬ? | បាទ --------------------- 1<br>ទេ ---------------------- 2<br>មិនដឹង --------------------- 8 |
| 703 | តើផ្ទៃពោះមានរយៈពេលប៉ុន្មានខែ ប៉ុន្មានសប្តាហ៍? ចូរបញ្ជាក់រយៈពេលមានផ្ទៃពោះ | ខែ ----- ----------- □□<br>សប្តាហ៍ -------------- □□<br>មិនដឹង -------------- 9 9 8 |
| 704 | តើទំងន់ពេលកើតរបស់កូន ប៉ុន្មាន? | គីឡូក្រាម- ----------- □□<br>មិនដឹង -------------- 9 8 |
| 705 | តើមានលាបអ្វីនៅលើគល់ទងផ្ចិតដែលកាត់ដែរឬទេ ក្រោយពេលកើត? | បាទ --------------------- 1<br>ទេ ---------------------- 2<br>មិនដឹង --------------------- 8 |
| 706 | តើវាជាអ្វី? | ----------------------------------------------------<br>(បញ្ជាក់) |
| 707 | តើមានសញ្ញានៃការរបួស ឬបាក់ឆ្អឹងដែរឬទេ? | បាទ --------------------- 1<br>ទេ ---------------------- 2<br>មិនដឹង --------------------- 8 |
| 708 | តើស្នាមរបួសនៅកន្លែងណា? | ----------------------------------------------------<br>(បញ្ជាក់) |
| 709 | តើមានសញ្ញានៃការខ្វិនដែរឬទេ? | បាទ --------------------- 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------- ----- 8 |
| 710 | តើទារកមានរូបរាងមិនប្រក្រតីណាមួយដែរឬទេ? | បាទ --------------------- 1<br>ទេ ---------------------- 2<br>មិនដឹង --------------------- 8 |
| 711 | តើរូបរាងមិនប្រក្រតីប្រភេទណាដែលទារកមាន? | ប៉ោង/ខូច នៅខ្នង------------ 1<br>ក្បាលធំក្រៃ- ----------- ---- 2<br>ក្បាលតូចក្រៃ-- ------------- 3<br>ខូចបបូរមាត់/ឬឆែប------------ 4<br>ផ្សេងទៀត ----------------- 6<br>(បញ្ជាក់)<br>មិនដឹង ---------------- ---- 8 |

| | | | |
|---|---|---|---|
| 712 | តើទារកមានពណ៌អ្វីនៅពេលកើត? | ធម្មតា -------------------- 1<br>ស្លេក --------------------- 2<br>ខៀវ --------------------- 3<br>មិនដឹង -------------------- 8 | |
| 713 | តើទារកដកដង្ហើម ក្រោយពេលកើត បើទោះជាតិច ក៏ដោយ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 714 | តើគេមានជួយទារកអោយដកដង្ហើមដែរឬទេ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 715 | តើទារកមានយំដែរឬទេ បើទោះជាតិចតួច ក៏ដោយ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 716 | តើទារកមានកំរើកដែរឬទេ បើទោះជាតិចតួច ក៏ដោយ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 717 | ឆែកមើល 713 715 និង716 សំរាប់កូដ ់ទេ់<br>កូដទាំងបី ់ទេ់<br>ទារកមិនដកដង្ហើម □ ↓<br>ទាកមិនយំ<br>ទារកមិនកំរើក | ផ្សេងទៀត □ | →801 |
| 718 | ប្រសិនបើទារកមិនដកដង្ហើម មិនយំ មិនកំរើក តើ វាស្លាប់កើតឬ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | <br>→ 801<br>→ 801 |
| 719 | តើទារកត្រាំនៅក្នុងទឹកភ្លោះ គឺថា បង្ហាញពីសញ្ញារលួយឬ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | → 1001<br>→ 1001<br>→ 1001 |

## ផ្នែក ៨. ប្រវត្តិរបួស/គ្រោះថ្នាក់

| | | | |
|---|---|---|---|
| 801 | តើទារកមានឈឺចាប់ពីរបួសឬគ្រោះថ្នាក់ណាមួយ ដែលនាំឈានទៅរកការស្លាប់របស់គាត់ដែរឬទេ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | <br>→ 804<br>→ 804 |
| 802 | តើទារកទទួលការឈឺចាប់ពីរបួស/គ្រោះថ្នាក់អ្វី? | គ្រោះថ្នាក់ចរាចរ ------------- 01<br>ធ្លាក់ --------------------- 02<br>លង់ទឹក -- ----------------- 03<br>ពុល --------------------- 04<br>រលាក -------------------- 05<br>អំពើហឹង្សា/ការបំពាន----------<br>06<br>ផ្សេងទៀត ----------------- 96<br>(បញ្ជាក់)<br>មិនដឹង ---------------------98 | |
| 803 | តើរបួសឬគ្រោះថ្នាក់បង្កឡើងដោយចេតនាពីអ្នក ដ៏ទៃឬ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |

| | | | |
|---|---|---|---|
| 804 | តើទារកឈឺចាប់រហូតស្លាប់ បង្កឡើងដោយសត្វ/សត្វល្អិតខាំ ទិចដែរឬទេ? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង ---------------------- 8 | <br>→ 901<br>→ 901 |
| 805 | តើជាប្រភេទសត្វ/សត្វល្អិតអ្វី? | ឆ្កែ --- -------------------- 1<br>ពស់ - ----- -------------- 2<br>សត្វល្អិត ------------------- 3<br>ផ្សេងទៀត ------------------ 6<br>(បញ្ជាក់)<br>មិនដឹង --------------------- 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក ៩. ប្រវត្តិជំងឺជុំវិញកំណើត** | | | |
| 901 | តើទារកដែលគេអោយជញ្ជក់ ឬ បៅដបដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | <br>→ 905<br>→ 905 |
| 902 | តើឆាប់ប៉ុណ្ណាក្រោយពេលកើតដែល ទារកជញ្ជក់ ឬ បៅដប? | ម៉ោង -- ----- ----------1 ☐☐<br>ថ្ងៃ --------------------2 ☐☐<br>មិនដឹង -------------- ----9 9 8 | |
| 903 | តើទារកមានឈប់ជញ្ជក់ ឬ បៅដបដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | <br>→ 905<br>→ 905 |
| 904 | តើប៉ុន្មានថ្ងៃក្រោយពេលកើតដែល ទារកឈប់ជញ្ជក់ ឬ បៅដប? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ----9 9 8 | |
| 905 | តើទារកបៅតែដោះម្តាយសុទ្ធដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | |
| 906 | តើទារកមានប្រកាច់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | <br>→ 908<br>→ 908 |
| 907 | តើឆាប់ប៉ុណ្ណាក្រោយពេលកើត ដែលទារកមាន ប្រកាច់? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ----9 9 8 | |
| 908 | តើទារកមានរឹងនិងទាញខ្នងទៅក្រោយដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | |
| 909 | តើទារកមានប៉ោងបង្ហើយដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | <br>→ 911<br>→ 911 |
| 910 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកមានប៉ោង បង្ហើយ? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 911 | តើទារកលែងមានកាយវិការឆ្លើយតប ឬបាត់ស្មារតី ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------- 8 | <br>→ 913<br>→ 913 |

| | | | |
|---|---|---|---|
| 912 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកលែងមានការឆ្លើយតប ឬបាត់ស្មារតី? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |

| | | | |
|---|---|---|---|
| 913 | តើទារកមានគ្រុនក្ដៅដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | <br>→ 915<br>→ 915 |
| 914 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកមានគ្រុនក្ដៅ? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 915 | តើទារកក្លាយទៅជាត្រជាក់នៅពេលស្ទាបដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | <br>→ 917<br>→ 917 |
| 916 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកក្លាយជាត្រជាក់ពេលស្ទាប? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 917 | តើទារកមានក្អកដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | <br>→ 919<br>→ 919 |
| 918 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកចាប់ផ្ដើមក្អក? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 919 | តើទារកមានដកដង្ហើមញាប់ដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | <br>→ 921<br>→ 921 |
| 920 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកចាប់ផ្ដើមដកដង្ហើមញាប់? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 92 1 | តើទារកមានការលំបាកដកដង្ហើមដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | <br>→ 926<br>→ 926 |
| 922 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកចាប់ផ្ដើមលំបាកដកដង្ហើម? | ថ្ងៃ ---------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 92 3 | តើទារកមានផិតផតដើមទ្រូងដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ----<br>2<br>មិនដឹង -----------------------<br>8 | |
| 92 4 | តើទារកមានបញ្ចេញសំលេងខឹតខតដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ---- | |

| | | | |
|---|---|---|---|
| | **ចូរធ្វើបង្ហាញ** | 2<br>មិនដឹង ----------------------<br>8 | |
| 92 5 | តើទារកមានប៉ឹតប៉ោងរន្ធច្រមុះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | |
| 926 | តើទារកមានរាគដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 930<br>→ 930 |

| | | | |
|---|---|---|---|
| 927 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារកមានរាគ? | ថ្ងៃ --------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 928 | នៅពេលដែលជំងឺរាគធ្ងន់បំផុត តើទារកជុះប៉ុន្មានដង ក្នុងមួយថ្ងៃ? | ចំនួនដង------------------ ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 929 | តើមានឈាមក្នុងលាមកឬ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | |
| 930 | តើទារកមានក្អួតដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 933<br>→ 933 |
| 931 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលក្អួតចាប់ផ្តើម? | ថ្ងៃ --------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 932 | នៅពេលដែលក្អួតធ្ងន់បំផុត តើទារកក្អួតប៉ុន្មានដង ក្នុងមួយថ្ងៃ? | ចំនួនដង------------------ ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 933 | តើទារកមានហើមពោះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 935<br>→ 935 |
| 934 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលទារក ចាប់ផ្តើម មានហើមពោះ? | ថ្ងៃ --------------------- ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 935 | តើទារកមានពណ៌ក្រហមនៅគល់ទងផ្ចិត ឬមានអ្វីហូរ ចេញពីគល់ទងផ្ចិតដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | |
| 936 | តើទារកមានពងក្រហមៗនៅលើស្បែកដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | |

| | | | |
|---|---|---|---|
| 937 | តើទារកមានពណ៌លឿងនៅបាតដៃ ឬបាតជើងដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 | <br>→ 1001<br>→ 1001 |
| 938 | តើប៉ុន្មានថ្ងៃក្រោយពេលកើត ដែលលឿងនៅបាតដៃ ឬបាតជើង ចាប់ផ្ដើម? | ថ្ងៃ ---------------------<br>☐☐<br>មិនដឹង -------------- ---- 9 8 | |
| 939 | តើទារកមានលឿងនៅបាតដៃ ឬបាតជើង រយៈពេលប៉ុន្មានថ្ងៃ? | ថ្ងៃ ---------------------<br>☐☐<br>មិនដឹង -------------- ---- 9 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 10. សុខភាពរបស់មាតា និងកត្តាកំណត់ (Contextual factors)** | | | |
| 1001 | តើម្តាយអាយុប៉ុន្មាន នៅពេលដែលទារកស្លាប់? | ឆ្នាំ --------------------- □□<br>មិនដឹង -------------- ---- 9 8 | |
| 1002 | តើម្តាយមានបានទទួលការថែទាំមុនពេលសំរាលដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 | |
| 1003 | តើម្តាយមានបានទទួលការចាក់ថ្នាំបង្ការជំងឺតេតាណុសដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 | → 1005<br>→ 1005 |
| 1004 | តើចំនួនប៉ុន្មានដូស? | ចំនួនដូស----------------- □□<br>មិនដឹង -------------- ---- 9 8 | |
| 1005 | តើសុខភាពម្តាយ ដូចម្តេចដែរឥឡូវនេះ? | មានសុខភាពល្អ --------------- 1<br>ឈឺ------------------ ---- 2<br>មិននៅរស់ ------------------- 3<br>មិនដឹង ---------------------- 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ |
|---|---|---|
| **ផ្នែក 11. ការព្យាបាល និង សេវាសុខភាពដែលប្រើសំរាប់ការឈឺចុងក្រោយ** | | |
| 1101 | តើទារកមានបានទទួលការព្យាបាលអ្វី នៅពេលឈឺ ដែលឈានទៅស្លាប់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 |
| 1102 | តើអ្នកអាចរាយបញ្ជីពីការព្យាបាលដែលទារកបាន ទទួល នៅពេលឈឺ<br>ដែលឈានទៅស្លាប់ដែរឬទេ?<br>ចំលងពីវេជ្ជបញ្ជា/កំណត់ត្រាចេញពីពេទ្យ ប្រសិនបើមាន | ------------------------------------------------------ |
| 1103 | សូមអ្នកមេត្តាប្រាប់ខ្ញុំ<br>តើនៅកន្លែងណានៃកន្លែងទាំង<br>នេះដែលទារកបានទទួលការព្យាបាល<br>នៅពេលឈឺ ដែលឈានទៅស្លាប់នោះ ? | មាន មិនមាន មិនដឹង<br>នៅផ្ទះ ---------- 1 2 8<br>គ្រូបូរាណ -------- 1 2 8<br>គ្លីនិករដ្ឋ --------- 1 2 8<br>មន្ទីរពេទ្យរដ្ឋ ------ 1 2 8<br>គ្លីនិកឯកជន ------- 1 2 8<br>មន្ទីរពេទ្យឯកជន ----1 2 8<br>ឱសថស្ថាន អ្នកលក់ថ្នាំ<br>ហាង ----------- 1 2 8<br>ផ្សេងទៀត -------- 1 2 8<br>-----------------------------<br>(បញ្ជាក់) |
| 1104 | នៅក្នុងខែមុននឹងស្លាប់តើទារកបានជួបពិគ្រោះ ប៉ុន្មានដងជាមួយសេវាសុខភាពផ្លូវការ ? | ចំនួនជួបពិគ្រោះ ------------ ☐☐<br>មិនដឹង -------------- ---- 9 8 |
| 1105 | តើមន្ត្រីសុខាភិបាលមានបានប្រាប់អ្នកពីមូលហេតុ ស្លាប់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 |
| 1106 | តើមន្ត្រីសុខាភិបាលនិយាយថាម៉េច ? | ------------------------------------------------------ |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
| --- | --- | --- | --- |
| **ផ្នែក 12. ទិន្នន័យទាញចេញពីសំបុត្រមរណៈភាព** | | | |
| 1201 | តើអ្នកមានសំបុត្រមរណៈភាពរបស់ទារកដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 | <br>→ 1301<br>→ 1301 |
| 1202 | អាចអោយខ្ញុំសុំមើលសំបុត្រមរណៈភាពបានដែរឬទេ?<br>ចូរកត់ត្រាថ្ងៃខែឆ្នាំស្លាប់ ពីសំបុត្រមរណៈភាព | ថ្ងៃ ខែ ឆ្នាំ<br>□□ □□ □□□□ | |
| 1203 | ចូរកត់ត្រាថ្ងៃខែឆ្នាំដែលចេញសំបុត្រមរណៈភាព | ថ្ងៃ ខែ ឆ្នាំ<br>□□ □□ □□□□ | |
| 1204 | ចូរកត់ត្រាមូលហេតុស្លាប់ពីជួរទី 1 ( ខាងលើបំផុត) នៃសំបុត្រមរណៈភាព :<br>---------------------------------------------------------------------- | | |
| 820 | តើប៉ុន្មានថ្ងៃមុនស្លាប់ ដែលគាត់មានរលូត? | ថ្ងៃ ----------------- □□<br>មិនដឹង --------------- 9 8 | |
| 821 | តើគាត់មានផ្ទៃពោះប៉ុន្មានខែនាពេលដែលគាត់រលូត? | ខែ ----------------- □□<br>មិនដឹង -------------- 9 8 | |
| 822 | តើគាត់មានធ្លាក់ឈាមខ្លាំងដែរឬទេ ក្រោយពេលរលូត? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 823 | តើការរលូតកើតមានឡើងដោយខ្លួនវា ឯង។? | បាទ ---------------------- 1<br>ទេ ----------------------- 2<br>មិនដឹង ---------------- ----- 8 | → 901<br><br>→ 901 |
| 824 | តើគាត់មានលេបថ្នាំ ឬ ព្យាបាល ដើម្បីរំលូត ដែរឬទេ? | បាទ ---------------------- 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------- ----- 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក ៩. បណ្តុំរោគសញ្ញា និង រោគសញ្ញា ដែលសំគាល់ឃើញក្នុងអំឡុងពេលឈឺចុងក្រោយ** | | | |
| 901 | តើគាត់ឈឺយូរប៉ុណ្ណាមុននឹងស្លាប់? | ថ្ងៃ --------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ----9 9 8 | |
| 902 | តើគាត់មានគ្រុនក្តៅដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | <br>→ 907<br>→ 907 |
| 903 | រយៈពេលប៉ុន្មានដែលគាត់មានគ្រុនក្តៅ? | ថ្ងៃ --------------------1 □□<br>ខែ --------------------2<br>□□<br>មិនដឹង -------------- ----9 9 8 | |
| 904 | តើគ្រុនក្តៅជាប់ ឬក្តៅត្រជាក់ៗ? | ក្តៅជាប់ -------------------- 1<br>ក្តៅត្រជាក់ៗ ------------ ---- 2<br>មិនដឹង ----------------------<br>8 | |
| 905 | តើគាត់ក្តៅតែពេលយប់ទេឬ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | |
| 906 | តើគាត់មានរងាររញ្ជាក់ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | |
| 907 | តើគាត់មានក្អកដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | <br>→ 913<br>→ 913 |
| 908 | រយៈពេលប៉ុន្មានដែលគាត់មានក្អក? | ថ្ងៃ --------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ----9 9 8 | |
| 909 | តើក្អកធ្ងន់ធ្ងរដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | |
| 910 | តើក្អកមានស្លេស្មដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | |

| | | | |
|---|---|---|---|
| 911 | តើគាត់មានក្អកឈាមដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------<br>8 | |
| 912 | តើគាត់មានបែកញើសពេលយប់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ----------------------<br>8 | |

| | | | |
|---|---|---|---|
| 913 | តើគាត់មានហត់ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | <br>→ 918<br>→ 918 |
| 914 | រយៈពេលប៉ុន្មានដែលគាត់មានហត់? | ថ្ងៃ --------------------1 ☐☐<br>ខែ ------------------- 2 ☐☐<br>មិនដឹង -------------- ----9 9 8 | |
| 915 | តើគាត់មិនអាចធ្វើការងាររាល់ថ្ងៃបាន ដោយសារតែហត់ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | |
| 916 | តើគាត់ ហត់នៅពេលដេករាប ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 917 | តើគាត់មានសំលេងខឺតខតពេលដកដង្ហើម ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 918 | តើគាត់មានឈឺទ្រូង ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | <br>→ 928<br>→ 928 |
| 919 | រយៈពេលប៉ុន្មានដែលគាត់មានឈឺទ្រូង? | ថ្ងៃ --------------------1 ☐☐<br>ខែ ------------------- 2 ☐☐<br>មិនដឹង -------------- ----9 9 8 | |
| 920 | តើការឈឺទ្រូងចាប់ផ្តើមឡើងភ្លាមៗ ឬបន្តិចម្តងៗ? | ភ្លាមៗ --------------------- 1<br>បន្តិចម្តងៗ ------------- ---- 2<br>មិនដឹង --------------------- 8 | |
| 921 | នៅពេលគាត់មានការឈឺចាប់ដើមទ្រូងខ្លាំង តើវាមានរយៈពេលប៉ុន្មាន? | តិចជាងកន្លះម៉ោង ------------- 1<br>កន្លះម៉ោងទៅ 24ម៉ោង ---------<br>2<br>លើសពី 24ម៉ោង ------------- 3<br>មិនដឹង ----------------------<br>8 | |
| 922 | តើការឈឺចាប់ដើមទ្រូងស្ថិតនៅក្រោមឆ្អឹងសន្ទះទ្រូងឬ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ----------------------<br>8 | |
| 923 | តើការឈឺចាប់ដើមទ្រូងស្ថិតនៅលើបេះដូង ហើយចាក់ទៅដៃខាងឆ្វេងឬ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 924 | តើការឈឺចាប់ដើមទ្រូងស្ថិតនៅលើឆ្អឹងជំនីឬ? (ខាង) | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 925 | តើការឈឺចាប់ដើមទ្រូង ឈឺជាប់ ឬឈឺបាត់ៗ? | ឈឺជាប់ -------------------- 1 | |

| | | | |
|---|---|---|---|
| | | ឈើ បាត់ៗ ------------------ ---- 2<br>មិនដឹង ---------------------- 8 | |

| | | | |
|---|---|---|---|
| 926 | តើការឈឺចាប់ដើមទ្រូង កាន់តែខ្លាំងពេលក្អកឬ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 927 | តើគាត់មានញ័រដើមទ្រូង ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 928 | តើគាត់មានរាគដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | <br>→ 933<br>→ 933 |
| 929 | រយៈពេលប៉ុន្មានដែលគាត់មានរាគ? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2 ☐☐<br>មិនដឹង ------------------ 9 9 8 | |
| 930 | តើការរាគជាប់ ឬរាគបាត់ៗ? | រាគជាប់ -------------------- 1<br>រាគបាត់ៗ ---------- ---- ---- 2<br>មិនដឹង --------------------- 8 | |
| 931 | នៅពេលណាក៏ដោយក្នុងអំឡុង ពេលឈឺចុងក្រោយ តើមានឈាមក្នុងលាមកឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 932 | នៅពេលដែលជំងឺរាគធ្ងន់បំផុត តើគាត់ជុះប៉ុន្មានដង ក្នុងមួយថ្ងៃ? | ចំនួនដង------------------ ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 933 | តើគាត់មានក្អួតដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | <br>→ 937<br>→ 937 |
| 934 | រយៈពេលប៉ុន្មានដែលគាត់មានក្អួត? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2 ☐☐<br>មិនដឹង -------------- ---- 9 9 8 | |
| 935 | តើកំអួតមានពណ៌ដូចកាហ្វេខាប់ៗ ឬ ក្រហមថ្លា/ ឈាមក្រហម ឬដូចអ្វីផ្សេងទៀត? | កាហ្វេខាប់ៗ ----------------- 1<br>ក្រហមថ្លា/ ឈាមក្រហម --- ---- 2<br>ផ្សេងទៀត ------------------ 6<br>----------------------------<br>(បញ្ជាក់)<br>មិនដឹង ---------------------- 8 | |
| 936 | នៅពេលដែលក្អួតធ្ងន់បំផុត តើគាត់ក្អួតប៉ុន្មានដង ក្នុងមួយថ្ងៃ? | ចំនួនដង------------------ ☐☐<br>មិនដឹង -------------- ---- 9 8 | |
| 937 | **ផែកមើល សំណួរ 302 សំរាប់ភេទរបស់អ្នកស្លាប់**<br>**ស្រី** ☐ ↓ | **ប្រុស** ☐ ——— | → 939 |

| | | | |
|---|---|---|---|
| 938 | **ផែកមើល សំណួរ 801 805 819 ដើម្បីមើលថាតើគាត់ស្លាប់ ក្នុងអំឡុងពេលមានផ្ទៃពោះ សំរាល រលូត ឬក្រោយសំរាល**<br>**ទេ** □↓ **មែន** □ ——→948 | | |
| 939 | តើគាត់មានចុកពោះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 941<br>→ 941 |
| 940 | រយៈពេលប៉ុន្មានដែលគាត់មានចុកពោះ? | ថ្ងៃ --------------------1 □□<br>ខែ --------------------2 □□<br>មិនដឹង -------------- ---- 9 9 8 | |
| 94 1 | តើគាត់មានហើមតឹងពោះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 945<br>→ 945 |
| 942 | រយៈពេលប៉ុន្មានដែលគាត់ហើមតឹងពោះ? | ថ្ងៃ --------------------1 □□<br>ខែ --------------------2 □□<br>មិនដឹង -------------- ---- 9 9 8 | |
| 943 | តើការហើមតឹងពោះកើតមានឡើងលឿនក្នុងរយៈប៉ុន្មានថ្ងៃឬ បន្តិចម្តងៗរាប់ខែ? | លឿនក្នុងរយៈប៉ុន្មានថ្ងៃ---------- 1<br>បន្តិចម្តងៗរាប់ខែ---------- ---- 2<br>មិនដឹង ---------------------- 8 | |
| 944 | តើមានរយៈពេលណាមួយថ្ងៃ ឬលើសពីនេះ ដែលក្នុងអំឡុងនេះគាត់មិនជុះ ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | |
| 945 | តើគាត់មានដុំអ្វីនៅក្នុងពោះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 948<br>→ 948 |
| 946 | រយៈពេលប៉ុន្មានដែលគាត់មានដុំនៅក្នុងពោះ? | ថ្ងៃ --------------------1 □□<br>ខែ --------------------2 □□<br>មិនដឹង -------------- ---- 9 9 | |

| | | | |
|---|---|---|---|
| | | 8 | |
| 947 | តើដុំនោះស្ថិតនៅកន្លែងណា ក្នុងពោះ? | ផ្នែកលើខាងស្តាំនៃពោះ --------- 1<br>ផ្នែកលើខាងឆ្វេងនៃពោះ --- ---- 2<br>ផ្នែកខាងក្រោមនៃពោះ --------- 3<br>ផ្នែកខាងលើទាំងអស់នៃពោះ ----- 4<br>មិនដឹង ---------------------- 8 | |
| 948 | តើគាត់មានការលំបាក ឬការឈឺចាប់ដែរឬទេ នៅពេលលេបរបស់រឹង? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង ---------------------- 8 | <br>→ 950<br>→ 950 |

| | | | |
|---|---|---|---|
| 949 | រយៈពេលប៉ុន្មានដែលគាត់មាន ការលំបាក ឬការឈឺចាប់ នៅពេលលេបរបស់រឹង? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2<br>☐☐<br>មិនដឹង -------------- ---- 9 9<br>8 | |
| 950 | តើគាត់មានការលំបាក ឬការឈឺចាប់ដែរឬទេ នៅពេលលេបរបស់រាវ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 952<br>→ 952 |
| 951 | រយៈពេលប៉ុន្មានដែលគាត់មាន ការលំបាក ឬការឈឺចាប់ នៅពេលលេបរបស់រាវ? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2<br>☐☐<br>មិនដឹង -------------- ---- 9 9<br>8 | |
| 952 | តើគាត់មានឈឺក្បាលដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | → 955<br>→ 955 |
| 953 | រយៈពេលប៉ុន្មានដែលគាត់មានឈឺក្បាល? | ថ្ងៃ --------------------1 ☐☐<br>ខែ ------------------- 2 ☐☐<br>មិនដឹង -------------- ---- 9 9<br>8 | |
| 954 | តើឈឺក្បាលនេះធ្ងន់ធ្ងរ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង -------------------- 8 | |
| 955 | តើគាត់មានរឹងក ឬឈឺចាប់នៅកដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 957<br>→ 957 |
| 956 | រយៈពេលប៉ុន្មានដែលគាត់មានរឹងក ឬឈឺចាប់នៅក? | ថ្ងៃ -------------------- ☐☐<br>មិនដឹង ------------------ 9 8 | |
| 957 | តើគាត់មានវង្វេងស្មារតីដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | → 960<br>→ 960 |
| 958 | រយៈពេលប៉ុន្មានដែលគាត់វង្វេងស្មារតី? | ថ្ងៃ --------------------1 ☐☐ | |

| | | | |
|---|---|---|---|
| | | ខែ --------------------2<br>□□<br>មិនដឹង ------------------ 9 9 8 | |
| 959 | តើការវង្វេងស្មារតីចាប់ផ្តើមឡើងភ្លាម លឿនក្នុងរយៈមួយថ្ងៃ ឬយឺតៗ ច្រើនថ្ងៃ? | ភ្លាមៗ --------------------- 1<br>លឿន (ក្នុង1ថ្ងៃ) --------- ----<br>2<br>យឺតៗ (ជាច្រើនថ្ងៃ) ----------- 3<br>មិនដឹង --------------------- 8 | |
| 960 | តើគាត់មានបាត់ស្មារតីដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ----<br>2<br>មិនដឹង --------------------- 8 | → 963<br>→ 963 |

| | | | |
|---|---|---|---|
| 961 | រយៈពេលប៉ុន្មានដែលគាត់បាត់បង់ស្មារតី? | ថ្ងៃ --------------------1 □□<br>ខែ ------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 962 | តើការបាត់បង់ស្មារតីចាប់ផ្តើមឡើងភ្លាម លឿនក្នុង រយៈមួយថ្ងៃ ឬយឺតៗ ច្រើនថ្ងៃ? | ភ្លាមៗ --------------------- 1<br>ក្នុង1ថ្ងៃ (លឿន) -------- ---- - 2<br>យឺតៗ (ជាច្រើនថ្ងៃ) ----------- 3<br>មិនដឹង ----------------------<br>8 | |
| 963 | តើគាត់មានប្រកាច់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង --------------------- 8 | → 965<br>→ 965 |
| 964 | រយៈពេលប៉ុន្មានដែលគាត់ប្រកាច់? | ថ្ងៃ --------------------1 □□<br>ខែ ------------------- 2 □□<br>មិនដឹង ------------------ 9 9 8 | |
| 965 | តើគាត់មិនអាចបើកមាត់បានឬ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | → 967<br>→ 967 |
| 966 | រយៈពេលប៉ុន្មានដែលគាត់មិនអាចបើកមាត់បាន? | ថ្ងៃ -------------------- □□<br>មិនដឹង ------------------ 9 8 | |
| 967 | តើគាត់មានការរឹងខ្លួនប្រាណទាំងមូលឬ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | → 969<br>→ 969 |
| 968 | រយៈពេលប៉ុន្មានដែលគាត់ មានការរឹងខ្លួនប្រាណទាំងមូល? | ថ្ងៃ -------------------- □□<br>មិនដឹង -------------- ---- 9 8 | |
| 969 | តើគាត់មានខ្ទិនមួយចំហៀងខ្លួនដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង --------------------- 8 | → 972<br>→ 972 |
| 970 | រយៈពេលប៉ុន្មានដែលគាត់ ខ្ទិនមួយចំហៀងខ្លួន? | ថ្ងៃ --------------------1 □□<br>ខែ ------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 971 | តើការខ្ទិនមួយចំហៀងខ្លួនចាប់ផ្តើមឡើងភ្លាម លឿនក្នុង រយៈមួយថ្ងៃ ឬយឺតៗ ច្រើនថ្ងៃ? | ភ្លាមៗ --------------------- 1<br>ក្នុង1ថ្ងៃ (លឿន) -------- ---- - 2<br>យឺតៗ (ជាច្រើនថ្ងៃ) ----------- 3 | |

| | | | |
|---|---|---|---|
| | | មិនដឹង --------------------- 8 | |
| 972 | តើគាត់មានខ្ញិនមួយកំណាត់ក្រោមដៃរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ----------------------- 2<br>មិនដឹង --------------------- 8 | <br>→ 975<br>→ 975 |

| | | | |
|---|---|---|---|
| 973 | រយៈពេលប៉ុន្មានដែលគាត់ ខ្ទិនមួយកំណាត់ក្រោម? | ថ្ងៃ ---------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 974 | តើការខ្ទិនមួយកំណាត់ក្រោមចាប់ផ្ដើមឡើងភ្លាម លឿនក្នុង រយៈមួយថ្ងៃ ឬយឺតៗ ច្រើនថ្ងៃ? | ភ្លាមៗ --------------------- 1<br>ក្នុង1ថ្ងៃ (លឿន) -------- ---- - 2<br>យឺតៗ (ជាច្រើនថ្ងៃ) ----------- 3<br>មិនដឹង ----------------------<br>8 | |
| 975 | តើទឹកនោមមានប្តូរពណ៌ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 977<br>→ 977 |
| 976 | រយៈពេលប៉ុន្មានដែលគាត់មានទឹកនោម ប្តូរពណ៌? | ថ្ងៃ ---------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 977 | ក្នុងរយៈពេលនៃការឈឺ តើគាត់មានដែលបញ្ចេញ ឈាមក្នុងទឹកនោម ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 979<br>→ 979 |
| 978 | រយៈពេលប៉ុន្មានដែលគាត់មានឈាមក្នុងទឹកនោម ? | ថ្ងៃ ---------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 979 | តើមានការផ្លាស់ប្តូរបរិមាណទឹកនោម ដែលគាត់នោម រាល់ថ្ងៃដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | → 982<br>→ 982 |
| 980 | រយៈពេលប៉ុន្មានដែលគាត់មាន ការផ្លាស់ប្តូរបរិមាណ ទឹកនោម ដែលគាត់នោម រាល់ថ្ងៃ? | ថ្ងៃ ---------------------1 □□<br>ខែ -------------------- 2 □□<br>មិនដឹង -------------- ---- 9 9<br>8 | |
| 981 | តើគាត់នោមច្រើនជ្រុល តិចជ្រុល ឬក៏មិនមានទឹក | ច្រើនជ្រុល------------------- 1<br>តិចជ្រុល ----- --------- ---- | |

| | | | |
|---|---|---|---|
| | នោមសោះ? | 2<br>មិនមានទឹកនោមសោះ ---------- 3<br>មិនដឹង ----------------------<br>8 | |
| 982 | ក្នុងអំឡុងពេលឃើដែលឈានទៅស្លាប់ តើគាត់ មានចេញកន្ទួលក្រហមនៅលើស្បែកដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------ ----<br>2<br>មិនដឹង --------------------- 8 | <br>→ 986<br>→ 986 |

| | | | |
|---|---|---|---|
| 983 | រយៈពេលប៉ុន្មានដែលមានកន្ទួលក្រហមនៅលើស្បែក? | ថ្ងៃ ---------------------<br>☐☐<br>មិនដឹង ------------------ 9 8 | |
| 984 | តើកន្ទួលក្រហមនោះមាននៅលើ:<br>1. មុខ?<br>2.ដងខ្លួន?<br>3. ដៃ និង ជើង?<br>4. កន្លែងណាផ្សេងទៀត | មាន មិនមាន<br>មិនដឹង<br>មុខ --------- 1 2 8<br>ដងខ្លួន ---------- 1 2 8<br>ដៃនិងជើង ------- 1 2 8<br>កន្លែងផ្សេងទៀត --- 1 2 8<br>បញ្ជាក់ ------------------------ | |
| 985 | តើកន្ទួលក្រហមនោះមើលទៅដូចម្ដេច? | កន្ទួលកញ្ច្រិល------------------ 1<br>កន្ទួលមានទឹកថ្លា --------- ---- 2<br>កន្ទួលមានខ្ទុះ ------ ---------- 3<br>មិនដឹង ---------------------- 8 | |
| 986 | តើគាត់មានភ្នែកក្រហមដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 987 | តើគាត់មានហូរឈាមតាមច្រមុះ មាត់ ឬរន្ធគូទដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 988 | តើគាត់ដែលមានជំងឺវាត់ (shingles)/ពងបែក (herpes) zoster ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | |
| 989 | តើគាត់មានស្រកទំងន់ដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- 2<br>មិនដឹង --------------------- 8 | → 990<br>→ 990 |
| 989.1 | រយៈពេលប៉ុន្មានដែលគាត់មាន ស្រកទំងន់? | ថ្ងៃ --------------------1 ☐☐<br>ខែ ------------------- 2<br>☐☐<br>មិនដឹង -------------- ---- 9 9<br>8 | |
| 989.2 | តើគាត់មើលទៅស្គមខ្លាំង និង តូច? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ---- | |

| | | | |
|---|---|---|---|
| | | 2<br>មិនដឹង --------------------- 8 | |
| 990 | តើគាត់មានឈឺមាត់ឬបន្ទះសនៅក្នុងមាត់ ឬនៅលើអណ្តាតដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង --------------------- 8 | → 991<br>→ 991 |
| 990.1 | រយៈពេលប៉ុន្មានដែលមានឈឺមាត់ឬបន្ទះសនៅក្នុងមាត់ ឬនៅលើ អណ្តាត? | ថ្ងៃ ---------------------<br>□□<br>មិនដឹង -------------- ---- 9 8 | |
| 991 | តើគាត់មាន ហើមណាមួយដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង --------------------- 8 | → 992<br>→ 992 |

| | | |
|---|---|---|
| 991.1 | រយៈពេលប៉ុន្មានដែលមានហើម? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2 ☐☐<br>មិនដឹង -------------- --- 9 9 8 |
| 991.2 | តើហើមនោះមាននៅលើ:<br>1. មុខ?<br>2. សន្លាក់?<br>3. កជើង?<br>4. ពេញទាំងខ្លួន?<br>5. កន្លែងណាផ្សេងទៀត? | មាន មិនមាន<br>មិនដឹង<br>មុខ ------------ 1 2 8<br>សន្លាក់ ---------- 1 2 8<br>កជើង ---------- 1 2 8<br>ពេញទាំងខ្លួន ------ 1 2 8<br>កន្លែងផ្សេងទៀត -- 1↵ 2 8<br>បញ្ជាក់ ---------------------- |
| 992 | តើគាត់មាន ហើមកួនកណ្ដុរដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2 → 993<br>មិនដឹង ---------------------- → 993<br>8 |
| 992.1 | រយៈពេលប៉ុន្មានដែលមានហើមកូនកណ្ដុរ? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2 ☐☐<br>មិនដឹង -------------- --- 9 9 8 |
| 992.2 | ហើមកូនកណ្ដុរនោះមាននៅលើ:<br>1. ក?<br>2. ឃ្លៀក?<br>3. ក្រលៀន?<br>4. កន្លែងណាផ្សេងទៀត? | មាន មិនមាន<br>មិនដឹង<br>ក ------------ 1 2 8<br>ឃ្លៀក ---------- 1 2 8<br>ក្រលៀន -------- 1 2 8<br>កន្លែងផ្សេងទៀត -- 1↵ 2 8<br>បញ្ជាក់ ---------------------- |
| 993 | តើគាត់មានភ្នែកប្រែពណ៌លឿងដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2 → 994<br>មិនដឹង ---------------------- → 994<br>8 |
| 993.1 | រយៈពេលប៉ុន្មានដែលភ្នែកប្រែពណ៌លឿង? | ថ្ងៃ --------------------1 ☐☐<br>ខែ --------------------2 ☐☐<br>មិនដឹង -------------- --- 9 9 8 |
| 994 | តើគាត់មើលទៅស្លេកស្លាំង (មិនសូវមាន/ខ្វះឈាម) ឬស្លេកនៅបាតដៃ ភ្នែក ឬក្រចកដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ---- 2 → 995<br>មិនដឹង ---------------------- → 995 |

| | | |
|---|---|---|
| | | 8 |
| 994.1 | រយៈពេលប៉ុន្មានដែលមើលទៅស្លេកស្លាំង (មិនសូវមាន/ខ្វះ ឈាម) ឬស្លេកនៅបាតដៃ ភ្នែក ឬក្រចក? | ថ្ងៃ --------------------- □□<br>មិនដឹង -------------- --- 9 8 |

| | | |
|---|---|---|
| 995 | តើគាត់មានដំបៅ បូស ឬឈឺត្រង់ណានៅលើខ្លួនប្រាណដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2 → 1001<br>មិនដឹង ---------------------- 8 → 1001 |
| 995.1 | រយៈពេលប៉ុន្មានដែល គាត់មានដំបៅ បូស ឬឈឺ? | ថ្ងៃ --------------------- □□<br>មិនដឹង -------------- --- 9 8 |
| 995.2 | តើដំបៅ បូស ឬឈឺស្ថិតនៅត្រង់ណា? | ----------------------------<br>------------- --- ---------<br>-<br>(បញ្ជាក់) |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 10. ការព្យាបាល និង សេវាសុខាភិបាល ដែលប្រើសំរាប់ការឈឺចុងក្រោយ** | | | |
| 1001 | តើគាត់មានបានទទួលការព្យាបាលជំងឺដែលនាំទៅរក ការស្លាប់នេះដែរឬទេ? | បាទ/ចាស៎ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 | → 1008<br>→ 1008 |
| 1002 | តើអ្នកអាចរាយបញ្ជីថ្នាំដែលគេអោយគាត់ សំរាប់ជំងឺដែលនាំទៅរកការស្លាប់នេះដែរឬទេ?<br>**ចូរចំលងចេញពីវេជ្ជបញ្ជា ឬឯកសារចេញពីពេទ្យ ប្រសិនបើមាន** | ______________________<br>______________________<br>______________________ | |
| 1003 | តើការព្យាបាលប្រភេទណាដែលគាត់បានទទួល:<br>1. ទឹកអូរ៉ាលិត និង/ឬការចាក់សេរ៉ូមតាមសសៃឈាម?<br>2. ការបញ្ចូលឈាម?<br>3. ការព្យាបាល/ចំណីអាហារតាមបំពង់ស៊កតាមច្រមុះ<br>4. ការព្យាបាលផ្សេងទៀត? | មាន មិនមាន មិនដឹង<br>ទឹកអូរ៉ាលិត និង/ ឬការចាក់សេរ៉ូម --- 1 2 8<br>ការបញ្ចូលឈាម ---- 1 2 8<br>តាមច្រមុះ -------- 1 2 8<br>ផ្សេងទៀត -- ------ 1 2 8<br>បញ្ជាក់ ------------------------ | |
| 1004 | សូមអ្នកមេត្តាប្រាប់ខ្ញុំ តើនៅកន្លែងណានៃកន្លែងទាំងនេះដែលគាត់បានទទួលការព្យាបាល នៅពេលឈឺដែលឈានទៅស្លាប់នោះ ? | មាន មិនមាន មិនដឹង<br>នៅផ្ទះ ---------- 1 2 8<br>គ្រូបូរាណ -------- 1 2 8<br>គ្លីនិករដ្ឋ --------- 1 2 8<br>មន្ទីរពេទ្យរដ្ឋ ------ 1 2 8<br>គ្លីនិកឯកជន ------- 1 2 8<br>មន្ទីរពេទ្យឯកជន ----1 2 8<br>ឱសថស្ថាន អ្នកលក់ថ្នាំ ហាង ----------- 1 2 8<br>ផ្សេងទៀត -------- 1 2 8<br>------------------------------<br>(បញ្ជាក់) | |
| 1005 | នៅក្នុងខែមុននឹងស្លាប់តើគាត់បានជួបពិគ្រោះ | ចំនួនជួបពិគ្រោះ ------------ | |

| | | | |
|---|---|---|---|
| | ប៉ុន្មានដងជាមួយសេវាសុខភាពផ្លូវការ ? | □□<br>មិនដឹង -------------- ---- 9 8 | |
| 1006 | តើមន្ត្រីសុខាភិបាលមានបានប្រាប់អ្នកពីមូលហេតុស្លាប់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ -------------------- ---- 2<br>មិនដឹង --------------------- 8 | → 1008<br>→ 1008 |

| | | |
|---|---|---|
| 1007 | តើមន្ត្រីសុខាភិបាលនិយាយថាម៉េច ? | ------------------------------------------------------------ |
| 1008 | តើគាត់មានទទួលការវះកាត់អ្វីសំរាប់ជំងឺនេះដែរឬទេ? | បាទ/ចាស៎ ------------------- 1<br>ទេ -------------------- ---- 2<br>មិនដឹង ---------------------- 8 |
| 1009 | រយះពេលប៉ុន្មាន<br>មុនស្លាប់ដែលក្មេងទទួលការវះ កាត់? | ថ្ងៃ ---------------------- □□<br>មិនដឹង -------------- --- 9 8 |
| 1010 | តើផ្នែកណានៃរាងកាយដែលគេវះកាត់? | ពោះ ---------------------- 1<br>ទ្រូង ------------------ ---- 2<br>ក្បាល ---------------------- 3<br>ផ្សេងទៀត ------------------- 6<br>----------------------------<br>(បញ្ជាក់)<br>មិនដឹង ---------------------- 8 |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|
| **ផ្នែក 11. កត្តាគ្រោះថ្នាក់** | | | |
| 1101 | តើគាត់ផឹកស្រា ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ---------------------<br>8 | <br>→ 1106<br>→ 1106 |
| 1102 | រយៈពេលប៉ុន្មានមកហើយដែលគាត់ពិសារស្រានេះ?<br>**ចូរកត់ត្រា "00" បើតិចជាងមួយឆ្នាំ** | ឆ្នាំ ---------------------<br>□□<br>មិនដឹង -------------- --- 9 8 | |
| 1103 | តើញឹកញាប់ប៉ុណ្ណាដែលគាត់ផឹកស្រា ? | រាល់ថ្ងៃ -------------------<br>1<br>ញឹកញាប់ (រាល់សប្តាហ៍) ----- ----<br>2<br>ម្តងម្កាល --------------------<br>3<br>មិនដឹង ---------------------<br>8 | |
| 1104 | តើគាត់ឈប់ផឹកស្រា ដែរឬទេ ? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ---------------------<br>8 | <br>→ 1106<br>→ 1106 |
| 1105 | រយៈពេលប៉ុន្មាន មុនស្លាប់ដែលគាត់ឈប់ពិសារស្រា?<br>**ចូរកត់ត្រា "00" បើតិចជាងមួយខែ** | ខែ ---------------------<br>□□<br>មិនដឹង -------------- --- 9 8 | |
| 1106 | តើគាត់ជក់ថ្នាំជក់ ដែរឬទេ (បារី ស៊ីហ្គា ខ្សៀ ។ល ។)? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ----------------------<br>8 | <br>→ 1201<br>→ 1201 |
| 1107 | រយៈពេលប៉ុន្មានមកហើយដែលគាត់ជក់ថ្នាំនេះ?<br>**ចូរកត់ត្រា "00" បើតិចជាងមួយឆ្នាំ** | ឆ្នាំ ---------------------<br>□□<br>មិនដឹង ------------------- 9 8 | |
| 1108 | តើញឹកញាប់ប៉ុណ្ណាដែលគាត់ជក់ ? | រាល់ថ្ងៃ -------------------<br>1<br>ញឹកញាប់ (រាល់សប្តាហ៍) ----- ----<br>2<br>ម្តងម្កាល --------------------<br>3<br>មិនដឹង ---------------------<br>8 | → 1201<br>→ 1201<br>→ 1201 |
| 1109 | តើគាត់ជក់បារីមួយថ្ងៃប៉ុន្មានដើម? | ចំនួនបារី ----------------- | |

| | | | |
|---|---|---|---|
| | | □□<br>មិនដឹង ------------------ 9 8 | |
| 1110 | តើគាត់មានឈប់ជក់ដែរឬទេមុនពេលគាត់ស្លាប់? | បាទ/ចាស់ ------------------ 1<br>ទេ ------------------- ----<br>2<br>មិនដឹង ---------------------<br>8 | → 1201<br>→ 1201 |
| 1111 | រយៈពេលប៉ុន្មាន មុនស្លាប់ដែលគាត់ឈប់ជក់?<br>**ចូរកត់ត្រា "00" បើតិចជាងមួយខែ** | ខែ --------------------<br>□□<br>មិនដឹង ------------------ 9 8 | |

| លេខ | សំណួរ និង កម្រង | កូដប្រភេទ | រំលង |
|---|---|---|---|

**ផ្នែក 12. ទិន្នន័យទាញចេញពីសំបុត្រមរណៈភាព**

| | | | |
|---|---|---|---|
| 1201 | តើអ្នកមានសំបុត្រមរណៈភាពរបស់អ្នកដែលស្លាប់ដែរឬទេ? | បាទ/ចាស់ ------------------ 1<br>ទេ ---------------------- 2<br>មិនដឹង --------------------- 8 | <br>→ 1301<br>→ 1301 |
| 1202 | អាចអោយខ្ញុំសុំមើលសំបុត្រមរណៈភាពបានដែរឬទេ?<br>**ចូរកត់ត្រាថ្ងៃខែឆ្នាំស្លាប់ ពីសំបុត្រមរណៈភាព** | ថ្ងៃ ☐☐ ខែ ☐☐ ឆ្នាំ ☐☐☐☐ | |
| 1203 | **ចូរកត់ត្រាថ្ងៃខែឆ្នាំដែលចេញសំបុត្រមរណៈភាព** | ថ្ងៃ ☐☐ ខែ ☐☐ ឆ្នាំ ☐☐☐☐ | |
| 1204 | ចូរកត់ត្រាមូលហេតុស្លាប់ពីជួរទី 1 (ខាងលើបំផុត) នៃសំបុត្រមរណៈភាព :<br>------------------------------------------------------------------------ | | |
| 1205 | ចូរកត់ត្រាមូលហេតុស្លាប់ពីជួរទី 2 នៃសំបុត្រមរណៈភាព (បើសិនមាន):<br>------------------------------------------------------------------------ | | |
| 1206 | ចូរកត់ត្រាមូលហេតុស្លាប់ពីជួរទី 3 នៃសំបុត្រមរណៈភាព (បើសិនមាន):<br>------------------------------------------------------------------------ | | |
| 1207 | ចូរកត់ត្រាមូលហេតុស្លាប់ពីជួរទី 4 នៃសំបុត្រមរណៈភាព (បើសិនមាន):<br>------------------------------------------------------------------------ | | |

| ផ្នែក 13. ទិន្នន័យទាញចេញពីរបាយការណ៍វេជ្ជសាស្ត្រដទៃទៀត | | | |
|---|---|---|---|
| 1301 | តើមានឯកសារវេជ្ជសាស្ត្រដទៃទៀតដែរឬទេ? | បាទ/ចាស់ ------------------- 1<br>ទេ -------------------- ---- 2 | <br>→ 1311 |
| 1302 | សំរាប់ឯកសារវេជ្ជសាស្ត្រនិមួយៗ ចូរសង្ខេបនូវពត៌មានលំអិតចំពោះការមកពិនិត្យពីរលើកចុងក្រោយ ( បើលើសពី2) ហើយកត់ត្រាថ្ងៃខែដែលចេញលិខិត ។ | | |
| 1303 | លិខិតអនុញ្ញាតអោយកប់ ( មូលហេតុស្លាប់) ------------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1304 | លទ្ធផលពិនិត្យក្រោយស្លាប់ ( មូលហេតុស្លាប់) -------------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1305 | បណ្ណ័សុខភាពមាតានិងទារក/បណ្ណ័ពិនិត្យផ្ទៃពោះ ( ពត៌មានទាក់ទង) -------------------------------<br>----------------------------------------------------------------------------------- | | |
| 1306 | ការចេញវេជ្ជបញ្ជាដោយមន្ទីរពេទ្យ ( ពត៌មានទាក់ទង) -----------------------------------------<br>----------------------------------------------------------------------------------- | | |
| 1307 | បណ្ណ័ព្យាបាល ( ពត៌មានទាក់ទង) --------------------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1308 | លិខិតចេញពីមន្ទីរពេទ្យ ( ពត៌មានទាក់ទង) ------------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1309 | ពត៌មានពីមន្ទីរពិសោធន៍ ( ពត៌មានទាក់ទង) ------------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1310 | ឯកសារមន្ទីរពេទ្យ ផ្សេងៗទៀត បញ្ជាក់ ----------------------------------------------<br>----------------------------------------------------------------------------------- | | |
| 1311 | កត់ត្រាម៉ោង នៅពេលបញ្ចប់នៃការសំភាសន៍ | ម៉ោង ------------ ☐☐<br>នាទី ------------ ☐☐ | |

<u>ការសង្កេតរបស់អ្នកសំភាសន៏</u>

ត្រូវបំពេញនៅពេលការសំភាសន៏បញ្ចប់សព្វគ្រប់

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

អធិប្បាយទៅលើសំណួរជាក់លាក់ៈ

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

អធិប្បាយអ្វីផ្សេងៗទៀតៈ

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

<u>ការសង្កេតរបស់អ្នកអភិបាល</u>

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

ឈ្មោះអ្នកអភិបាលៈ ----------------------------ថ្ងៃ ខែ ឆ្នាំៈ --------------------------

# ៣. អនុវត្តន៍ ICD-10 ពេលធ្វើកោសល្យវិច័យផ្ទាល់មាត់

## ៣.១ គោលបំណង

មគ្គុទេសក៍ពីការធ្វើកោសល្យវិច័យផ្ទាល់មាត់នេះ មានគោលបំណងជួយដល់បុគ្គលិកដែលត្រូវធ្វើកោសល្យវិច័យផ្ទាល់មាត់ អោយប្រើវិធាននៅក្នុង *ចំណាត់ថ្នាក់ស្ថិតិអន្តរជាតិអំពីជំងឺ និងបញ្ហាសុខភាព ច្បាប់កែតំរូវលើកទី១០* (ICD-10) ចំពោះការធ្វើរោគវិនិច្ឆ័យដែលកើតចេញពីការធ្វើកោសល្យវិច័យនោះ។ ជាគោលបំណងគឺថា ជួយបុគ្គលិកដែល កត់ត្រារោគវិនិច្ឆ័យលើក្នុងសំបុត្រមរណភាព ស្តង់ដារ (អ្នកបញ្ជាក់) និងដាក់លេខកូដរោគវិនិច្ឆ័យ(អ្នកដាក់លេខកូដ) និងជ្រើសរើសមូលហេតុនៃការស្លាប់(អ្នកដាក់លេខកូដ)។ មគ្គុទេសក៍នេះបង្ហាញពីទិដ្ឋភាពទូទៅពី ការបញ្ជាក់ ការដាក់លេខកូដ និងការដាក់មូលហេតុមរណភាព ដែលអាចអោយអ្នកដែលធ្វើការលើទិដ្ឋភាពណាមួយនៃនិតិវិធីការធ្វើកោសល្យវិច័យផ្ទាល់មាត់ នឹងយល់បានគ្រប់ជំហានទាំងអស់។ ការប្រើមគ្គុទេសក៍នេះនឹងធានានូវឯកភាពនៃស្ថិតិមរណភាពដែលផ្អែកលើការធ្វើកោសល្យវិច័យផ្ទាល់មាត់ ហើយអាចប្រៀបធៀបបានជាមួយប្រភពដទៃទៀតនៃទិន្នន័យពីមូលហេតុនៃការស្លាប់ដែលដាក់លេខកូដតាម ICD-10។ មគ្គុទេសក៍នេះរួមបញ្ចូលនូវសំនួរ និង លំហាត់ ដើម្បីអោយអ្នកប្រើប្រាស់ស្គាល់ច្បាស់ពី ICD-10 ដើម្បីចៀសវាងបាននូវកំហុសញឹកញាប់។ មគ្គុទេសក៍ពីការធ្វើ កោសល្យវិច័យផ្ទាល់មាត់ ដែលមាននៅផ្នែក ៣.១ -៣.៨ ត្រូវប្រើរួមជាមួយសៀវភៅ ICD-10 ទាំងបីក្បាល។

បញ្ជីមូលហេតុនៃការស្លាប់សំរាប់ការធ្វើកោសល្យវិច័យផ្ទាល់មាត់ ដោយមានកូដ ICD-10 (តារាងពាក់ព័ន្ធ) ក្នុងវគ្គ ៣.៩ ផ្តល់នូវបញ្ជីចំណាត់ថ្នាក់មូលហេតុនៃការស្លាប់សំរាប់កោសល្យវិច័យផ្ទាល់មាត់ ដែលគេដាក់នៅក្នុងចំណាត់ថ្នាក់ ICD-10 ដែលមានបីខ្ទង់ និងបួនខ្ទង់តារាងពាក់ព័ន្ធសំរួលនូវដំណើរការនៃការប្រើប្រាស់ ICD-10 ក្នុងការដាក់កូដ។ តារាងនេះ មានកូដលក្ខណៈវិនិច្ឆ័យមួយចំនួនដែលធានាអោយមានការប្រើប្រាស់ចំណាត់ថ្នាក់បានត្រឹមត្រូវ ព្រមទាំងមានជាតំរុយខ្លះ សំរាប់ជួយអោយអ្នកប្រើប្រាស់ចៀសវាងបាននូវកំហុសដែលឧស្សាហ៍កើតមាន។ បើសិនជាមានពតិមានគ្រប់គ្រាន់ដើម្បីពណ៌នាពីមូលហេតុនៃការស្លាប់ បានលំអិតជាងពតិមានដែលផ្តល់ដោយតារាងនេះ អ្នកដាក់កូដគួរប្រើ ICD-10 ពេញលេញ។

ត្រូវមានសៀវភៅណែនាំដោយឡែកមួយទៀត ដែលត្រូវតែ ចងក្រងឡើង ដោយអ្នកដែលមានបំណង បង្កើតគំរោងធ្វើ កោសល្យវិច័យ ផ្ទាល់មាត់។ ខ្លឹមសាររបស់វាអាស្រ័យទៅតាមស្ថានភាពនៃកន្លែងនិមួយៗ ហើយគំរោងណាក៏ដោយគួរតែពណ៌នាពីៈ

- ដំណើរការនៃការធ្វើកោសល្យវិច័យផ្ទាល់មាត់
- អង្គការលេខ និង ចរន្តការងាររបស់គំរោង
- ការប្រមូលទិន្នន័យ
- ការប្រើសំនួរសំភាសន៍ដោយឡែក
- ការណែនាំពីការបកស្រាយទិន្នន័យបានពីសំភាសន៍ពេលធ្វើកោសល្យវិច័យផ្ទាល់មាត់
- តួនាទីនិងការទទួលខុសត្រូវរបស់បុគ្គលិកពាក់ព័ន្ធទាំងអស់
- និតិវិធីធានាគុណភាព និង

- កាលៈទេសៈនៅនឹងកន្លែង ដូចជា តើអ្នកណាជាអ្នកធ្វើទំនាក់ទំនង លេខទូរស័ព្ទដែលត្រូវទាក់ទង និង ថាតើមានកំព្យូទ័រដែរឬទេ

## ៣.២ និជ្ជភាពទូទៅ

ផ្នែកនេះនិយាយពីទិដ្ឋភាពទូទៅពីការប្រើប្រាស់ពត៌មានមរណភាព ពន្យល់ថាតើគ្រូពេទ្យប្រមូលពត៌មានទាំងនោះតាមរបៀបណា និងពន្យល់ថា តើដំណើរការនេះខុសគ្នាពីកន្លែងមួយទៅកន្លែងមួយទៀតយ៉ាងណា។ ផ្នែកនេះក៏និយាយផងដែរថា តើការធ្វើស្តង់ដាណីយកម្មនៃចំណាត់ថ្នាក់មានសារៈសំខាន់យ៉ាងណា ក្នុងការធានាអោយអាចប្រៀបធៀបគ្នាបាននៃទិន្នន័យរវាងក្រុមមនុស្សផ្សេងគ្នា និងទៅតាមពេលវេលាខុសគ្នា។

### ៣.២.១ សេចក្តីផ្តើមពីពត៌មានមរណភាព

នៅតំបន់ជាច្រើននៃពិភពលោកនេះ មនុស្សមួយចំនួនធំមិនបានទទួលសេវាថែទាំសុខភាពពីបុគ្គលិកពេទ្យដែលមានសមត្ថភាពឡើយ។ នៅតំបន់ទាំងនេះ សេវាថែទាំសុខភាពច្រើនតែផ្តល់ដោយ បុគ្គលិកធម្មតា ឬបុគ្គលិកអមវេជ្ជសាស្ត្រ ហើយច្រើនធ្វើតាមរបៀបបុរាណ ឬតាមការបណ្តុះបណ្តាលមូលដ្ឋាន។ នៅក្នុងស្ថានភាពបែបនេះគឺបុគ្គលិកដដែលនេះ ដែលផ្តល់ពត៌មានពីមរណភាពដែលគេត្រូវការសំរាប់បញ្ជាក់ពីអត្ថិភាពនៃបញ្ហាសុខភាព និងសំរាប់សំរួលដល់ការគ្រប់គ្រងប្រព័ន្ធសុខាភិបាល។
គេប្រើពត៌មានមរណភាពដើម្បី :

- បង្កើតពត៌មានពីអេពីដេមីសាស្ត្រ និង ការបង្ការ
- គ្រប់គ្រងការថែទាំសុខភាព
- ប្រើថវិកាសាធារណៈអោយមានប្រយោជន៍បំផុត
- ប្រៀបធៀបស្ថានភាពសុខភាពរវាងតំបន់ផ្សេងៗ

### ៣.២.២ ប្រភពនៃពត៌មានមរណភាព

គេប្រមូលពត៌មានមរណភាពតាមប្រព័ន្ធមួយគេហៅថា "ការចុះបញ្ជីជីវិត" (Vital registration)។ ប្រព័ន្ធនេះពណ៌នាពីរបៀបដែលប្រទេសមួយ ធ្វើការប្រមូលពត៌មានពីកំណើត និងមរណភាពនៃប្រជាជនរបស់គេ។ ជាទូទៅគេប្រមូលពត៌មានទាំងនេះ នៅតាមមជ្ឈមណ្ឌលជាតិ ដែលរក្សាទុកនូវឯកសារដែលកត់ត្រាពីព្រឹត្តការណ៍ជីវិតទាំងអស់ (កំណើត និងមរណភាព) ដោយប្រើទំរង់ស្តង់ដារ។ ប្រទេសនានានៅជុំវិញពិភពលោក មានប្រព័ន្ធចុះបញ្ជីជីវិតនៅដំណាក់កាលខុសៗគ្នានៃការអភិវឌ្ឍ។ សមាមាត្រនៃព្រឹត្តិការណ៍ជីវិតដែលបានចុះបញ្ជី (អត្រាគ្របដណ្តប់) និងភាពលំអិត និងគុណភាពនៃពត៌មាន ក៏ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដែរ។ នៅក្នុងការវិវត្តពីការគ្មានប្រព័ន្ធចុះបញ្ជីទៅមានប្រព័ន្ធចុះបញ្ជីពេញលេញមួយ ជាការមានប្រយោជន៍ដែលត្រូវធ្វើតាមលក្ខណៈជាជំហានៗ។

- **ការចុះបញ្ជីបែបឆ្នាំ:** ជាប្រព័ន្ធមួយដែលគេធ្វើការតាមដានជម្ងឺមួយ ឬ ក្រុមជម្ងឺមួយ នៅក្នុងចំណោម តំណាងរបស់ប្រជាជន ជាឧទាហរណ៍ គេវាស់មរណភាពមាតា នៅក្នុងចំណោម តំណាងប្រជាជន នៅទីក្រុង និង ជនបទ
- **ប្រព័ន្ធតាមដានប្រជាសាស្ត្រ** ជាតំបន់ដែលគេបានបង្កើតប្រព័ន្ធចុះបញ្ជី ហើយធ្វើតេស្ត និង វាយតម្លៃ ប្រព័ន្ធនោះ

- **ប្រព័ន្ធចុះបញ្ជីតំណាង** ជាប្រព័ន្ធដែលចុះបញ្ជីតំណាងប្រជាជន ដោយប្រើពិធីសារនៃការចុះបញ្ជីជីវិត
- **ការចុះបញ្ជីជីវិតមិនពេញលេញ** មានន័យថា គេធ្វើការចុះបញ្ជីពេញលេញនៅកន្លែងណាដែលមានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ប៉ុណ្ណោះ ឧទាហរណ៍នៅតំបន់ទីក្រុង ហើយនៅកន្លែងផ្សេងទៀតជាទូទៅនៅតំបន់ជនបទគេធ្វើការចុះបញ្ជីតំណាង ។
- **ការចុះបញ្ជីជីវិតពេញលេញ** សំដៅលើប្រព័ន្ធដែលមានការចុះបញ្ជី កំណើត និងមរណភាពបានយ៉ាងហោចណាស់ ៩០% ។ ពតិមានដែលគេប្រមូលពេលចុះក្នុងបញ្ជីមរណៈភាពត្រូវមាន អាយុ ភេទ មូលហេតុស្លាប់ អាស័យដ្ឋានស្នាក់នៅ និង កន្លែងទទួលមរណភាព ។

### ៣.២.៣ ការធ្វើកោសល្យវិច័យផ្ទាល់មាត់

ការធ្វើកោសល្យវិច័យផ្ទាល់មាត់ គឺជាបច្ចេកទេស ដែលគេប្រើ សំរាប់កំណត់ មូលហេតុនៃការស្លាប់ ដោយធ្វើការសាកសួរ អ្នកថែទាំ មិត្តភ័ក្រ ឬសមាជិកគ្រួសារពីរោគសញ្ញា ដែលស្តែងចេញមុនពេលស្លាប់ ។ ការនេះគេច្រើនធ្វើឡើង ដោយប្រើកំរងសំនួរស្តង់ដាដើម្បីប្រមូលពតិមានលំអិតពីរោគសញ្ញា ការត្អូញត្អែរ ប្រវត្តិ ឬព្រឹត្តិការណ៍វេជ្ជសាស្ត្រនានា ។

គេកំណត់ មូលហេតុនៃការស្លាប់ លំដាប់នៃមូលហេតុ ដែលនាំទៅដល់ការស្លាប់ ផ្អែកតាមទិន្នន័យដែលប្រមូលបានពីកំរងសំនួរ និងតាមពតិមានដទៃទៀតដែលមាន ។ វិធាន ឬមគ្គុទេសក៏អាល់ហ្គោរីត ឬកម្មវិធីកំព្យូទ័រអាចជួយក្នុងការវាយតម្លៃពតិមាន ។

គោលបំណងនៃការធ្វើកោសល្យវិច័យផ្ទាល់មាត់គឺធ្វើការពណ៌នាពីមូលហេតុនៃការស្លាប់ នៅថ្នាក់សហគមន៍ ឬនៅថ្នាក់ប្រជាជន ដែលគ្មាន ឬមានតិចតួចនូវការចុះបញ្ជីជីវិតដែលមានភ្ជាប់ជាមួយនូវប័ណ្ណវេជ្ជសាស្ត្រ ។

### ៣.២.៤ មូលហេតុនៃការស្លាប់

ការចុះបញ្ជីមូលហេតុនៃការស្លាប់ ពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ មានគោលបំណង កំណត់រកមូលហេតុមួយដែលនាំអោយមានការស្លាប់ ។ ជាការចាំបាច់ ដែលត្រូវតែធ្វើតាម៨ជំហានជាស្តង់ដារក្នុងការកំណត់នូវមូលហេតុនៃការស្លាប់ ។ ដើម្បីប្រមូលពតិមានស្ថិតិដែលអាចយកជាការបាន និងមានប្រយោជន៍គេត្រូវតែអនុវត្តជំហាននិមួយៗអោយមមានលក្ខណៈជាស្តង់ដារ ។ វគ្គបន្តបន្ទាប់ខាងក្រោមនេះនឹងនិយាយលំអិតពីជំហាននិមួយៗ:

#### ៣.២.៤.១ ជំហានទី១: កំណត់ពីមូលហេតុនៃការស្លាប់

នៅកន្លែងដែលមានគ្រូពេទ្យធ្វើការបញ្ជាក់ពីមូលហេតុនៃការស្លាប់ ដោយផ្ទាល់គ្រូពេទ្យធ្វើដូច្នោះបានតាមរយៈការពិនិត្យសពការបកស្រាយឯកសារវេជ្ជសាស្ត្រ និងពតិមានផ្សេងទៀត ឬធ្វើកោសល្យវិច័យ ។

នៅកន្លែងដែលមនុស្សស្លាប់ដោយមិនបានជួបគ្រូពេទ្យ គ្រូពេទ្យមិនបានពិនិត្យសពឡើយ គេអាចប្រើការធ្វើកោសល្យវិច័យផ្ទាល់មាត់ដើម្បីប្រមូលពតិមានចាំបាច់សំរាប់កំណត់រកមូលហេតុនៃការស្លាប់ ។

### ៣.២.៤.២ ជំហានទី២: បញ្ជាក់ពីការស្លាប់

លក្ខខ័ណ្ឌដែលនាំទៅដល់ការស្លាប់ មូលហេតុនៃការស្លាប់ ត្រូវរាយាការណ៍ក្នុង "ទំរង់ជាអន្តរជាតិមួយនៃប័ណ្ណវេជ្ជសាស្ត្រ នៃមូលហេតុនៃការស្លាប់"។ បើគេធ្វើកោសល្យវិច័យផ្ទាល់មាត់ គេប្រើ ទំរង់ជាអន្តរជាតិនៃប័ណ្ណវេជ្ជសាស្ត្រ នៃមូលហេតុ នៃការស្លាប់។ ការនេះអាចអោយគេប្រើនិតិវិធីស្តង់ដារ ICD តាំងពីដំណាក់កាលដំបូងនៃការប្រមូលពត៌មាន។ អ្នកដែលកំណត់រោគវិនិច្ឆ័យនៅពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ គឺជាអ្នកដែលទទួលខុសត្រូវក្នុងការកត់ត្រាមូលហេតុនៃការស្លាប់ ក្នុងលិខិតមរណភាព។

### ៣.២.៤.៣ ជំហានទី៣: ដាក់កូដមូលហេតុនៃការស្លាប់

ត្រូវដាក់កូដ រោគវិនិច្ឆ័យដែលមាននៅលើលិខិតមរណភាព។ ការដាក់កូដមានន័យថា ដាក់លេខស្តង់ដារមួយជាតំណាងជម្ងឺមួយ ឬមូលហេតុនៃការស្លាប់មួយ។ កូដកំណត់ពីចំណាត់ថ្នាក់ត្រឹមត្រូវមួយនៅក្នុង ICD-10។ ICD-10 ផ្តល់វិធាន និងមគ្គុទេសក៏សំរាប់ដាក់កូដ។

ការដាក់កូដអោយជម្ងឺមួយ អាចអោយគេធ្វើការចាត់ជាក្រុមនូវមូលហេតុស្រដៀងៗគ្នានៃការស្លាប់។ គេអាចធ្វើវិភាគទិន្នន័យដែលដាក់កូដបាន ទោះជាក្នុងប័ណ្ណសរសេរជាភាសារអ្វីក៏ដោយ។ អ្នកដាក់កូដអាចជាគ្រូពេទ្យ ឬមនុស្សធម្មតាដែលបានទទួលការបណ្តុះបណ្តាលពិសេស។

ក្នុងករណីណាក៏ដោយ ជាការសំខាន់ណាស់ដែលអ្នកដាក់កូដត្រូវមានការយល់ដឹងច្បាស់លាស់ពីកូដនៅក្នុង ICD-10។ អ្នកដាក់កូដទាំងអស់ត្រូវស្គាល់ពាក្យពេទ្យ និងយល់ដឹងថា ខ្លួនប្រាណមនុស្សមានដំណើរការយ៉ាងដូចម្តេច។

### ៣.២.៤.៤ ជំហានទី៤: ជ្រើសរើសមូលហេតុនៃការស្លាប់

នៅក្នុង ICD-10 អង្គការសុខភាពពិភពលោក បានបង្កើតវិធានសំរាប់ជ្រើសរើសមូលហេតុនៃការស្លាប់។ គេប្រើវិធាននេះដើម្បីកំណត់មូលហេតុមួយនៃការស្លាប់ បើមានមូលហេតុលើសពីមួយ នៅក្នុងលិខិតមរណភាព។

វិធានទាំងនេះធានាថា គេប្រើដំណើរការជ្រើសរើសដូចគ្នានៅគ្រប់ទីកន្លែង។ នៅពេលដែលគេអនុវត្តតាមវិធាននេះ ការជ្រើសរើសមិនអាស្រ័យទៅតាមការយល់ឃើញរបស់បុគ្គលឡើយ ហើយគេអាចប្រៀបធៀបលទ្ធផល (មូលហេតុនៃការស្លាប់)នៅថ្នាក់មូលដ្ឋានថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិបាន។

ការចាំបាច់ដែលត្រូវមានការបណ្តុះបណ្តាលជាបន្ត និងបទពិសោធន៍ល្អដើម្បីធានាអោយមានការអនុវត្តតាមវិធានអោយបានត្រឹមត្រូវ។ ការស្លាប់ខ្លះ មានតែមូលហេតុមួយទេដែលបានចុះក្នុងលិខិតមរណភាព។ ក្នុងករណីនេះ អ្វីដែលត្រូវធ្វើគឺដាក់កូដមូលហេតុមួយនេះ។

ក្នុងករណីផ្សេងទៀត អាចមានមូលហេតុពីរ ឬបី បានចុះក្នុងលិខិតមរណភាព។ បើមានមូលហេតុពីរ ឬបីត្រូវជ្រើសរើសយកមូលហេតុដែលសមស្របបំផុតសំរាប់ដាក់កូដ និងរាយការណ៍។ មូលហេតុមួយដែលជ្រើសរើសបាននេះគេហៅថា "មូលហេតុចំបងនៃការស្លាប់"។ ដូច្នេះមូលហេតុចំបងនៃការស្លាប់ គឺជា លក្ខខ័ណ្ឌ ព្រឹត្តិការណ៍ ឬ កាលៈទេសៈ ដែលថា បើគ្មានវាទេ អ្នកជម្ងឺនឹងមិនស្លាប់ឡើយ។

**អង្គការសុខភាពពិភពលោកអោយនិយមន័យមូលហេតុចំបងនៃការស្លាប់យ៉ាងដូច្នេះ៖ ជាជម្ងឺ ឬរបួសដែលបណ្តាលអោយកើតមាន ព្រឹត្តការណ៍នៃការឈឺនាំទៅ ដល់ការស្លាប់ដោយផ្ទាល់ ឬជាកាលៈទេសៈនៃគ្រោះថ្នាក់ ឬហិង្សា ដែលនាំទៅដល់របួសដល់ស្លាប់។**

*ឧទាហរណ៍:*

អ្នកជំងឺមហារីកម្នាក់ស្លាប់។ មូលហេតុភ្លាមៗដែលនាំអោយស្លាប់គឺការគាំងបេះដូងបណ្តាលមកពីការរាលដាលនៃមហារីក។ ប៉ុន្តែជំងឺមហារីកដំបូងគឺនៅនឹងដោះ។ ដូច្នេះតាមលំដាប់លំដោយគឺថា: មហារីករាលដាល នាំអោយគាំងបេះដូង។

ក្នុងឧទាហរណ៍នេះ ការគាំងបេះដូងជាមូលហេតុចុងក្រោយធ្វើអោយស្លាប់នៅក្នុងលំដាប់ដែលផ្តើមដោយមហារីកដោះ។ មហារីកដោះគឺជាលក្ខខ័ណ្ឌដែលត្រូវដាក់កូដថាជាមូលហេតុចំបងនៃការស្លាប់។

## ៣.៣ ការណែនាំ

ផ្នែកនេះផ្តល់នូវការណែនាំ ក្នុងការបំពេញជំហានទាំងបួនដែលបានរៀបរាប់នៅក្នុងផ្នែក ៣.២។ ក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់ លិខិតមរណភាពស្តង់ដារ (រូបទី១) គំរបានបំពេញពេញលេញណាស់។ ប៉ុន្តែគេត្រូវតែប្រើលិខិតស្តង់ដារនេះជានិច្ចក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់ ដើម្បីធានាថាគេធ្វើទៅតាមវិធានតែមួយក្នុងការកំណត់មូលហេតុចំបងនៃការស្លាប់។

ផ្នែកនេះក៏បង្ហាញពីការរៀបរាប់ដោយសង្ខេបនូវគោលការណែនាំ និងវិធាននៃការដាក់កូដក្នុង ICD-10 សំរាប់ជ្រើសរើសមូលហេតុចំបងនៃការស្លាប់។ អ្នកដាក់កូដត្រូវការការបណ្តុះបណ្តាលជាក់លាក់ក្នុងការអនុវត្តវិធាននេះ។

### ៣.៣.១ ការកំណត់មូលហេតុនៃការស្លាប់ក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់

កំរងសំនួរដែលបានបំពេញរួចហើយនៅក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់ មានពត៌មានពីជម្ងឺ រោគសញ្ញា អាយុ ភេទ របស់អ្នកជំងឺក៏ដូចជាប្រវត្តិអ្នកជំងឺ និង ឯកសារវេជ្ជសាស្ត្រ (បើមាន)។ ពត៌មានទាំងនេះ ប្រើសំរាប់កំណត់មូលហេតុនាំដល់ការស្លាប់។

#### ៣.៣.១.១ កំណត់ជម្ងឺតាមរោគសញ្ញា

ការប្រើសំណុំលក្ខណៈវិនិច្ឆ័យស្តង់ដារនៃការធ្វើរោគវិនិច្ឆ័យ ធានាថា លទ្ធផលដែលបានពីការវាយតម្លៃ និង ជ្រើសរើស ត្រូវធ្វើឡើងដោយមានស្តង់ដា ដោយបុគ្គលិកដែលពាក់ព័ន្ធនៅក្នុងជំហាននេះ។ អ្នកនេះអាចជាគ្រូពេទ្យ ឬមនុស្សធម្មតាដែលទទួលបានការបណ្តុះបណ្តាលវេជ្ជសាស្ត្រ។

#### ៣.៣.១.២ លក្ខណៈវិនិច្ឆ័យនៃការធ្វើរោគវិនិច្ឆ័យ (អាល់ហ្គោរីត)

គេអាចហៅលក្ខណៈវិនិច្ឆ័យនៃកាធ្វើរោគវិនិច្ឆ័យថា អាល់ហ្គោរីត។ វាពណ៌នាថាតើការរួមផ្សំបែបណារវាង រោគសញ្ញា រយៈពេល និង ភាពធ្ងន់ធ្ងរ ដែលអាចនាំទៅដល់រោគវិនិច្ឆ័យជាក់លាក់មួយ។

គេប្រើលក្ខណៈវិនិច្ឆ័យនៃការធ្វើរោគវិនិច្ឆ័យទាំងនេះសំរាប់:

- ផ្តល់ជាមគ្គុទេសក៍ ។ គេអាចប្រើអាល់ហ្គោរីតដើម្បីជួយជាមគ្គុទេសក៍ និង គាំទ្រដល់ការធ្វើការសំរេចចិត្តរបស់គ្រូពេទ្យ ដើម្បីធានាថាគេបានគិតគូរដល់គ្រប់កត្តាទាំងអស់ ក្នុងការធ្វើរោគវិនិច្ឆ័យ ។
- ធានាស្ថេរភាពនៃលទ្ធផល ។ អាល់ហ្គោរីត ជួយអោយមានការផ្តោតលទ្ធភាពនៃរោគវិនិច្ឆ័យទៅលើលក្ខខ័ណ្ឌមួយឬច្រើន និងបន្ថយចំនួនរោគវិនិច្ឆ័យដែលមិនទំនង ។

*ឧទាហរណ៍:*

**ពីសម្ភាសន៍ទៅរោគវិនិច្ឆ័យ**

គេសម្ភាសន៍ប្រពន្ធរបស់បុរសម្នាក់ដែលស្លាប់កាលពីពីរខែកន្លងទៅ ។ គាត់រាយការណ៍ថា ប្តីគាត់ត្អូញត្អែរថាឈឺក្បាលពីរ-បីថ្ងៃ ។ រួចគាត់ពិបាកងាកក្បាល រួចនិយាយថាឈឺក ។

គាត់និយាយទៀតថា ប្តីគាត់មានឡើងកំដៅ ញាក់ និងបែកញើសច្រើន ។ រយៈពេលប៉ុន្មានថ្ងៃក្រោយ គាត់មានក្អួត និងវង្វេងវង្វាយ ។ គាត់អស់កំលាំង ហើយដេករហូត ។

អ្នកសម្ភាសន៍សួរក្រែងគាត់មានគ្រោះថ្នាក់ និងក្រែងគាត់មានប៉ះទង្គិចក្បាលប៉ុន្មានអាទិត្យមុនពេលគាត់ស្លាប់ ។ ប្រពន្ធគាត់ឆ្លើយថា គាត់មិនបានធ្លាក់ ឬមានរបួសអ្វីលើក្បាលរបស់គាត់ទេ ។

គេវាយតម្លៃចំលើយនេះដោយប្រើសំណុំនៃលក្ខណៈវិនិច្ឆ័យ ។ បន្ទាប់មក គេអោយចំណាត់ថ្នាក់ កោសល្យវិច័យផ្ទាល់មាត់មួយ និងកូដ ICD-10 មួយចំពោះករណីនេះ ។ ដំណើរការនៃឧទាហរណ៍ខាងលើមានបង្ហាញនៅក្នុងរូបទី១ ។

## រូបទី ១. គំរូនៃអាល់ហ្គោរីតរោគវិនិច្ឆ័យសំរាប់កំណត់រោគវិនិច្ឆ័យ "រលាកស្រោមខួរ"



អាល់ហ្គោរីតដែលប្រើសំរាប់ជ្រើសរើសរោគវិនិច្ឆ័យជាក់លាក់មួយពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ អាចគិតគូរផងដែរដល់ ចំនួនជំងឺនៅក្នុងតំបន់។ ICD-10 ផ្តល់នូវឧទាហរណ៍បែបនោះ (សូមមើលកំណត់ចំណាំនៅត្រង់កូដ A09 ជំពូក១ សៀវភៅ១)។

មានអាល់ហ្គោរីតជាច្រើនសំរាប់ប្រើ។ អ្នកត្រូវតែសំរេចថាតើអ្នកប្រើមួយណាសំរាប់គំរោងធ្វើកោសល្យវិច័យផ្ទាល់មាត់របស់អ្នក។ មានលក្ខណៈវិនិច្ឆ័យខ្លះដូចគ្នា។ លក្ខណៈវិនិច្ឆ័យទាំងនេះមាននៅខាងចុងនៃផ្នែកទី៣។

## ៣.៣.១.៣ កំព្យូទ័រ

កំព្យូទ័រអាចមានប្រយោជន៏នៅជំហានផ្សេង១នៃការកំណត់មូលហេតុនៃការស្លាប់។ វាអាចជួយអោយមានភាពងាយស្រួលក្នុងការកំណត់រោគវិនិច្ឆ័យ ដោយប្រើពតិមានដែលប្រមូលបានពី ការធ្វើកោសល្យវិច័យផ្ទាល់មាត់ វាអាចជួយក្នុងការដាក់កូដ ហើយវាក៏អាចមានប្រយោជន៏ក្នុងការជ្រើសរើសយក មូលហេតុចំបងនៃការស្លាប់ ប្រសិនបើមានមូលហេតុលើសពី មួយ នៅក្នុងលិខិតមរណភាព។

## ៣.៣.២ ទំរង់ជាអន្តរជាតិនៃលិខិតវេជ្ជសាស្ត្រសំរាប់បញ្ជាក់មូលហេតុនៃការស្លាប់

លិខិតមរណភាពជាប្រភពចំបងនៃទិន្នន័យមរណភាព។ លិខិតមរណភាពដែលគេបំពេញបានត្រឹមត្រូវ បង្ហាញច្បាស់ថាហេតុអ្វី និងយ៉ាងដូចម្តេច បានជាស្លាប់។ ពតិមានដែលប្រមូលបានតាមរយៈកោសល្យវិច្ឆ័យផ្ទាល់មាត់ អាចប្រើសំរាប់ដាក់រោគវិនិច្ឆ័យមួយឬច្រើន ដើម្បីបំពេញពតិមានពីមូលហេតុនៃកាស្លាប់ និង ដើម្បីបំពេញនូវលិខិតមរណភាព។

ក្នុងការបំពេញលិខិត អ្នកបញ្ជាក់ត្រូវតែរាយការណ៏ រាល់ជម្ងឺ ភាពមិនប្រក្រតី របួស ឬ មូលហេតុខាងក្រៅណាមួយដែលគេជឿថាអាចរួមចំណែកដល់ការស្លាប់។ ជាការសំខាន់ណាស់ដែលត្រូវចាំថា របៀបស្លាប់ - ដូចជា ការដាច់ដង្ហើម គាំងបេះដូង ស្លាប់ខួរក្បាល- មិនត្រូវចាត់ទុកជាមូលហេតុនៃការស្លាប់ឡើយ។

លិខិតមរណភាពមានពីរផ្នែក (ផ្នែក I និង ផ្នែក II) និងវគ្គមួយសំរាប់កត់ត្រាពីចន្លោះពេលចាប់ផ្តើមឈឺ និងកាលបរិច្ឆេទស្លាប់។
ផ្នែក I សំរាប់កត់ត្រាជម្ងឺ ឬ លក្ខខ័ណ្ឌ ទាក់ទងនឹងព្រឹត្តិការណ៍លំដាប់លំដោយ ដែលនាំដោយផ្ទាល់ទៅដល់ការស្លាប់
ផ្នែក II សំរាប់កត់ត្រាលក្ខខ័ណ្ឌដែលមិនមានទំនាក់ទំនងផ្ទាល់ជាមួយព្រឹត្តិការណ៍ដែលនាំដល់ការស្លាប់ ប៉ុន្តែ បានរួមចំណែកដល់ការស្លាប់។

### ៣.៣.២.១ ផ្នែក I នៃលិខិតមរណភាព

ផ្នែក I នៃលិខិតមរណភាព មានបួនបន្ទាត់សំរាប់កត់ត្រាព្រឹត្តិការណ៏លំដាប់លំដោយ ដែលនាំទៅដល់ការស្លាប់។ កន្លែងនេះប្រើសំរាប់ជម្ងឺដែលពាក់ព័ន្ធនឹងលំដាប់លំដោយនៃព្រឹត្តិការណ៏ ដែលនាំដោយផ្ទាល់ទៅដល់ការស្លាប់។ លក្ខខ័ណ្ឌដែលគេគិតថា ជាមូលហេតុពិតប្រាកដនៃការស្លាប់ ត្រូវដាក់នៅបន្ទាត់ចុងក្រោយបំផុត នៃផ្នែក I នេះ។

មូលហេតុផ្ទាល់នៃការស្លាប់ត្រូវដាក់នៅបន្ទាត់ទីមួយគឺបន្ទាត់ I (ក)។ ជានិច្ចកាលត្រូវតែបំពេញនៅលើបន្ទាត់ I (ក)។ នៅផ្នែក I អាចមានតែការបំពេញនៅលើបន្ទាត់ I (ក) នេះបាន។

បើមានលក្ខខ័ណ្ឌពីរ ឬច្រើនដែលត្រូវកត់ត្រា គេត្រូវបំពេញនូវលំដាប់លំដោយនៃព្រឹត្តិការណ៍ដែលនាំទៅដល់ការស្លាប់ ។ គេត្រូវបំពេញព្រឹត្តិការណ៍និមួយៗនៅលើបន្ទាត់ផ្សេងគ្នា ។

មានការលើកលែងមួយៈ អាចមានជម្ងឺពីរដែលមិនទាក់ទងគ្នាសោះ ហើយដែលគេគិតថា អាចរួមចំណែក ស្មើគ្នា ដល់លំដាប់លំដោយនៅពេលណាមួយ ។ ក្នុងករណីមិនធម្មតាបែបនេះ គេអាចបំពេញនៅលើបន្ទាត់តែមួយ ។

## រូបទី ២. ទំរង់ជាអន្តរជាតិនៃលិខិតវេជ្ជសាស្ត្រ នៃមូលហេតុនៃការស្លាប់

### ទំរង់ជាអន្តរជាតិនៃលិខិតមរណភាព

| មូលហេតុនៃការស្លាប់ | | ចន្លោះពេលប្រហាក់ប្រហែល រវាងពេលចាប់ឈឺនិង ស្លាប់ |
|---|---|---|
| **I** | | |
| ជម្ងឺដែលនាំដល់ការស្លាប់ដោយផ្ទាល់ * | ក) - ........................................<br>(បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ................................. |
| **មូលហេតុកើតមុន**<br>លក្ខខ័ណ្ឌឈឺ, បើមាន, ដែលនាំអោយកើតមាននូវមូលហេតុខាងលើ, ដាក់លក្ខខ័ណ្ឌផ្ទាល់នៅក្រោយបង្អស់ | ខ) - ........................................<br>(បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ................................. |
| | គ) - ........................................<br>(បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ................................. |
| | ឃ) - ........................................ | ................................. |
| **II** | | |
| លក្ខខ័ណ្ឌសំខាន់ៗ ដែលអាចរួមចំណែកដល់ការស្លាប់ តែមិនទាក់ទងនឹងជម្ងឺ ឬលក្ខខ័ណ្ឌដែលបណ្តាលអោយស្លាប់ទេ | ..................................................... | ................................. |
| | ..................................................... | ................................. |
| ** នេះមិនចង់និយាយពីរបៀបស្លាប់ ដូចជា គាំងបេះដូង ដាច់ដង្ហើមនោះទេ គឺនិយាយពីជម្ងឺ របួសឬ ផលវិបាកដែលធ្វើអោយស្លាប់* | | |

លំដាប់នៃការបំពេញនៅផ្នែក I មានដូចខាងក្រោមៈ

- បន្ទាត់ (ក) កត់ត្រាជម្ងឺ ឬ លក្ខខ័ណ្ឌ ដែលនាំផ្ទាល់ដល់ការស្លាប់
- បន្ទាត់ (ខ) កត់ត្រា ជំងឺ ឬ លក្ខខ័ណ្ឌ ផ្សេង (បើមាន) ដែលនាំ អោយកើតមាន (ក)
- បន្ទាត់ (គ) កត់ត្រា ជំងឺ ឬ លក្ខខ័ណ្ឌ ផ្សេង (បើមាន) ដែលនាំអោយកើតមាន (ខ) និង
- បន្ទាត់ (ឃ) កត់ត្រា ជំងឺ ឬ លក្ខខ័ណ្ឌ ផ្សេង (បើមាន) ដែលនាំអោយកើតមាន (គ)

**មូលហេតុផ្ទាល់នៃការស្លាប់ត្រូវបំពេញនៅលើបន្ទាត់ចុងក្រោយខ**

អ្នកបញ្ជាក់ត្រូវធ្វើយ៉ាងណាដើម្បី អោយមានលំដាប់លំដោយនៃព្រឹត្តិការណ៍ច្បាស់លាស់ នៅផ្នែក I។ បើគេមិនដឹងពីមូលហេតុនៃការស្លាប់ ទោះបីជាក្រោយពីធ្វើការស៊ើបអង្កេតហើយ គេអាចកត់ត្រាថា "មិនដឹង"។ ការនេះ ប្រសើរជាងការដាក់មូលហេតុនៃការស្លាប់ ដោយស្មានៗ។

## ៣.៣.២.២. ផ្នែក II នៃលិខិតមរណភាព

ផ្នែក II សំរាប់កត់ត្រាលក្ខខ័ណ្ឌដែលមិនមានទំនាក់ទំនងផ្ទាល់ជាមួយព្រឹត្តិការណ៍ដែលនាំដល់ការស្លាប់ ប៉ុន្តែបានរួមចំណែកដល់ការស្លាប់

## ៣.៣.២.៣. រាយការណ៍រយៈពេលនៃលក្ខខ័ណ្ឌ

រយៈពេលនៃជម្ងឺ ឬលក្ខខ័ណ្ឌ គឺជាចន្លោះរវាងការចាប់ផ្តើមនៃលក្ខខ័ណ្ឌ និមួយៗ ដែលចុះនៅក្នុងលិខិត (មិនមែនពេលដែលធ្វើរោគវិនិច្ឆ័យលក្ខខ័ណ្ឌនោះទេ) និងកាលបរិច្ឆេទស្លាប់។ គេបំពេញចន្លោះនេះ នៅជួរខាងស្តាំរបស់ជម្ងឺ ឬលក្ខខ័ណ្ឌ ។

បើមិនដឹងពីពេលចាប់ផ្តើម ឬកាលបរិច្ឆេទស្លាប់ គេត្រូវកត់ត្រារយៈពេលប៉ាន់ស្មាន។ ខ្នាតពេលវេលាត្រូវបំពេញគ្រប់ជម្ងឺទាំងអស់ ទោះបីជា :

- ឆ្នាំ
- ខែ
- ថ្ងៃ
- ម៉ោង
- នាទី
- មិនដឹង

ចំពោះលិខិតដែលបំពេញបានត្រឹមត្រូវ រយៈពេល ដែលបំពេញនៅលើបន្ទាត់និមួយៗ មិន លើសពីរយៈពេល ដែលបំពេញ នៅបន្ទាត់ខាងក្រោមឡើយ (លក្ខខ័ណ្ឌ ដែលកើតមុន) ដោយហេតុថាលំដាប់លំដោយនៃមូលហេតុ តំរូវអោយ គេកត់ត្រាលក្ខខ័ណ្ឌដែលកើតមុនទៅតាមលំដាប់ បញ្ច្រាសនឹងការកកើតរបស់វា។ នៅលើលិខិត នេះមានន័យថា គេកត់ត្រាលក្ខខ័ណ្ឌទៅតាមលំដាប់ឡើង (រូបទី៣)។ ពតិមានពី រយៈពេល មានប្រយោជន៍ សំរាប់ការដាក់កូដជម្ងឺមួយចំនួន ហើយជួយអោយគេផ្ទៀងផ្ទាត់មើល ភាពត្រឹមត្រូវនៃលំដាប់លំដោយនៃលក្ខខ័ណ្ឌ ដែលបានរាយការណ៍។

## រូបទី ៣. ទំរង់ជាអន្តរជាតិនៃលិខិតវេជ្ជសាស្ត្រ នៃមូលហេតុនៃការស្លាប់

### ទំរង់ជាអន្តរជាតិនៃលិខិតមរណភាព

| មូលហេតុនៃការស្លាប់ | | ចន្លោះពេលប្រហាក់ប្រហែល រវាងពេលចាប់ឈឺនិង ស្លាប់ |
|---|---|---|
| **I**<br>ជម្ងឺដែលនាំដល់ការស្លាប់ដោយផ្ទាល់ * | ក) - ......រលាកសួត...... (បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ......២សប្តាហ៍...... |
| **មូលហេតុកើតមុន**<br>លក្ខខ័ណ្ឌឈឺ, បើមាន, ដែលនាំអោយកើតមាននូវមូលហេតុខាងលើ, ដាក់លក្ខខ័ណ្ឌផ្ទាល់នៅក្រោយបង្អស់ | ខ) - ......ខ្វះអាហារ...... (បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ......រាប់ខែ...... |
| | គ) - ...................... (បណ្តាលមកពី ឬ ជាផលវិបាកនៃ) | ...................... |
| | ឃ) - ...................... | ...................... |
| **II**<br>លក្ខខ័ណ្ឌសំខាន់ៗ ដែលអាចរួមចំណែកដល់ការស្លាប់ តែមិនទាក់ទងនឹងជម្ងឺ ឬ លក្ខខ័ណ្ឌដែលបណ្តាលអោយស្លាប់ទេ | ......ទឹកនោមផ្អែម...... | ...................... |
| | ...................... | ...................... |
| *នេះមិនចង់និយាយពីរបៀបស្លាប់ ដូចជា គាំងបេះដូង ដាច់ដង្ហើមនោះទេ គឺនិយាយពីជម្ងឺ របួសឬ ផលវិបាកដែលធ្វើអោយស្លាប់* | | |

ក្នុងករណីនេះ កង្វះអាហារបណ្តាលអោយរលាកសួត។ រលាកសួតសម្លាប់អ្នកជម្ងឺ។ អ្នកជម្ងឺក៏មានជម្ងឺទឹកនោមផ្អែមដែរ។ ជម្ងឺទឹកនោមផ្អែមអាចរួមចំណែកដល់ការស្លាប់។ វាមិនស្ថិតនៅក្នុងលំដាប់លំដោយនៃព្រឹត្តិការណ៍ ដែលបណ្តាលអោយកើតរលាកសួតធ្ងន់ធ្ងរនេះទេ។

### ៣.៣.២.៤ "វិធានមាស" បីក្នុងការបំពេញលិខិតមរណភាព

មូលហេតុនៃការស្លាប់ដែលរាយការណ៍ក្នុងលិខិតមរណភាព ផ្តល់នូវមូលដ្ឋានសំរាប់ដាក់លេខកូដ និង ជ្រើសរើសមូលហេតុផ្ទាល់នៃការស្លាប់។ មានតរិយាបថខ្លះធ្វើអោយប៉ះពាល់ដល់ការវាយតំលៃលិខិតមរណភាព។ "វិធានមាស" នឹងជួយដោះស្រាយបញ្ហាទាំងនោះ។

១. សរសេរអោយបានច្បាស់ និង មិនត្រូវប្រើអក្សរកាត់
២. ត្រូវតែមានការបំពេញនៅលើបន្ទាត់ (ក) នៃផ្នែក I
៣. សរសេរវាល់លក្ខខ័ណ្ឌទាំងអស់តាមលំដាប់មូលហេតុ។ លក្ខខ័ណ្ឌថ្មីៗបំផុត-មូលហេតុផ្ទាល់នៃការស្លាប់-ត្រូវសរសេរនៅបន្ទាត់លើបំផុត ហើយលក្ខខ័ណ្ឌយូរបំផុត ត្រូវសរសេរនៅបន្ទាប់ក្រោមបំផុត។

## ៣.៤ រចនាសម្ព័ន្ធ និងគោលការណ៍របស់ ICD-10

ICD គឺជាទំរង់ដែលគេឯកភាពជាអន្តរជាតិ ប្រើសំរាប់ដាក់លេខកូដជម្ងឺតាមលក្ខណ:ស្តង់ដារ។ គេបានកែសំរួលវា ១០ លើកហើយចាប់តាំងពីការចាប់កំណើតរបស់វា កាលពីជាង ១០០ ឆ្នាំមកនោះ ដូច្នេះហើយបានជាច្បាប់បោះពុម្ពឥឡូវនេះ គេហៅថា **ICD-10** ។

ផ្នែកនេះនិយាយត្រួសៗ ពីប្រព័ន្ធចាត់ថ្នាក់។ លោកអ្នកមិនត្រូវរំពឹងថា លោកអ្នកនឹងក្លាយទៅជាអ្នកជំនាញបន្ទាប់ពីបានអានហើយនោះទេ។ លោកអ្នកនឹងដឹងថា តើ ICD គេរៀបចំយ៉ាងម៉េច ហើយវាមានដំណើរការយ៉ាងម៉េច។

### ៣.៤.១. និជ្ជភាពទូទៅនៃការចាត់ថ្នាក់ ICD-10

គេបែងចែកជម្ងឺនៅក្នុង ICD-10និងមូលហេតុរបស់វា ទៅតាមហេតុផលអនុវត្ត និង អេពីដេមីសាស្ត្រ ដូចខាងក្រោមនេះ:

- ជម្ងឺឆ្លង
- ជម្ងឺទូទៅ ដែលអាចប៉ះពាល់ខ្លួនប្រាណទាំងមូល
- ជម្ងឺកើតតាមកន្លែង រៀបចំទៅតាមកន្លែងរបស់វា
- ជម្ងឺពីការវិវត្តន៍
- របួស
- មូលហេតុខាងក្រៅ

ICD-10 មានបីភាគ:

**ភាគទី១. បញ្ជី**

- ភាគទី ១ ជាតារាងបញ្ជី។ វាជាការរាយឈ្មោះជម្ងឺ និង ក្រុមជម្ងឺទៅតាមលេខរៀងរ៉ូម៉ាំង។ វាមានកំណត់សំគាល់ពីវិធានក្នុងការរាប់បញ្ចូល និង មិនរាប់បញ្ចូល និងវិធានសំរាប់ដាក់លេខកូដ។
- វាមាន ២២ជំពូក និង ១១ ៤០០ ចំណាត់ថ្នាក់ ដែលគេរាប់ ដល់ ៤ តួ។ ប៉ុន្តែ មានតែចំណាត់ថ្នាក់៣តួ ចំនួន ១៦៥៥ ប៉ុណ្ណោះ ដែលអាចយកទៅប្រើបាន សំរាប់ការដាក់លេខកូដ នៃមូលហេតុតែមួយគត់នៃការស្លាប់។

**នៅចុងនៃភាគទី១ មានតារាងបញ្ជីពិសេសប្រាំ។ តារាងទាំងនេះមិនមែនធ្វើសំរាប់ដាក់លេខកូដនោះទេ គឺសំរាប់តែធ្វើជាតារាងតែប៉ុណ្ណោះ។ មិនត្រូវប្រើវាសំរាប់ដាក់លេខកូដ ឬ រាយការណ៍ទេ។ មិនត្រូវច្រឡំ បញ្ជីដែលបាននិយាយនៅទីនេះ នឹង តារាងដែលនៅខាងចុងនៃផ្នែកទី៣ នៃសៀវភៅនេះឡើយ ដែលតារាងនោះ បង្ហាញពីភាពស្របគ្នារវាងលេខកូដរបស់ ICD-10 និង លេខកូដដែលប្រើក្នុងការធ្វើកោសល្យវិច័យផ្ទាល់មាត់។**

*លំហាត់:*

*មើលបញ្ជីលេខ១ នៅក្នុង ICD-10 ហើយរកភាពខុសគ្នា ជាមួយតារាងដៃគូ នៅចុងបញ្ចប់នៃមគ្គុទេសក៍នេះ។*

**ភាគទី ២. សៀវភៅណែនាំ**

ភាគនេះនិយាយពី សេចក្តីផ្តើម និង ការណែនាំ ក្នុងការប្រើប្រាស់ ICD-10

- វាមានគោលការណ៍ណែនាំសំរាប់បញ្ជាក់ និង វិធានក្នុងការដាក់លេខកូដមរណភាព (គឺដាក់លេខកូដមូលហេតុនៃការស្លាប់)
- វាមាន គោលការណ៍ណែនាំសំរាប់កត់ត្រា និង ដាក់លេខកូដ ជម្ងឺ (ឧទាហរណ៍ ស្ថិតិមន្ទីរពេទ្យ)
- វាក៏មានគោលការណ៍ណែនាំ សំរាប់ធ្វើជាតារាង នូវទិន្នន័យស្ថិតិ និង និយមន័យ (ឧទាហរណ៍ សំរាប់ "ជុំវិញកំណើត")

**ភាគទី ៣. លិបិក្រម និង មគ្គុទេសក៍**

- នេះជាលិបិក្រមរៀបតាមតួអក្ខរក្រម នូវជម្ងឺ និង លក្ខខ័ណដែលមាននៅក្នុង តារាងបញ្ជី
- វាមានតារាងណេអូប្លាសមួយ
- មានតារាងថ្នាំ និង ជាតិគីមីមួយដែរ
- មានតារាងមូលហេតុខាងក្រៅ
- មានមគ្គុទេសក៍ក្នុងការជ្រើសរើសកូដត្រឹមត្រូវសំរាប់លក្ខខ័ណ្ឌជាច្រើនដែលមិនមាននៅក្នុងតារាងបញ្ជី

**ភាគ១ និងភាគ៣ មិនអាច ដាច់គ្នាបានឡើយ។** ភាគ១ និងភាគ៣ ត្រូវតែប្រើជាមួយគ្នា ដើម្បី រកលេខកូដសំរាប់ករណីនិមួយៗ អោយបានត្រឹមត្រូវ (ឧទាហរណ៍ មូលហេតុនៃការស្លាប់)។

## ៣.៤.២. តារាងបញ្ជី

ICD-10 មាន ២២ជំពូក ហើយជំពូកនិមួយៗកំណត់ដោយលេខរ៉ូម៉ាំងមួយ។ ជំពូក XIX (របួស ការពុល និងផលវិបាកផ្សេងៗទៀតនៃមូលហេតុខាងក្រៅ) និងជំពូក XXI (កត្តាដែលមានឥទ្ធិពលលើស្ថានភាពសុខភាព និងការទៅជួបជាមួយនឹងសេវាសុខភាព) មិនប្រើសំរាប់ដាក់កូដចំពោះមូលហេតុផ្ទាល់នៃការស្លាប់ទេ។

បញ្ជីពេញលេញនៃជំពូកទាំងនេះ មាននៅខាងក្រោម៖

| ជំពូក | ចំណងជើង | តំណាងកូដ នៅក្នុងជំពូកទាំងមូល |
|---|---|---|
| I | ជំងឺឆ្លង និង ជំងឺប៉ារ៉ាស៊ីត មួយចំនួន | A00-B99 |
| II | ដុំដុះមិនធម្មតា | C00-D48 |
| III | ជំងឺឈាម និងសរីរាង្គបង្កើតឈាម និងភាពមិនប្រក្រតីមួយចំនួនដែលទាក់ទងនឹងយន្តការនៃភាពស៊ាំ | D50-D89 |
| IV | ជំងឺក្រពេញអង់ដូគ្រីន អាហារូបត្ថម្ភ និងការរំលាយអាហារក្នុងរាងកាយ | E00-E99 |
| V | ភាពមិនប្រក្រតីខាងផ្លូវចិត្ត និង ការប្រព្រឹត្តិ | F00-F99 |
| VI | ជំងឺប្រពន្ធ័សរសៃប្រសាទ | G00-G99 |
| VII | ជំងឺភ្នែក និង កន្សោមប្រពន្ធ័ភ្នែក | H00-H59 |
| VIII | ជំងឺត្រចៀក និង ឆ្អឹងត្រចៀកខាងក្នុង | H60-H95 |
| IX | ជំងឺប្រពន្ធ័សរសៃឈាម | I00-I99 |
| X | ជំងឺប្រពន្ធ័ដង្ហើម | J00-J99 |
| XI | ជំងឺប្រពន្ធ័រំលាយអាហារ | K00-K93 |
| XII | ជំងឺស្បែក និងជាលិកាក្រោមស្បែក | L00-L99 |
| XIII | ជំងឺប្រពន្ធ័សាច់ដុំនិងឆ្អឹង និងសរសៃពួរ | M00-M99 |
| XIV | ជំងឺប្រពន្ធ័បន្តពូជ-ទឹកនោម | N00-N99 |
| XV | ផ្ទៃពោះ សំរាល និង ក្រោយសំរាល | O00-O99 |
| XVI | លក្ខ័ខណ្ឌ័មួយចំនួនមានប្រភពជុំវិញកំណើត | P00-P96 |
| XVII | ពិការភាពពីកំណើត ខូចរូបរាង និងភាពមិនធម្មតានៃក្រូម៉ូសូម | Q00-Q99 |
| XVIII | បណ្តុំរោគសញ្ញា រោគសញ្ញា និងគំហើញមិនធម្មតានៃសញ្ញាគ្លីនិក និងមន្ទីរពិសោធន៍ មិនចាត់នៅកន្លែងដទៃ | R00-R99 |
| XIX | របួស ការពុល និងផលវិបាកផ្សេងៗទៀត នៃមូលហេតុខាងក្រៅ | S00-T99 |
| XX | ជំងឺនិងស្លាប់ដោយមូលហេតុខាងក្រៅ | V01-Y98 |
| XXI | កត្តាដែលមានឥទ្ធិពលលើស្ថានភាពសុខភាព និងការទៅជួបជាមួយនឹងសេវាសុខភាព | Z00-Z99 |
| XXII | កូដសំរាប់គោលបំណងពិសេសៗ | U00-U99[a] |
| a មានតែផ្នែកខ្លះតែប៉ុណ្ណោះនៅក្នុងជំពូកនេះដែលគេប្រើសំរាប់ដាក់កូដនៃការស្លាប់ ។ | | |

### ៣.៤.២.១ បណ្តុំនៃលក្ខខណ្ឌទាក់ទងនៅក្នុង ICD-10

ជំពូកនិមួយៗចែកចេញជាបណ្តុំនៃលក្ខខណ្ឌទាក់ទង។ បណ្តុំទាំងនោះចែកចេញជា ប្រភេទ ៣-លក្ខណៈ និង ៤-លក្ខណៈ។ ឧទាហរណ៍:

ឧទាហរណ៍នៃបណ្តុំមួយនៅក្នុងជំពូក១

ជំងឺរលាកថ្លើមដោយវីរុស (B15-B19)

B15 ជំងឺរលាកថ្លើមដោយវីរុសស្រួចស្រាវប្រភេទ A

B16 ជំងឺរលាកថ្លើមដោយវីរុសស្រួចស្រាវប្រភេទ B

B17 ជំងឺរលាកថ្លើមដោយវីរុសស្រួចស្រាវដ៏ទៃទៀត

B18 ជំងឺរលាកថ្លើមដោយវីរុសរ៉ាំរ៉ៃ

B19 ជំងឺរលាកថ្លើមដោយវីរុសដែលមិនកំណត់បាន

### ៣.៤.២.២ ប្រភេទ៣-លក្ខណៈ

ប្រភេទ ៣-លក្ខណៈ ខ្លះ ប្រើសំរាប់តែលក្ខខណ្ឌទោលៗតែប៉ុណ្ណោះ។ ហើយផ្សេងទៀតសំរាប់ក្រុមជំងឺនានា។ ឧទារហណ៍:

ប្រភេទ ៣-លក្ខណៈជាមួយនឹងជំងឺទោល

**A 71** ជំងឺភ្នែកឡើងបាយ (Trachoma)

មិនរាប់ចូល: សំណល់របស់ជំងឺភ្នែកឡើងបាយទេ (B94.0)

ប្រភេទ ៣-លក្ខណៈជាមួយនឹងក្រុមជំងឺ

**A 75** ក្រុមជំងឺគ្រុនក្តៅបែប Typhus (គ្រុនក្តៅ ឆ្លង កន្ទួលស្បែក ឈឺក្បាលខ្លាំង ហើយជាទូទៅរវើរវាយ)

មិនរាប់ចូល: ជំងឺឆ្លងជាមួយនឹងមេរោគ Rickettsiae ដែលបណ្តាលឡើងដោយពួក Ehrlichia sennetsu ទេ (A79.8)

**A75.0** ការរាតត្បាតដែលចំលងដោយចៃនៃជំងឺគ្រុនពោះវៀនដែលបណ្តាលឡើងដោយពួក Rickettsia prowazekii

គំរូជំងឺដោយពួក Typhus (គ្រុន)

ការរាតត្បាត (ចំលងដោយចៃ) ជំងឺដោយពួក Typhus

**A75.1** ការឈឺធ្ងន់ឡើងវិញនៃជំងឺគ្រុនក្តៅ [Brill's disease]

ជំងឺ Brill-Zinsser

**A75.2** ជំងឺគ្រុនក្តៅបណ្តាលមកពីពួក Rickettsia typhi

ជំងឺគ្រុនក្តៅដែលទាក់ទងនឹងកណ្តុរ (ចំលងដោយចៃ) Murine typhus

**A75.3** ជំងឺគ្រុនក្ដៅបណ្ដាលមកពីពួក Rickettsia tsutsugamushi

Scrub (ចំលងដោយពពួកសត្វល្អិត) Typhus

គ្រុនក្ដៅ Tsutsugamushi

**A75.9** ជំងឺគ្រុនក្ដៅបែប Typhus ដែលមិនអាចកំណត់បាន

Typhus (fever) NOS

## ៣.៤.២.៣ ប្រភេទ ៤-លក្ខណៈ ឬចំណាត់ថ្នាក់ក្រុមមុខអក្សរពិសេស

ប្រភេទ ៤-លក្ខណៈទាំងនេះ មិនមានបទបញ្ជាសំរាប់អោយរាយការណ៏ នៅថ្នាក់អន្តរជាតិឡើយ តែគេប្រើលក្ខណៈទី៤បន្ថែមពត៌មានលំអិត និងបញ្ជាក់ទៅលើទិន្នន័យដែលដាក់កូដរួចហើយ ។ ការប្រើប្រាស់លក្ខណៈទី៤ អាចអោយគេមានអនុ-ប្រភេទប្រហែលជា ១០ ទៀត ។

ឧទាហរណ៏:

**A 01** ជំងឺគ្រុនពោះវៀន និងគ្រុនក្ដៅទាំងអស់ដែលបណ្ដាលមកពីមេរោគគ្រុនពោះវៀន (Typhoid and paratyphoid fevers)

**A01.0** ជំងឺគ្រុនពោះវៀន

ការបង្ករោគដែលបណ្ដាលមកពី Salmonella typhi

**A01.1** ជំងឺគ្រុនក្ដៅដែលបណ្ដាលមកពីមេរោគគ្រុនពោះវៀន ប្រភេទ A

**A01.2** ជំងឺគ្រុនក្ដៅដែលបណ្ដាលមកពីមេរោគគ្រុនពោះវៀន ប្រភេទ B

**A01.3** ជំងឺគ្រុនក្ដៅដែលបណ្ដាលមកពីមេរោគគ្រុនពោះវៀន ប្រភេទ C

**A01.4** ជំងឺគ្រុនក្ដៅដែលបណ្ដាលមកពីមេរោគគ្រុនពោះវៀន ដែលមិនអាចបញ្ជាក់បាន

ការបង្ករោគដែលបណ្ដាលមកពី Salmonella typhi NOS

} **ប្រភេទ ៤-លក្ខណៈ**

## ៣.៤.២.៤ រចនាសម្ពន្ធ័ ខ្លឹមសារ

ជំពូកភាគច្រើនមានទំនាក់ទំនងជាមួយនឹងប្រពន្ធ័នានានៃរាងកាយ ជំងឺពិសេសៗ និងកត្តាខាងក្រៅនានា ។

ជំពូកអំពីជំងឺពិសេសៗមានរួមបញ្ចូលលក្ខ័ខណ្ឌ័ដែលមិនមាននៅក្នុងជំពូកប្រពន្ធ័រាងកាយ បើទោះជាវាអាចមានវត្តមាននៅជំពូកប្រពន្ធ័រាងកាយនោះក៏ដោយ ។ លក្ខ័ខណ្ឌ័នានាដែលបានដាក់កូដនៅក្នុងជំពូកជំងឺពិសេស មានអាទិភាពលើលក្ខ័ខណ្ឌ័នានា ដែលគេដាក់កូដនៅក្នុងជំពូកប្រពន្ធ័រាងកាយ ។

លំហាត់:

ចូរមើលចំណងជើងជំពូកនៅក្នុង ICD-10 ។ ចំណងជើងជំពូកបញ្ជាក់ពីលក្ខ័ខណ្ឌ័ដែលមាន គឺមានភាពទូលំទូលាយណាស់ ។ ដូចនេះតំរូវអោយមានកូដមួយចំនួនធំ ដើម្បីគ្របដណ្ដប់រាល់លក្ខ័ខណ្ឌ័ទាំងអស់ ។

## ពាក្យរាប់បញ្ចូល

នៅក្នុងចំណងជើងរបស់ ប្រភេទ ៣-លក្ខណៈនិង ៤-លក្ខណៈ មានរាយនូវពាក្យរោគវិនិច្ឆ័យដ៏ទៃទៀតមួយចំនួន បន្ថែមទៅលើចំណងជើងកូដ។ ពាក្យទាំងនេះត្រូវគេស្គាល់ថា "ពាក្យរាប់បញ្ចូល " ហើយប្រើធ្វើជាឧទាហរណ៍នៃប្រយោគរោគវិនិច្ឆ័យ សំរាប់ចាត់ថ្នាក់ទៅក្នុងចំណងជើងនោះ។ ជាលក្ខណៈសំខាន់ វាបាន ឆ្លុះបញ្ចាំងនូវជំងឺប្រហាក់ប្រហែលគ្នានានាដែលអាចនឹង ត្រូវតែ ដាក់កូដទៅក្នុងប្រភេទតែមួយ ឬពាក្យនិងលក្ខខណ្ឌខុសគ្នា ដែលគេប្រើ សំរាប់ពិពណ៌នាជំងឺតែមួយ។

ឧទាហរណ៍:

A06 ជំងឺដោយពួកអាមីប (Amoebiasis)

រាប់បញ្ចូលទាំងការបង្ករោគដោយ Entanoeba histolytica

ប្រភេទ A06 ត្រូវចែកជាអនុក្រុម(ផ្នែកតូចៗ)ទៀត ហើយរាល់លក្ខខណ្ឌនិងការចាត់បញ្ចូលនៅក្នុងអនុក្រុមទាំងនេះ អាចនឹងដាក់កូដជា A06 ដែរ។ នេះគឺជាមូលហេតុ ដែលជានិច្ចជាកាលអ្នកនឹងត្រូវការ ICD-10 និង រាល់ផ្នែកតូចៗរបស់វា (បណ្តុំ ប្រភេទ) ដើម្បីដាក់កូដយ៉ាង ហ្មត់ចត់: លក្ខណៈទី៤ផ្តល់នូវភាពជាក់លាក់ដ៏មានប្រយោជន៍បន្ថែម។

លំហាត់:

ចូររកមើលនៅក្នុងអនុក្រុមរបស់ A06 នៅក្នុង ICD-10និង មើលថាតើមានអ្វីទៀតដែលត្រូវបញ្ចូលទៅក្នុងប្រភេទនេះ។

## ពាក្យមិនរាប់បញ្ចូល

ចំណងជើងខ្លះមានបញ្ជីនៃលក្ខខណ្ឌដែលនាំមុខដោយពាក្យ "មិនរាប់បញ្ចូល"។ នេះមានន័យថា ពាក្យដែលមិនរាប់បញ្ចូល ត្រូវគេដាក់កូដនៅកន្លែងផ្សេង។ កូដត្រឹមត្រូវដែលគួរប្រើ ត្រូវបានដាក់នៅក្នុងរង្វង់ក្រចកនៅបន្ទាប់នឹងពាក្យនោះ។

ឧទារហណ៏:

ប្រភេទ A06 ជំងឺដោយពួកអាមីប (Amoebiasis) មិនរាប់ចូលជំងឺពោះវៀនដោយពួកប្រូតូសូអ៊ែរផ្សេងៗទៀត ដែលមានលើកឡើងនៅក្នុង A07 ឡើយ ដូចជា តេនញ៉ា (giardiasis)និង ដង្កូវព្រូន (ascariasis)(ជំងឺដង្កូវមូល)។

ប្រសិនបើមានពាក្យដែលមិនរាប់បញ្ចូលនៅក្នុងអនុក្រុមរបស់ A06 ការមិនរាប់ចូលនេះគួរតែមានប្រសិទ្ធភាពផងដែរសំរាប់ A06។ ចូរកត់សំគាល់ថាការមិនរាប់បញ្ចូលនេះក៏មានផងដែរនៅក្នុងថ្នាក់ជំពូក និង ថ្នាក់បណ្តុំ ហើយការមិនរាប់បញ្ចូលនេះគឺត្រូវនឹងកូដ នៅកំរិតប្រភេទ ៣-លក្ខណៈ និង ៤-លក្ខណៈ។

លំហាត់:

ចូររកមើល A06 និង A04។ ចូរកំណត់ពាក្យមិនរាប់បញ្ចូលនានា។

### ៣.៤.២.៥ អនុសញ្ញានានានៃ ICD-10

បញ្ជីតារាង ICD-10 (ភាគទី ១) និងលិបិក្រមតាមលំដាប់តួអក្សរ (ភាគទី៣) មានប្រើអក្សរកាត់ សញ្ញាវណ្ណយុត្តិ និមិត្តសញ្ញា និង ពាក្យណែនាំ ដែលត្រូវតែអោយមានការយល់ច្បាស់លាស់។ ទាំងអស់នេះគេហៅថា "អនុសញ្ញានៃការដាក់កូដ"។

**កូដសញ្ញាខ្វែង (†) និងសញ្ញាផ្កាយ (*)**

សញ្ញាខ្វែង(†)និង ផ្កាយ(*) គេមិនប្រើទេនៅពេលដាក់កូដមូលហេតុទោលនៃការស្លាប់។ កូដសញ្ញាខ្វែង តំណាង អោយមូលហេតុជំងឺ ហើយត្រូវតែប្រើ នៅពេលណាដែលអាចប្រើបាន។ កូដរូបផ្កាយ គេប្រើសំរាប់ពិពណ៌នា នូវការស្តែង ឡើងនៃជំងឺ ប្រសិនបើចាំបាច់។ គេមិនប្រើកូដរូបផ្កាយសំរាប់ដាក់កូដមូលហេតុផ្ទាល់នៃការស្លាប់ នៅក្នុងកោសល្យវិច័យផ្ទាល់មាត់ ឡើយ។

ឧទាហរណ៍

**B57.0 (†) ជំងឺ Chagas' ស្រួចស្រាវដោយមានពាក់ពន្ធ័នឹងបេះដូង (I41.2*, I98.1*)**

ជំងឺ Chagas' ស្រួចស្រាវ ជាមួយនឹង:

- ការទាក់ទងបេះដូងសរសៃឈាម NEC (I98.1*)
- រលាកស្រោមបេះដូង (I41.2*)

នៅក្នុងឧទាហរណ៍នេះមានរូប(†) នៅក្បែរនឹង B57.0។ កូដជាមួយនឹង *ត្រូវគេផ្តល់អោយនៅក្នុងរង្វង់ក្រចក។ នៅក្នុងកោសល្យវិច័យផ្ទាល់មាត់ អ្នកអាចដាក់កូដ B57.0 ហើយបំភ្លេចកូដផ្កាយ។

**មិនមានបញ្ជាក់ផ្សេងទៀត**

NOS គឺជាអក្សរកាត់ សំរាប់ "not otherwise specified" (មិនមានបញ្ជាក់ផ្សេងទៀត)។ វាមានន័យថា មូលហេតុមិន អាច "បញ្ជាក់បាន" ឬ "មិនមានគុណវឌ្ឍ"។ អ្នកដាក់កូដ គួរប្រយត្ន័ប្រយែង ដោយ មិនដាក់កូដ មិនមានគុណវឌ្ឍ ដ៏រាបណាវាច្បាស់ ថាមិនមានពត៌មានដែលអាចបញ្ជាក់ពីកូដដែលដាក់លាក់ជាងនេះ ក្នុងការចាត់ ពីប្រភពដ៏ទៃនៃចំណាត់ថ្នាក់។

ឧទាហរណ៍:

B50.0 ជំងឺគ្រុនចាញ់ដោយប្លាស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម ជាមួយនឹងផលវិបាកខួរក្បាល
ជំងឺគ្រុនចាញ់ខួរក្បាល NOS

## មិនមានបញ្ជាក់នៅកន្លែងផ្សេង

NEC ស្តង់ដារសំរាប់ "Not elsewhere classified មិនមានបញ្ជាក់នៅកន្លែងផ្សេង "។ អក្សរកាត់នេះប្រើសំរាប់ជាការព្រមាន ថាប្រភេទមួយចំនួនដែលគេបញ្ជាក់ហើយ អាចនឹងឃើញមាននៅផ្នែកដ៏ទៃនៃចំណាត់ថ្នាក់។

ឧទាហរណ៍:

**K73 ជំងឺរលាកថ្លើមរ៉ាំរ៉ៃ មិនមានបញ្ជាក់នៅកន្លែងផ្សេង**

" មិនមានបញ្ជាក់នៅកន្លែងផ្សេង " បរិយាយនៅទីនេះ ដោយហេតុថាមានប្រភេទផ្សេងទៀត នៅក្នុង ICD-10សំរាប់បញ្ជាក់ពីជំងឺរលាកថ្លើមរ៉ាំរ៉ៃ ឧទាហរណ៍ នៅក្នុងជំពូក I:

B18 ជំងឺរលាកថ្លើមរ៉ាំរ៉ៃដោយវីរុស

## អនុសញ្ញាផ្សេងៗទៀត

**មានភាពខុសគ្នារវាង រង្វង់ក្រចក"()" និង ខ្នៀបជ្រុង"[]" ។**

**រង្វង់ក្រចក**ក្តោបពាក្យបំពេញបន្ថែម ដែលអាចនឹងបន្តពីពាក្យរោគវិនិច្ឆ័យ ដោយមិនមានប្តូរផ្លាស់លេខកូដ ដែលត្រូវដាក់អោយពាក្យដែលនៅខាងក្រៅរង្វង់ក្រចក។

ឧទាហរណ៍:

G11.1 ការចាប់មានយ៉ាងលឿននូវភាពវិកលខួរក្បាល
ភាពវិកល Friedrich's (autosomal recessive)
ប្រមេះ (ស្រួចស្រាវ) (រ៉ាំរ៉ៃ) A54.9

**ខ្នៀបជ្រុង**ក្តោបសទិសន័យ ពាក្យជំនួស ឬឃ្លាពន្យល់។

ឧទាហរណ៍:

A77 គ្រុនក្តៅដោយមានស្នាមអុចៗ [ជំងឺ Rickettsioses ដែលចំលងដោយពួកចៃ]
B02 Zoster [herpes zoster]

**នៅពេលដែល" និង" ត្រូវប្រើនៅក្នុងកូដចំណងជើង នៅក្នុងភាគទី១ វាមានន័យថា"និង/ឬ"។**

ឧទាហរណ៍:

A18.4 ជំងឺរបេងស្បែក និង ជាលិកាក្រោមស្បែក
នៅក្នុងករណីនេះ "ជំងឺរបេងស្បែក" **និង** "ជំងឺរបេងជាលិកាក្រោមស្បែក " **និង** "ជំងឺរបេងស្បែកនិងជាលិកាក្រោមស្បែក" អាចនឹងកូដ ទៅលេខ A18.4

ភាពមិនប្រក្រតីកើតក្រោយនិតិវិធី (Postprocedural) ខ្លះ មិនគួរប្រើសំរាប់ដាក់កូដមូលហេតុផ្ទាល់នៃការស្លាប់នោះទេ។ ពួកវាមាន E89.- G97.- H59.- H95.- I97.- J95.- K91.- M96.- N99.-
លំហាត់:
ចូរមើលទៅលើ ភាពមិនប្រក្រតីកើតនិតិវិធី ដែលរាយខាងលើ និង មើលថាអ្វីខ្លះដែលកូដបានគ្របដណ្តប់។

## ៣.៤.៣. លិបិក្រមតាមលំដាប់តួអក្សរ

**លិបិក្រមតាមលំដាប់តួអក្សរ មានពាក្យរោគវិនិច្ឆ័យច្រើនជាង បញ្ជីតារាង។**

ភាគទី៣ គឺជាលិបិក្រមតាមលំដាប់តួអក្សរ នៃបញ្ជីតារាងដែលឃើញនៅក្នុងភាគទី១។ វាមានពាក្យរោគវិនិច្ឆ័យច្រើនជាងបញ្ជីតារាងឆ្ងាយ ដែលឆ្លុះបញ្ចាំងនូវរបៀបជាច្រើន និងផ្សេងៗគ្នាដែលវេជ្ជបណ្ឌិត និងបុគ្គលិកគ្លីនិកពិពណ៌នាពីជំងឺ។

ដោយប្រើលិបិក្រម អ្នកដាក់កូដអាចរកឃើញកូដដែលគេអោយប្រើ ពីបណ្តាពាក្យអាចជំនួសបាន។ ដូច្នេះអ្នកដាក់កូដត្រូវតែកមើលកូដនោះដោយផ្ទៀងនឹងបញ្ជីតារាង ដើម្បីធានាថាមិនមានការកត់សំគាល់ដែលពាក់ពន្ធ័ ឬអនុសញ្ញាផ្សេងៗ ដែលអាចនឹងផ្លាស់ប្តូរការសំរេចចិត្តក្នុងការដាក់កូដ។

**ភាគទី១ និងទី៣ ត្រូវតែប្រើជាមួយគ្នា** ដើម្បីរកកូដដើម្បីពិពណ៌នាភាពត្រឹមត្រូវករណីគ្លីនិកនិមួយៗ។
**អ្នកដាក់កូដមិនត្រូវធ្លាក់ទៅក្នុងអន្ទាក់ក្នុងការដាក់កូដ ភ្លាមៗពីលិបិក្រមតាមតួអក្សរឡើយ ឬ មើលទៅលើបញ្ជីតារាង ដើម្បីរកមើលកូដដែលដូចជាត្រូវនឹងករណីដែលកំពុងតែធ្វើការវាយតំលៃនេះឡើយ។**

- ផ្នែក I គឺជាការរាយបញ្ជីតាមតួអក្សរនូវពាក្យដែលទាក់ទងនឹងជំងឺ។ វាក៏បញ្ចូលផងដែរនូវតារាងនៃដុំមិនធម្មតា។
- ផ្នែក II គឺជាការរាយបញ្ជីតួអក្សរនូវពាក្យ នៃមូលហេតុខាងក្រៅនៃរបួសនិងការពុល
- ផ្នែក III គឺជារៀបចំតាមលំដាប់តួអក្សរ នូវតារាងថ្នាំ និង ជាតិគីមី។

### ៣.៤.៣.១ ការបញ្ចូលលិបិក្រម

ការបញ្ចូលលិបិក្រមមាន ពាក្យនាំមុខ និង ពាក្យកែប្រែ។

**ពាក្យនាំមុខ** (ជាទូទៅជានាម) លេចឡើងនៅចុងខាងឆ្វេងនៃបន្ទាត់បញ្ឈរ ក្នុងពណ៌ខ្មៅក្រាស់។ វាយោងជាសំខាន់ទៅឈ្មោះជំងឺនានានិងលក្ខខណ្ឌនានា។ វាពណ៌នាពីលក្ខខណ្ឌជំងឺបច្ចុប្បន្នរបស់អ្នកជំងឺ ឬហេតុផលក្នុងការស្វែងរកការថែទាំវេជ្ជសាស្រ្ត។

**ពាក្យកែប្រែ** ឃើញមាននៅថ្នាក់ផ្សេងៗនៃអត្តសញ្ញាណនៅខាងស្តាំ។ ជាទូទៅវាយោងទៅភាពផ្សេងៗរបស់ជំងឺ ឬមូលហេតុខាងក្រៅនៃការស្លាប់ ដែលមានឥទ្ធិពលលើការដាក់កូដ។ ពាក្យកែប្រែអាចកំណត់នូវអត្តសញ្ញាណទីកន្លែងរបស់ជំងឺបញ្ហា ឬការជួបប្រទះ។ ពាក្យកែប្រែមិនចាំបាច់ប្រើនៅរាល់ការថ្លែងឡើយ។ ពាក្យកែប្រែមិនមានឥទ្ធិពលទៅលើការចាត់កូដដែលមាននៅក្នុង រង្វង់ក្រចក () នៅខាងក្រោយជំងឺឡើយ។

ឧទាហរណ៏:

| ពាក្យលិបិក្រម | ពាក្យនាំមុខ | ពាក្យកែប្រែ |
|---|---|---|
| **បាក់**ឆ្អឹងខ្នង | បាក់ | បាក់ឆ្អឹងខ្នង (ទីកន្លែងបាក់) |
| រលាកត្រចៀកកណ្តាលស្រួចស្រាវ | រលាកត្រចៀក | រលាកត្រចៀកស្រួចស្រាវ (តំណាក់កាលជំងឺ) កណ្តាល (ទីកន្លែងនៃជំងឺ) |
| **ការបង្ករោគ**នៅប្រពន្ធ័ដកដង្ហើមផ្នែកខាងលើ | ការបង្ករោគ | ការបង្ករោគផ្នែកខាងលើ (កន្លែង) ដង្ហើម (ប្រពន្ធ័ដែលមានជំងឺ) |
| **ជំងឺគ្រុនចាញ់** ទឹកខ្មៅ | គ្រុនចាញ់ | ទឹកខ្មៅ (ប្រភេទនៃជំងឺ) |
| **ជំងឺគ្រុនចាញ់**ពីកំណើត | គ្រុនចាញ់ | ពីកំណើត (ប្រភេទនៃជំងឺ) |
| **ប្រមេះ**ស្រួចស្រាវ កស្បូន | ប្រមេះ | ប្រមេះស្រួចស្រាវ (តំណាក់កាលជំងឺ) កស្បូន (កន្លែង) |
| **ស្ទះកំណកលោហិត**មានមេរោគ | ស្ទះកំណកលោហិត | ស្ទះកំណកលោហិតមានមេរោគ (លក្ខណះរបស់ជំងឺ) |
| សំគាល់: នៅក្នុងលិបិក្រម ជាញឹកញាប់មានការបញ្ចូលជាច្រើន នៅថ្នាក់និមួយៗនៃការកំណត់អត្តសញ្ញាណ។ ចាំបាច់ គេត្រូវតែប្រុងប្រយត្ន័ នៅពេលដែលតាម ដាននៃការបញ្ចូលដែលត្រូវ សំរាប់រោគវិនិច្ឆ័យស្ថិតក្រោមពាក្យនាំមុខនិមួយៗ។ | | |

ឧទាហរណ៏:

គំរូលិបិក្រម

ភាពរសាបរសល់ R53

ភ្នាសស្តើងៗជាប់សរីរាង្គប្រហោងនានា (Malakoplakia) (ចូរមើលនៅក្នុង Malacoplakia)

គ្រុនចាញ់ (គ្រុនក្តៅ) គ្រុនចាញ់ B54

- ជាមួយ

-- គ្រុនក្តៅមានដុះឈាម (Blackwater fever) B50.8

--- ដែលមានជាតិអេម៉ូគ្លូប៊ីនក្នុងទឹកនោម (ជាតិទឹកប្រម៉ាត់) B50.8

-- នោមមកនូវជាតិអេម៉ូគ្លូប៊ីន B50.8

- រលូតដោយដៃដន្យ (ដោយការព្យាបាល) - ចូរមើលទៅក្នុងជំងឺគ្រុនចាញ់តាមប្រភេទ

- ញាក់ B50.9

- ដែលប៉ះពាល់ដល់ខួរក្បាល B50.0† G94.8*

- ដែលធ្វើរោគវិនិច្ឆ័យដោយរោគសញ្ញា (ដោយមិនមានការបញ្ជាក់ប៉ារ៉ាសិត) B54

- ផ្ទៃពោះដែលមានផលវិបាក ការសំរាល ឬ ក្រោយការសំរាល O98.6

- ជំងឺពីកំណើតដែលមិនមានកំណត់នៅកន្លែងដ៏ទៃ P37.4

- ហ្វាល់ស៊ីប៉ារុម P37.3

- បន្ត ជាប់(គ្រុនក្តៅ) B50.9

- តំណាក់កាលដេកក្នុងសរទរដូវ (Estivo-autumnal) B50.9

- ហ្វាល់ស៊ីប៉ារុម B50.9

-- ដោយមានផលវិបាក ដែលមិនមានកំណត់នៅកន្លែងដ៏ទៃ B50.8

--- ដែលប៉ះពាល់ដល់ខួរក្បាល B50.0† G94.8*

-- ធ្ងន់ធ្ងរ B50.8

- ពួកម៉ាឡារីយ៉ា (ដោយ) B52.9

លំហាត់:

ចូរមើលទៅលើ "ជំងឺពណ៌ទាក់ទងនឹងគ្រាប់ឈាមក្រហម ជាមួយនឹងភាពស្លេកស្លាំងដែលពិបាកនឹងបំបាត់" (Haemochromatosis with refractory anaemia)
ចូរមើលទៅលើ "មហារីកដោះ"

ចូរមើលទៅលើ " គ្រោះថ្នាក់រថយន្ត"

តើអ្នកចាំដែរឬទេ ថា ដង្កៀបជ្រុង មានន័យដូចម្តេច?

តើអ្នកធ្វើអ្វីជាមួយនឹង † ឬ * ក្នុងការដាក់កូដមរណៈភាព?

## ៣.៤.៤ ជ្រើសរើសមូលហេតុផ្ទាល់នៃការស្លាប់

នៅពេលដែលមូលហេតុស្លាប់ត្រូវបានគេចាត់ និងរាយការណ៍នៅលើទំរង់អន្តរជាតិនៃលិខិតបញ្ជាក់វេជ្ជសាស្ត្រដោយគ្រូពេទ្យ ចំពោះមូលហេតុស្លាប់ លិខិតបញ្ជាក់ត្រូវតែពិនិត្យសុពលភាព។ ជាបឋម លំដាប់នៃព្រឹត្តិការណ៍ដែលនាំទៅរកការស្លាប់ ត្រូវតែត្រឹមត្រូវ។ "លំដាប់ " គឺយោងទៅលើលក្ខ័ខណ្ឌ័ពីរឬច្រើន ដែលបញ្ចូលនៅលើបន្ទាត់ជាបន្តបន្ទាប់។ លក្ខ័ខណ្ឌ័និមួយៗគឺជាមូលហេតុដែលអាចទទួលយកបានមួយ នៃមូលហេតុមួយដែលបញ្ចូលនៅលើបន្ទាត់ខាងលើវា។

- នៅពេលដែលមានមូលហេតុតែមួយនៃការស្លាប់ត្រូវគេកត់ត្រា មូលហេតុនេះគឺជាមូលហេតុផ្ទាល់នៃការស្លាប់ ហើយត្រូវប្រើសំរាប់ធ្វើតារាង។
- នៅពេលដែលមូលហេតុច្រើនជាងមួយ ត្រូវគេកត់ត្រា ការជ្រើសរើសមូលហេតុផ្ទាល់នៃការស្លាប់ គួរត្រូវធ្វើឡើងស្របតាមវិធាន ដែលសង្ខេបនៅក្នុងជំពូកនេះ។

**ការរៀបចំនិតិវិធី**-ការជ្រើសរើសចាប់ផ្តើមជាមួយនឹង "គោលការណ៍ទូទៅ " និង សំណុំនៃវិធានបឋមមួយ។ មូលហេតុស្លាប់ដែលបានជ្រើសរើសហើយ អាចនឹងកែតំរូវដោយវិធានទីពីរ។
សៀវភៅនេះផ្តល់នូវសេចក្តីសរុបយ៉ាងសង្ខេបអំពីវិធានទាំងនេះ។ នៅក្នុងករណីដ៏កំរ នៅពេលដែលអ្នកត្រូវការយោងទៅ វិធាននេះក្នុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ អ្នកអាចមើលទៅលើផ្នែកទី ៤.១ និង ៤.២ នៃភាគទី២។ ផ្នែកទាំងនេះមានការពន្យល់ លំអិតនិងឧទាហរណ៍ជាច្រើន។

**ភាពអាចប្រៀបធៀបបាន**- វិធានទាំងនេះធានាថា ការជ្រើសរើសត្រូវបានធ្វើឡើងតាមរបៀបតែមួយនៅគ្រប់ទីកន្លែង ហើយមិនអាស្រយ័លើគំនិតរបស់បុគ្គលឡើយ។ ការនេះនឹងធ្វើអោយលទ្ធផលអាចប្រៀបធៀបបាន។
វិធានជ្រើសរើសនានាគឺចង់កែនូវរាល់កំហុសដែលអ្នកចាត់ថ្នាក់អាចនឹងធ្វើឡើងនៅពេលបំពេញលិខិតមរណៈភាព។

### ៣.៤.៤.១ គោលការណ៍ទូទៅ

នៅពេលដែលមានជំងឺលើសពីមួយត្រូវគេបញ្ចូលទៅលើលិខិតបញ្ជាក់ ជំងឺដែលគេបញ្ចូលតែឯងនៅលើបន្ទាត់ក្រោយបង្អស់ ដែលគេប្រើក្នុងផ្នែកទី I គួរតែត្រូវបានគេជ្រើសរើស តែ នៅក្នុងតែករណីដែល វានាំអោយកើត **ជំងឺទាំងអស់ដែលគេបានបញ្ចូលនៅពីលើវាតែប៉ុណ្ណោះ**។

ឧទាហរណ៍:

I(a) បូសសួត

I(b) រលាកសួត

ចូរជ្រើសរើសយករលាកក្លែបសួត (J18.1) ជាមូលហេតុផ្ទាល់នៃការស្លាប់ ដោយហេតុថាបូសសួតអាចជាលទ្ធផលមកពីរលាកសួត។

### ៣.៤.៤.២ វិធានទី១

ប្រសិនបើប្រើគោលការណ៍ទូទៅមិនបាន និង មានការរាយការណ៍ពីលំដាប់បញ្ចប់នៅក្នុងលក្ខខណ្ឌទី១ដែលគេបានបញ្ចូល នៅលើលិខិតបញ្ជាក់ - ខាងឆ្វេងបំផុតនៅលើបន្ទាត់ I(a) - ចូរជ្រើសរើសយកមូលហេតុនៅក្នុងលំដាប់នេះ នៅលើបន្ទាត់ចុងក្រោយបំផុតដែលអាចធ្វើទៅបាន។ ប្រសិនបើមានលំដាប់លើសពីមួយ ចូរជ្រើសរើសយកលំដាប់មួយដែលចប់ដោយពាក្យទីមួយនៅលើបន្ទាត់ I(a)។ មានន័យថា វិធានទី1 ប្រើនៅពេលដែលមានលំដាប់ដែលគេរាយការណ៍ តែមូលហេតុដែលនៅលើបន្ទាត់ចុងក្រោយនៅក្នុងភាគទី I នៃលិខិតបញ្ជាក់មិនមានការពន្យល់នូវរាល់ជំងឺដែលបានរ៉ាយរ៉ាប់នៅខាងលើវា។

ឧទាហរណ៍.:

I(a) ជំងឺរលាកទងសួត-សួត (Brochopneumonia)

(b) ការស្លាប់កោសិកាខួរក្បាល និង ជំងឺបេះដូងបណ្តាលពីលើសឈាម (Cerebral infarction and hypertensive heart disease)

ចូរជ្រើសយក ការស្លាប់កោសិកាខួរក្បាល (I63.9)។ មានលំដាប់ពីរដែលរាយការណ៍ដែលបញ្ចប់នៅក្នុងលក្ខខណ្ឌ ដែលដំបូងឡើង ត្រូវគេបញ្ចូលនៅលើលិខិតបញ្ជាក់: ជំងឺរលាកទងសួត-សួត បណ្តាលមកពី ការស្លាប់កោសិកាខួរក្បាល និង ជំងឺបេះដូងបណ្តាលពីលើសឈាម។ មូលហេតុដើម នៃលំដាប់ដែលគេរ៉ាយរ៉ាប់ខាងដើម ត្រូវបានជ្រើសយក។

ឧទាហរណ៍:

I(a) បែកសរសៃឈាមបំពង់ក និង ជំងឺខ្សោយបេះដូងដោយការស្លាក់ឈាម (oesophageal varices and congestive heart failure)

(b) ជំងឺបេះដូងបណ្តាលមកពីការឈឺសន្លាក់រ៉ាំរ៉ៃ និងជំងឺក្រិនថ្លើម (chronic rheumatic heart disease and cirrhosis of liver)

ចូរជ្រើសយកជំងឺក្រិនថ្លើម (K74.6)។ លំដាប់ដែលបញ្ចប់នៅក្នុងលក្ខខណ្ឌ ដែលគេបញ្ចូលដំបូងនៅលើលិខិតបញ្ជាក់ គឺបែកសរសៃឈាមបំពង់កដែលបណ្តាលមកពីក្រិនថ្លើម។

ឧទា.: I(a) ជំងឺរលួយសាច់បេះដូងស្រួចស្រាវ (Acute myocardial infarction)

(b) ជំងឺបេះដូងបណ្តាលមកពីរឹងសរសៃឈាម (Atherosclerotic heart disease)

(c) ផ្តាសាយធំ

ចូរជ្រើសយកជំងឺ ជំងឺបេះដូងបណ្តាលមកពីរឹងសរសៃឈាម។ លំដាប់ដែលគេរាយការណ៍បញ្ចប់នៅក្នុងលក្ខខណ្ឌ ដែលគេបញ្ចូលដំបូងនៅលើលិខិតបញ្ជាក់ គឺជំងឺរលួយសាច់បេះដូងស្រួចស្រាវ បណ្តាលមកពីជំងឺបេះដូងដោយរឹងសរសៃឈាម។ តែវិធានកែតំរូវ Cក៏គេប្រើដែរ។

ឧទា.: I(a) ជំងឺរលាកស្រោមបេះដូង (Pericarditis)

(b) ជាតិអ៊ុយរ៉េក្នុងឈាម និង រលាកសួត (Uraemia and pneumonia)

ចូរជ្រើសយកជាតិអ៊ុយរ៉េក្នុងឈាម។ មានលំដាប់ពីរដែលគេរាយការណ៍ បញ្ចប់នៅក្នុងលក្ខខណ្ឌ ដែលដំបូងឡើង ត្រូវគេបញ្ចូលនៅលើលិខិតបញ្ជាក់: រលាកស្រោមបេះដូងបណ្តាលពីជាតិអ៊ុយរ៉េក្នុងឈាម និង រលាកស្រោមបេះដូងបណ្តាលពីរលាកសួត។ មូលហេតុដើម នៃលំដាប់ដែលគេរ៉ាយរ៉ាប់ខាងដើម ត្រូវបានជ្រើសយក។ តែវិធានកែតំរូវ Dក៏គេប្រើដែរ។

ឧទា.: I (a) ស្លាប់កោសិកាខួរក្បាល និង ជំងឺរលាកសួតដោយដេកយូរនៅលើគ្រែ (Cerebral infarction and hypostatic pneumonia)

(b) ជំងឺលើសឈាម និង ទឹកនោមផ្អែម (Hypertension and diabetes)

(c) ជំងឺរឹងក្រិនសរសៃឈាម (Atherosclerosis)

ចូរជ្រើសយកជំងឺរឹងក្រិនសរសៃឈាម។ មានលំដាប់ពីរដែលគេរាយការណ៍ បញ្ចប់នៅក្នុងលក្ខខណ្ឌ ដែលដំបូងឡើង ត្រូវគេបញ្ចូលនៅលើលិខិតបញ្ជាក់: ស្លាប់កោសិកាខួរក្បាល បណ្តាលពីលើសឈាម បណ្តាលពីរឹងក្រិនសរសៃឈាម និងស្លាប់កោសិកាខួរក្បាលបណ្តាលពីជំងឺទឹកនោមផ្អែម។ មូលហេតុដើម នៃលំដាប់ដែលគេរ៉ាយរ៉ាប់ខាងដើម ត្រូវបានជ្រើសយក។ តែវិធានកែតំរូវ C ក៏គេប្រើដែរ។

ប្រសិនបើគ្មានលំដាប់ត្រឹមត្រូវ វិធានទី២ គួរតែយកមកប្រើ (ចូរមើលខាងក្រោម)។

### ៣.៤.៤.៣ វិធានទី ២

ប្រសិនបើគ្មានអ្វីសោះរាយការណ៍នៅលើបន្ទាត់ខាងក្រោមគេ ដែលអាចពន្យល់លក្ខខណ្ឌរ៉ាយរ៉ាប់ខាងដើម I(a)-នៃលិខិតបញ្ជាក់មរណៈភាព ទេនោះ — ដូចនេះចូរជ្រើសយកលក្ខខណ្ឌនៅលើបន្ទាត់ I(a)។

ឧទា.: I(a) ស្លេកស្លាំងធ្ងន់ធ្ងរ និង ជំងឺពិសបាតជើង (Pernicious anaemia and gangrene of foot)

(b) រឹងក្រិនសរសៃឈាម (Atherosclerosis)

ចូរជ្រើសយកស្លេកស្លាំងធ្ងន់ធ្ងរ (D51.0)។ មិនមានលំដាប់ដែលគេរាយការណ៍ បញ្ចប់នៅក្នុងលក្ខខណ្ឌដែលគេបញ្ចូលដំបូង។

ឧទា.: I(a) ជំងឺបេះដូងដែលមកពីជំងឺរលាកសន្លាក់ និងរឹងក្រិនសរសៃឈាម (Rheumatic and artherosclerotic heart disease)

ចូរជ្រើសយក ជំងឺបេះដូងដែលមកពីជំងឺរលាកសន្លាក់ (I09.9)។ មិនមានលំដាប់ដែលគេបានរាយការណ៍ឡើយ។ លក្ខខណ្ឌទាំង២ នៅលើបន្ទាត់តែមួយ។

ឧទា.: I(a) ជំងឺរីកលំពែង (Fibrocystic disease of the pancreas)

(b) ជំងឺរលាកទងសួត និង ជំងឺស្បៀតសួត (Bronchitis and brochectasis)

ចូរជ្រើសយក ជំងឺរីកលំពែង ()។ មិនមានលំដាប់ដែលគេបានរាយការណ៍។

ឧទា.: I(a) ជំងឺចាស់ជរា និង ជំងឺរលាកសួតដោយសារដេកលើគ្រែយូរ (Senility and hypostatic pneumonia)

(b) ជំងឺរលាកសន្លាក់ (rheumatoid arthritis)

ចូរជ្រើសយក ជំងឺចាស់ជរា។ មានលំដាប់ដែលគេរាយការណ៍ - ជំងឺរលាកសួតដោយសារដេកលើគ្រែយូរ ដោយសារតែជំងឺរលាកសន្លាក់ - តែវាមិនចប់ត្រឹមជំងឺដែលបញ្ចូលពីដំបូងនៅលើលិខិតបញ្ជាក់នោះឡើយ។ តែវិធានកែតំរូវ A ក៏គេប្រើដែរ។

ឧទា.: I(a) ជំងឺរលាកស្រោមពោះ និង ដំបៅរលាកពោះវៀនធំ (Bursitis and ulcerative colitis)

ចូរជ្រើសយក ជំងឺរលាកស្រោមពោះ ()។ មិនមានលំដាប់ដែលគេបានរាយការណ៍ឡើយ។ តែវិធានកែតំរូវ B ក៏គេប្រើដែរ

ឧទា.: I(a) ជំងឺរលាកវក្កស្រួចស្រាវ ជំងឺគ្រុនក្តៅស្បែកក្រហម (Acute nephritis, scarlet fever)

ចូរជ្រើសយកជំងឺរលាកវក្កស្រួចស្រាវ។ មិនមានលំដាប់ដែលគេបានរាយការណ៍ឡើយ។ តែវិធានទី៣ (ចូរមើលខាងក្រោម) ក៏គេប្រើដែរ។

ឧទាហរណ៍ខ្លះនៃឧទាហរណ៍ខាងលើ មានការយោងទៅរកវិធានបន្ថែម ដែលគេត្រូវតែយកមកប្រើ។ ចូរមើលទៅលើវិធាន ទាំងនោះ និងពិចារណា តើវាអាចនឹងកែប្រែលទ្ធផលនៃការជ្រើសរើសយ៉ាងដូចម្តេច។

### ៣.៤.៤.៤ វិធានទី ៣

ប្រសិនបើជំងឺដែលគេបានជ្រើសយកតាមរយៈគោលការណ៍ទូទៅ ឬវិធានទី១ ឬទី២ គេឃើញច្បាស់ថា ជាផលវិបាកផ្ទាល់នៃជំងឺដែលគេរាយការណ៍មួយទៀត បើទោះជានៅក្នុងផ្នែកទី១ ឬក៏ផ្នែកទី២ក៏ដោយ ចូរជ្រើសយកជំងឺដំបូងបំផុត។ នេះមានន័យថា ក្នុងករណីខ្លះ វាមានជំងឺដែលគេរាយការណ៍នៅក្នុងផ្នែកទី១ ឬទី២នៃទំរង់ដែលមិនបានជ្រើសយក ដោយប្រើគោលការណ៍ទូទៅ វិធានច្បាប់ទី១ ឬទី២ តែវាអាចបណ្តាលអោយមានជំងឺដំទៃទៀតនៅលើលិខិតបញ្ជាក់។ ក្នុងករណីនេះ គេត្រូវប្រើវិធានទី៣។

វិធាននេះវាមានល្បិចពិសេស។ ឧទាហរណ៍ខាងក្រោមនេះ គឺចង់ផ្តល់នូវមគ្គុទេសន៍។ គួរតែអានពតិមាននៅក្នុងភាគទី២ ផ្នែក៤.១.៧ ដោយយកចិត្តទុកដាក់ ហើយត្រូវមានបទពិសោធន៍យ៉ាងច្រើនលើសលុបដើម្បីយល់នូវវិធាននេះ។ នៅក្នុងកោសល្យវិច័យផ្ទាល់មាត់ ប្រសិនបើលិខិតបញ្ជាក់បានបំពេញពេញលេញយ៉ាងត្រឹមត្រូវ នោះអ្នកនឹងកំរត្រូវប្រើវិធានទី3នេះណាស់។

ឧទា.: I（a） Kaposi’s sarcoma
II AIDS
ចូរជ្រើសយក AIDS ដែលអោយផលជា Kaposi’s sarcoma (B21.0)

ឧទា.: I（a） មហារីកកន្សោមពង (Cancer ovary)
II HIV
ចូរជ្រើសយក ដុំមហារីកកន្សោមពង (C56)

ឧទា.: I（a） របេង (Tuberculosis)
II HIV
ចូរជ្រើសយក HIV ដែលអោយផលជាការបង្ករោគដោយមេរោគរបេង (B20.0).

ឧទា.: I（a） Cerebral toxoplasmosis and herpes zoster
(b) Burkitt’s lymphoma, HIV disease
ចូរជ្រើសយក HIV ដែលនាំអោយមានជំងឺជាច្រើនដែលចាត់ថ្នាក់នៅកន្លែងដំទៃ（B22.7）។ ជំងឺប៉ះពាល់ខួរក្បាលដោយពួក toxoplasmosis ដែលគេជ្រើសយកទៅតាមវិធានទី2 អាចនឹងត្រូវពិចារណាថាជាផលវិបាកផ្ទាល់របស់ជំងឺ HIV។

ឧទា.: I（a） ជំងឺរលាកទងសួតនិងសួត (Bronchopneumonia)
II ជំងឺស្លេកស្លាំងពីមូលហេតុមួយទៀត និង ជំងឺមហារីកគ្រាប់ឈាមស (Secondary anaemia and chronic lymphatic leukaemia)
ចូរជ្រើសយក Chronic lymphatic leukaemia (C91.1)។ ជំងឺរលាកទងសួតនិងសួត គេជ្រើសរើសទៅតាមគោលការណ៍ទូទៅ（ចូរមើលវិធានទី2 នៅឧទាហរណ៍រលាកស្រោមពោះនិងដំបៅរលាកពោះវៀនធំ）ហើយ Secondary anaemia អាចត្រូវ ពិចារណាទាំងពីរ ថាជាផលសំណល់ពី Chronic lymphatic leukaemia ។

ឧទា.: I(a) ហូរឈាមក្នុងខួរក្បាល (Cerebral haemorrhage)

(b) ជំងឺលើសឈាម (Hypertension)

(c) ជំងឺរលាកតំរងនោមរ៉ាំរ៉ៃ និង ស្ទះនោមដោយក្រពេញប្រូស្តាត (Chronic pyelonephritis and prostatic obstruction)

ចូរជ្រើសយក Prostatic obstruction (N40)។ ជំងឺរលាកតំរងរ៉ាំរ៉ៃ ត្រូវគេជ្រើសរើសទៅតាមវិធានទី1 វាអាចត្រូវពិចារណាថាជាផលសំណល់នៃ Prostatic obstruction ។

ឧទា.: I(a) ជំងឺរលាកវក្កស្រួចស្រាវ ជំងឺគ្រុនក្តៅស្បែកក្រហម (Acute nephritis, Scarlet fever)

ចូរជ្រើសយក Scarlet fever (A38)។ ជំងឺរលាកវក្កស្រួចស្រាវ ត្រូវគេជ្រើសរើសទៅតាមវិធានទី1 (ចូរមើលឧទាហរណ៍ខាងក្រោម ដែលយោងទៅជំងឺរលាកសួតដោយដេកលើគ្រែយូរ និងហូរឈាមក្នុងខួរក្បាល) វាអាចត្រូវពិចារណាថាជាផលសំណល់នៃ Scarlet fever ។

ឧទា.: I(a) ការកាត់វក្ក (Nephrectomy)

II មហារីកកោសិកាវក្ក (Clear cell carcinoma of kidney)

ចូរជ្រើសយក Clear cell carcinoma of kidney (C64) ។ វាមិនមានត្រូវសង្ស័យឡើយ ការកាត់វក្ក គឺធ្វើឡើងសំរាប់មហារីកវក្ក។

ឧទា.: I(a) ជំងឺស្លេកស្លាំងស្រួចស្រាវ (Acute anaemia)

(b) ក្អួតឈាម (Haematemesis)

(c) ការហូរឈាមពីពកសរសៃឈាមបំពង់ក (Bleeding of oesophageal varices)

(d) សំពាធឈាមសរសៃវ៉ែននៅថ្លើម ឡើងខ្ពស់ (Portal hypertension)

ចូរជ្រើសយក ជំងឺក្រិនថ្លើម (Cirrhosis of liver) (K74.6)។ សំពាធឈាមសរសៃវ៉ែននៅថ្លើម ឡើងខ្ពស់ ត្រូវគេជ្រើសរើសទៅតាមគោលការណ៍ទូទៅ អាចពិចារណាថាជាផលវិបាកផ្ទាល់នៃជំងឺក្រិនថ្លើម។

ឧទា.: I(a) ជំងឺរលាកសួតដែលមកពីដេកយូរនៅលើគ្រែ (Hypostatic pneumonia)

(b) ហូរឈាមខួរក្បាល និង មហារីកដោះ (Haemorrhage and cancer of breast)

ចូរជ្រើសយក ហូរឈាមខួរក្បាល (I61.9)។ ជំងឺរលាកសួតដែលមកពីដេកយូរនៅលើគ្រែ ត្រូវគេជ្រើស រើសទៅតាមវិធានទី2 អាចពិចារណាថាជាផលវិបាកផ្ទាល់នៃជំងឺណាមួយទៀតដែលគេបានរាយការណ៍។ ចូរជ្រើសយកមួយដែលរាយការណ៍ដំបូងគេ។

ឧទា.: I(a) ការស្លាប់កោសិកាសួតដោយ ស្ទះសរសៃឈាម (Pulmonary infarction)

II កាត់សួតខាងឆ្វេងដោយមហារីកនៅសួត កាលពីបីសប្តាហ៍មុន (Left pneumonectomy for carcinoma of lung 3 weeks ago)

ចូរជ្រើសយក មហារីកសួត (C34.9)

### ៣.៤.៤.៥ វិធាននៃការកែប្រែ

ក្នុងករណីខ្លះ មូលហេតុនៅពីក្រោយការស្លាប់ដែលបានជ្រើសយកដោយប្រើប្រាស់វិធាននានាខាងលើ មិនមែនជាមូលហេតុដែលមានសារៈប្រយោជន៍ ឬពត៌មានសំរាប់សុខភាពសាធារណៈ ឬ គោលបំណងការពារ នោះទេ - ឧទាហរណ៍ជំងឺចាស់ជរា ឬ ដំណើរនៃជំងឺទូទៅ ដូចជាការរឹងក្រិនសរសៃឈាម ។

នៅក្នុងករណីបែបនេះ វិធាននៃការកែប្រែត្រូវគេយកមកប្រើ នៅក្រោយគោលការណ៍ទូទៅ វិធានទី១ ទី២ និង ទី៣ ដែលបានប្រើរួចហើយនោះ ។

មានវិធានកែប្រែចំនួន៦ (A-F) ។ ចូរកត់សំគាល់ថាបណ្តុំនៃវិធានទាំងនេះមានល្បិចកលច្រើនណាស់ ។ ឃ្លាខាងក្រោមនេះ គឺចង់ផ្តល់គំនិតនូវអ្វីដែលវិធានគ្របដណ្តប់ ។ ពត៌មាននៅក្នុងភាគទី២ ផ្នែក ៤.១.៨ ត្រូវតែអាន ដោយយកចិត្តទុកដាក់ ហើយត្រូវមានបទពិសោធន៍យ៉ាងច្រើនលើសលុបដើម្បីយល់ និងប្រើវិធានទាំងនេះ ។

#### វិធាន A : ជំងឺចាស់ជរានិង " ជំងឺដែលគេថា " ផ្សេងៗទៀត

នៅទីណាដែលមូលហេតុនៃការស្លាប់ត្រូវគេជ្រើសយក គឺជា "ជំងឺដែលគេថា " និង ជំងឺដ៏ទៃទៀត គេបានរាយការណ៍នៅលើលិខិតបញ្ជាក់ ចូររើសយកមូលហេតុស្លាប់ ដោយចាត់ទុកថា ជំងឺដែលគេថា មិនបានត្រូវគេរាយការណ៍ ។

#### វិធាន B : ជំងឺកំប៉ិកកំប៉ុក

នៅពេលដែលគេបានរាយការណ៍ជំងឺធ្ងន់ធ្ងរ តែមូលហេតុដែលបានជ្រើសយកគឺជាជំងឺ "កំប៉ិកកំប៉ុក" (គឺថា ជំងឺដែលមើលទៅ មិនអាចបណ្តាលអោយស្លាប់) ចូរជ្រើសយកមូលហេតុនៅពីក្រោយការស្លាប់ ដោយចាត់ទុកថា ជំងឺកំប៉ិកកំប៉ុក មិនបានត្រូវគេរាយការណ៍ ។

#### វិធាន C : បន្សារ

ICD-10 ផ្តល់នូវបញ្ជីមួយ សំរាប់ថាតើត្រូវភ្ជាប់ជំងឺខ្លះបែបណា ដើម្បីជ្រើសយកមូលហេតុនៅពីក្រោយការស្លាប់ ដែលទាក់ទងបំផុត ។ អ្នកនឹងឃើញការពន្យល់ដ៏ច្រើននៅក្នុងផ្នែក ៤.១.១១ និង ៤.១.១២ នៃភាគទី២ ។

ឧទា.: I(a) ស្ទះពោះវៀនតូច (Intestinal obstruction)

(b) ក្លូនលូននៅក្រលៀន (Femoral hernia)

ចូរដាក់កូដ ជាក្លូនលូននៅក្រលៀន ដោយមានការស្ទះ (K41.3) ។

## វិធាន D :  ភាពជាក់លាក់

នៅពេលដែលមូលហេតុដែលបានជ្រើសយក  ពណ៌នាជំងឺនៅក្នុងពាក្យទូទៅ  ហើយពាក្យជំងឺដែលផ្តល់នូវពត៌មានកាន់តែច្បាស់លាស់ អំពីទីកន្លែង ឬក៏សភាពរបស់វា ដែកគេរាយការណ៍នៅលើលិខិតបញ្ជាក់ ត្រូវការនូវពាក្យដែលផ្តល់នូវពត៌មានទាំងនេះអោយកាន់តែច្បាស់ ។ វិធាននេះគេប្រើជាញឹកញាប់នៅពេលដែលពាក្យទូទៅក្លាយទៅជាគុណនាមបញ្ជាក់អោយពាក្យកាន់តែច្បាស់លាស់ ។

ឧទាហរណ៍:

I (a)　រលាកស្រោមខួរ (Meningitis)

(b)　របេង

ចូរដាក់កូដ ជារលាកស្រោមខួរដោយរបេង (A17.0) ។ អ្នកបញ្ជាក់បានដាក់ថារលាកស្រោមខួរដោយសារតែជំងឺរបេង ។

## វិធាន E :  តំណាក់ដំបូង  និងតំណាក់ចុងក្រោយនៃជំងឺ

នៅពេលដែលមូលហេតុដែលបានជ្រើសយក  ជាតំណាក់ដំបូងនៃជំងឺ  ហើយតំណាក់ធ្ងន់ដាបនៃជំងឺដដែលត្រូវគេរាយការណ៍នៅលើលិខិតបញ្ជាក់ ចូរដាក់កូដសំរាប់តំណាក់កាលធ្ងន់ដាប ។

វិធាននេះមិនត្រូវបានគេប្រើសំរាប់ទំរង់រ៉ាំរ៉ៃ ដែលគេរាយការណ៍ថាវាបណ្តាលមកពីទំរង់ស្រួចស្រាវនោះទេ ដ៏រាបណាការចាត់ថ្នាក់ផ្តល់នូវសេចក្តីណែនាំពិសេសចំពោះផលបែបនេះ ។

ឧទាហរណ៍:

I (a)　ជំងឺស្វាយតំណាក់ទី៣ (Tertiary syphilis)

(b)　ជំងឺស្វាយតំណាក់ទី១

ចូរដាក់កូដ ជា ជំងឺស្វាយតំណាក់ទី៣ (A52.9) ។

ឧទាហរណ៍:

I (a)　ជំងឺរលាកតំរងនោមរ៉ាំរ៉ៃ (Chronic nephritis)

(b)　ជំងឺរលាកតំរងនោមស្រួចស្រាវ

ចូរដាក់កូដ ជារលាកតំរងនោមរ៉ាំរ៉ៃ មិនជាក់លាក់ (N03.9) ដោយហេតុគេផ្តល់អោយការណែនាំពិសេស ចំពោះផលនេះ (ចូរមើលនៅលំហាត់តទៅនេះ) ។

លំហាត់:

ចូរមើលក្នុងភាគទី២ និងព្យាយាមរកមើលការណែនាំនេះ ។

**វិធាន F ៖ លំដាប់**

វិធាននេះផ្តល់នូវការណែនាំអំពីការជ្រើសរើសក្នុងករណីដែលការខូចខាតនាត់ណាក់កាលចុងក្រោយនៃជំងឺមួយ (សំណល់) ហើយជំងឺបង្ក (កើតមានឡើងយ៉ាងយូរមុនពេលស្លាប់) ត្រូវតែរៀបរាប់នៅលើលិខិតបញ្ជាក់។

ឧទាហរណ៍៖

I(a) ក្បាលមានទឹក (Hydrocephalus)

(b) រលាកស្រោមខួរដោយជំងឺរបេង (Tuberculous meningitis)

ចូរដាក់កូដ ជាសំណល់នៃការរលាកស្រោមខួរដោយជំងឺរបេង (B90.0) ។

ប្រភេទនៃ "សំណល់" មានដូចតទៅ៖ B90, B94, E64, E68, G09, I69, 097, Y85, និង Y89 ។

លំហាត់៖

ចូរមើលទៅលើប្រភេទពិសេសទាំងនេះនៅក្នុង ICD-10 ដើម្បីអោយថ្នឹកជាមួយនឹងពួកវា។

## ៣.៥ ការប្រើប្រាស់ទិន្នន័យ

ICD-10 ផ្តល់នូវបញ្ជីតារាងសំរាប់មរណៈភាព និង ជំងឺ នៅក្នុងភាគទី១។ ក្រុមអ្នកមានវិជ្ជាជីវៈផ្សេងៗទៀត បានបង្កើតបញ្ជីផ្សេងៗសំរាប់ប្រមូលផ្តុំជំងឺនិងការបង្ហាញស្ថិតិ។ ដោយមិនទាក់ទងនឹងបញ្ជីដែលប្រើ មរណៈភាពគួរចាត់ទៅតាមភេទ និង នៅក្នុងក្រុមអាយុដូចតទៅនេះ៖ អាយុ <១ឆ្នាំ, អាយុ១-៤ឆ្នាំ, ហើយបន្ទាប់មក ក្នុងក្រុម៥ឆ្នាំៗ ដោយចាប់ពី ៥ឆ្នាំ ទៅ៨៤ឆ្នាំ និងតទៅអាយុ ≥៨៥ឆ្នាំ។ ភាគទី២ ផ្នែក៥.៦.១ មានសេចក្តីណែនាំពេញលេញ។

គោលបំណងនៃកោសល្យវិច័យផ្ទាល់មាត់ គឺពិពណ៌នាមូលហេតុនៃមរណៈភាពនៅក្នុងសហគមន៍ ឬនៅក្នុងប្រជាជន ក្នុងខណៈដែលមិនមានប្រភពណាផ្សេងទៀតល្អជាងនេះ។ ដូច្នេះវាជាប្រភពជំនួសដែលមានកំរិតសំរាប់ការបញ្ជាក់វេជ្ជសាស្ត្រដែលត្រឹមត្រូវ។ គុណភាពពតិមាននិងរោគវិនិច្ឆ័យ ប្រែប្រួលអាស្រ័យលើជំនាញរបស់អ្នកសំភាសន៍ និង ស្មារតីចងចាំរបស់អ្នកឆ្លើយ។

"បញ្ជីមូហេតុស្លាប់ដែលបានមកពីកោសល្យវិច័យផ្ទាល់មាត់" គេឃើញនៅក្នុងបន្ទាត់បញ្ឈរពីរខាងឆ្វេងបំផុត នៅក្នុងបញ្ជីតារាងនៅចុងបញ្ចប់នៃសៀវភៅនេះ។ បញ្ជីរបស់កោសល្យវិច័យផ្ទាល់មាត់គឺជាប្រពន្ធ័ចំណាត់ថ្នាក់ដ៏សំខាន់ ដែលបញ្ជាក់នូវមូលហេតុស្លាប់ដ៏សំខាន់បំផុតខ្លះៗ នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចទាបនិងមធ្យម។ វាអាចនឹងត្រូវគេមើលឃើញថាជា "ភាគបែងរួមទាបបំផុត" ដែលអាចប្រើប្រាស់បានដើម្បីរួបរួមទិន្នន័យពីគំរោងកោសល្យវិច័យផ្ទាល់មាត់នានា។ ការដាក់កូដរោគវិនិច្ឆ័យដោយ ICDនឹងជួយការរួបរួមទិន្នន័យនេះ និងចាប់ទុកពតិមានលំអិតដែលអាចធ្វើទៅបាន ទៅតាមសេចក្តីត្រូវការនៅនឹងទីកន្លែង។

**កំណត់សំគាល់៖ កុំរួបរួមទិន្នន័យដែលប្រមូលបានពីកោសល្យវិច័យផ្ទាល់មាត់ ជាមួយនឹងទិន្នន័យពីប្រពន្ធ័ចុះបញ្ជីជីវិតពេញលេញ និងលិខិតបញ្ជាក់មរណៈភាពវេជ្ជសាស្ត្រ (ការពិនិត្យវេជ្ជសាស្ត្រក្រោយការស្លាប់)។**

របៀបដែលគេប្រមូលពត៌មានក្នុងអំឡុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ និងរបៀបដែលគេធ្វើរោគវិនិច្ឆ័យគឺខុសគ្នាពីវិធីសាស្ត្រដែលប្រើក្នុងអំឡុងពេលធ្វើលិខិតបញ្ជាក់វេជ្ជសាស្ត្រ ។ ភាពប្រាកដប្រជានៃការធ្វើរោគវិនិច្ឆ័យ គឺទាបជាងយ៉ាងឆ្ងាយពីការធ្វើកោសល្យវិច័យផ្ទាល់មាត់ និងជំងឺខ្លះមិនអាចធ្វើរោគវិនិច្ឆ័យបាន ។ រូបបូមទិន្នន័យពីវិធីទាំងពីរនេះនឹងបិទបាំងភាពខុសគ្នាដែលអាចអោយលទ្ធផលពីវិធីទាំងនេះ និងឈានទៅរកការបកស្រាយខុសនូវលទ្ធផល ។

## ៣.៦ ការសំងាត់

និតិវិធីនៃកោសល្យវិច័យផ្ទាល់មាត់ទាក់ទងនឹងការប្រមូល និងរក្សាពត៌មានដែល ប្រសិនបើលេចចេញទៅអ្នកទី៣ អាចនឹងបង្កនូវការខូចខាត ឬឈឺចាប់ដល់អ្នកដែលគេសំភាសមិត្តភក្តិ ឬសាច់ញាតិរបស់អ្នកដែលស្លាប់ ។ អ្នកស្រាវជ្រាវត្រូវរៀបចំដើម្បីការពារការសំងាត់របស់មនុស្សដែលផ្តល់ពត៌មាន ដោយឧទាហរណ៍ លុបពត៌មានដែលអាចឈានទៅសំគាល់អត្តសញ្ញាណរបស់បុគ្គលដែលគេសំភាស ឬដោយកំរិតកំណត់នូវការទទួលបាននូវពត៌មាន ឬដោយដាក់ទិន្នន័យជាអនាមិក ។ ក្នុងអំឡុងនៃដំណើរការទទួលយកនូវកិច្ចយល់ព្រមអោយសំភាសន៍ អ្នកស្រាវជ្រាវគួរអនុញ្ញាត្តិអោយអ្នកដែលនឹងត្រូវសំភាស ដឹងអំពីការប្រុងប្រយត្ន័ដែលនឹងត្រូវប្រកាន់យកដើម្បីការពារនូវការសំងាត់ ។

**អ្នកស្រាវជ្រាវត្រូវរៀបចំការការពារដ៏រឹងមាំដើម្បីការពារការសំងាត់អ្នកដែលខ្លួនសំភាស និង ទិន្នន័យដែលពួកគាត់ផ្តល់អោយ ។ ត្រូវប្រាប់អ្នកដែលខ្លួនត្រូវសំភាសអំពីព្រំដែន ច្បាប់ឬអ្វីផ្សេងទៀត ទៅតាមលទ្ធភាពរបស់អ្នកស្រាវជ្រាវ ក្នុងការការពារការសំងាត់ និងផលវិបាកដែលកើតមានឡើងនៃការធ្វើអោយធ្លាយការសំងាត់ ។**

អ្នកដែលត្រូវគេសាកសួរត្រូវប្រាប់អោយដឹងពីព្រំដែននៃលទ្ធភាពរបស់អ្នកស្រាវជ្រាវដើម្បីធានាយ៉ាងម៉ឺងម៉ាត់នូវការសំងាត់ និង ផលវិបាកសង្គមមិនល្អដែលប្រមើលឃើញ ក្នុងករណីដែលធ្លាយការសំងាត់ ។ តាមផ្លូវច្បាប់ខ្លះតំរូវអោយរាយការណ៍ពីមរណៈភាព ទៅភ្នាក់ងារសមស្របនានា ។ អ្វីក៏ដោយដែលកំណត់ព្រំដែនលទ្ធភាពរបស់អ្នកស្រាវជ្រាវក្នុងការរក្សាការសំងាត់ ត្រូវតែរំពឹងទុកជាមុន និងបើកចំហរអោយដឹង ដើម្បីការពារការសំងាត់របស់អ្នកដែលខ្លួនសំភាស ។
ល្អបំផុត អ្នកដែលគេសាកសួរ គួរចុះហត្ថលេខាលើទំរង់កិច្ចយល់ព្រមដែលត្រូវតាមកន្លែង ដោយផ្អែកលើគោលការណ៍ទាំងនេះ ។

## ៣.៧ ប្រភពពត៌មានបន្ថែមទៀត

### ៣.៧.១ ការផ្លាស់ប្តូរ និង បច្ចុប្បន្នភាព ចំពោះ ICD-10

ជាផ្នែកនៃដំណើរការធ្វើអោយមានបច្ចុប្បន្នភាពសំរាប់ ICD-10 អ្វីៗ ដែលត្រូវធ្វើការបន្ថែមទៅលើការផ្លាស់ប្តូរនិងបច្ចុប្បន្នភាពនៃចំណាត់ថ្នាក់ ត្រូវតែបញ្ចេញអោយដឹងជារៀងរាល់ឆ្នាំ ។ ច្បាប់នៃរាល់ការធ្វើបច្ចុប្បន្នភាពតាំងពីឆ្នាំ ១៩៩៦ មក មាននៅក្នុងគេហ៍ទំព័រ http://www.who.int/classifications/en/ ។

### ៣.៧.២ ពត៌មានអំពី ICD

ពត៌មានទូទៅអំពី ICD អាចរកបាននៅ http://www.who.int/classifications/icd/en/ ។ ភាគទី២ និង បណ្ណ័បញ្ជាក់មាននៅលើទំព័រនេះ ។

### ៣.៧.៣ តារាងការសំរេចចិត្ត

តារាងការសំរេចចិត្តជួយក្នុងការជ្រើសរើសមូលហេតុនៅពីក្រោយការស្លាប់ ហើយការធ្វើអោយមានបច្ចុប្បន្នភាពជាទៀតទាត់ អាចរកបានពី United States Centers for Disease Control and Prevention’s National Center for Health Statistics ។ តារាងទាំងនេះអាចចំលងចេញបានពី http://www.cdc.gov/nchs/about/major/dvs/im.htm ។

### ៣.៧.៤ ការពិនិត្យមើលជាទូទៅអំពីឱកាសនៃការបណ្តុះបណ្តាល

គ្រួសារអង្គការសុខភាពពិភពលោកនៃចំណាត់ថ្នាក់អន្តរជាតិ (WHO-FIC) គណៈកម្មការសិក្សាអប់រំ បានប្រមូលផ្តុំបញ្ជីអ្នកជំនាញការ និងកន្លែងបណ្តុះបណ្តាល ។ ពត៌មាននេះអាចរកបាននៅក្នុង http://www.cdc.gov/nchs/about/otheract/icd9/nacc_ed_ committee.htm ។

ការភ្ជាប់ទៅការិយាល័យតំបន់របស់អង្គការសុខភាពពិភពលោក អាចរកឃើញនៅក្នុង http://www.who.int/about/regions/en/.

### ៣.៧.៥ វេទិកាសាធារណៈអំពីមរណៈភាព

វេទិកាសាធារណៈអំពីមរណៈភាពនៃបណ្តាញ WHO-FIC គឺជា បណ្តាញពិភាក្សាអន្តរជាតិដែលពិនិត្យមើលពីបញ្ហាដែលជួបប្រទះនៅពេលដាក់កូដមរណៈភាព ICD-10 ។ បញ្ហាដែលមិនអាចដោះស្រាយបាននៅក្នុងវេទិកានេះ ត្រូវតែបញ្ជូនទៅក្រុមសំអាងមរណៈភាព ( Mortality Reference Group) ។ ភារកិច្ចរបស់ក្រុមសំអាងមរណៈភាពនៃមជ្ឈមណ្ឌលសហប្រតិបត្តិការនៃ WHO-FIC រួមមានធ្វើការសំរេចចិត្តអំពីការប្រើប្រាស់និងបកស្រាយ ICD-10 នៅពេលវាទាក់ទងនឹងមរណៈភាព និង រៀបចំគំរោងសំរាប់ធ្វើបច្ចុប្បន្នភាព និងផ្លាស់ប្តូរ ។

វេទិកាសារណៈនេះ អាចរកបាននៅ http://www.nordclass.uu.se/verksam/mortfore ។

## ៣.៨ កូដ ICD នៅក្នុងកោសល្យវិច័យផ្ទាល់មាត់_ករណីពិសេសៗ

មូលហេតុស្លាប់ខ្លះសមនឹងទទួលនូវការយកចិត្តទុកដាក់ជាពិសេសនៅក្នុងពេលដាក់កូដ ។ ទាំងជាមូលហេតុញឹកញាប់ដែលជួបប្រទះក្នុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ និងមូលហេតុស្លាប់រួមបញ្ចូលដែលកើតមានជាញឹកញាប់ ។ ករណីនានាដែលរ៉ាយរ៉ាប់នៅក្នុងសៀវភៅនេះ មិនទាន់អស់នៅឡើយទេ ។

### ៣.៨.១ ដោះស្រាយជាមួយនឹងមូលហេតុច្រើន

កោសល្យវិច័យផ្ទាល់មាត់អាចនឹងនាំទៅរកការកំណត់មូលហេតុស្លាប់លើសពីមួយ ដោយហេតុថាការធ្វើរោគវិនិច្ឆ័យផ្សេងៗអាចនឹងត្រូវរាយការណ៍ដោយសាច់ញាតិ ឬរ៉ាយរ៉ាប់នៅក្នុងរបាយការណ៍វេជ្ជសាស្ត្រនានា។

ចំណាត់ថ្នាក់ខ្លះនៃ ICD-10ដែលគេបានចាត់សំរាប់ដាក់កូដត្រូវនឹងជំងឺគួបផ្សំនានា និងខណៈដែលការណែនាំនៃករណីដ៏ទៃទៀត ត្រូវតែផ្តល់អោយដើម្បីថាតើជ្រើសរើសនិងរាយការណ៍យ៉ាងដូចម្តេច អំពីមូលហេតុស្លាប់ដែលមានប្រយោជន៏បំផុត។ វាសំខាន់ដែលយើងត្រូវតែធ្វើតាមវិធាននៃការដាក់កូដ ដោយប្រើប្រាស់លិបិក្រមរបស់ ICD-10 និងបញ្ជីតារាង ក៏ដូចជាវិធាន និងអនុសញ្ញានានាដែលបានបញ្ជាក់នៅក្នុងភាគទី២ ដើម្បីកំណត់ទីនន្លែងកូដដែលមានប្រយោជន៏បំផុត។

**ឧទាហរណ៏រួមះ**

មិនមានវិធានចាត់ថ្នាក់ដែលផ្តល់អោយ HIV នាំមុខគ្រុនចាញ់ ឬបញ្ច្រាសមកវិញ ដោយស្វ័យប្រវត្តិនោះទេ។ បើទោះជាមូលហេតុស្លាប់ ត្រូវគេចាត់ថាជា HIV ឬគ្រុនចាញ់ក៏ដោយ វាអាស្រ័យលើរបៀបដែលគេបំពេញលិខិតបញ្ជាក់មរណះភាព។

ឧទាហរណ៏:

នៅទីណាដែលមានរ៉ាយរ៉ាប់អំពី HIVជាមួយនឹងគ្រុនចាញ់ ចូរកូដទៅ B20.8។

ឧទាហរណ៏:

តារាងខាងក្រោមបង្ហាញពីដំណោះស្រាយចំពោះបញ្ហាដាក់កូដដែលគេតែងតែឃើញជាទូទៅ។

| ជំងឺ | កូដ |
|---|---|
| HIVនិងរលាកសួត | B23.8 ( ប្រសិនបើគេមិនដឹងពីភ្នាក់ងារបង្កជំងឺរលាកសួត) |
| ជំងឺលើសឈាមនិងដាច់សរសៃឈាមខួរក្បាល | I64 |
| ជំងឺលើសឈាមដោយគួបផ្សំជាមួយនឹងងាប់សាច់បេះដូងស្រួចស្រាវ ឬអសមត្ថភាពបេះដូង | I21 |
| ជំងឺលើសឈាម និងអសមត្ថភាពបេះដូង | I11.0 |
| ជំងឺទឹកនោមផ្អែម និងដាច់សរសៃឈាមខួរក្បាល | E14.6 |
| ជំងឺទឹកនោមផ្អែមនិងជំងឺលើសឈាម | ដែលកូដត្រូវប្រើ អាស្រ័យទៅលើរបៀបដែលគេបំពេញលិខិតមរណភាព : មានកូដតែមួយប៉ណ្ណោះដែលត្រូវទុក |
| កើតមិនគ្រប់ខែ និង/ឬ ទំងន់ពេលកើតទាប និង គ្រោះថ្នាក់ដង្ហើម | P22.0 |
| ជំងឺរាគ និង រលាកសួត | A09 |

## ៣.៨.២ មូលហេតុពិសេសផ្សេងទៀត

លក្ខខណ្ឌដែលអាចអោយមានការយល់ច្រឡំក្នុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ គឺពួកទាំងឡាយដែលមានពហុរោគវិនិច្ឆ័យឬផលវិបាក ឬទាំងពីរ។ ឧទាហរណ៍នានានៃលក្ខខណ្ឌដែលអាចបង្កនូវការយល់ច្រឡំ គឺមាន ស្លាប់កើត ដែលគេដឹងឬមិនដឹងមូលហេតុមកពីមាតាដែលនៅពី ក្រោយការស្លាប់ និងមូលហេតុ របួសពីខាងក្រៅ។

ជំងឺតទៅនេះត្រូវការនូវការយកចិត្តទុកដាក់ជាពិសេស នៅពេលដែលពតិមានពីកោសល្យវិច័យផ្ទាល់មាត់ត្រូវគេដាក់កូដ។

### ៣.៨.២.១ ជំងឺគ្រុនចាញ់

កូដ ICD-10 អាចត្រូវប្រើនៅពេលដែលជំងឺគ្រុនចាញ់គឺជាមូលហេតុស្លាប់ តែភាពមិនជាក់លាក់នៃជំងឺ និងការខ្វះខាតពតិមានលំអិតដែលទាញចេញពីកោសល្យវិច័យផ្ទាល់មាត់ អាចនឹងដាក់នូវការពិបាកពិសេស។ ក្នុងការចាត់កូដ។ ជំងឺគ្រុនចាញ់ដែលគេធ្វើរោគវិនិច្ឆ័យដោយរោគសញ្ញាគ្លីនិកត្រូវដាក់កូដ B54។

ជំងឺគ្រុនចាញ់ដែលប៉ះពាល់ដល់ខួរក្បាលគឺជាករណីពិសេសក្នុងការដាក់កូដ។ រោគវិនិច្ឆ័យជាទូទៅគឺផ្អែកទៅលើការមិនរាប់ចូលនៃជំងឺខួរក្បាលដ៏ទៃទៀត (ឧទាហរណ៍ ជំងឺខួរក្បាលដោយ កង្វះជាតិស្ករនៅក្នុងឈាម រលាកខួរនិងស្រោមខួរ ក្រលាភ្លើង ពុល របួសក្បាល គ្រោះថ្នាក់សរសៃឈាមខួរក្បាល ភាពមិនប្រក្រតីនៃការរំលាយអាហារក្នុងរាងកាយ និងការបង្ករោគផ្សេងទៀត) និងការបញ្ជាក់នៃវត្តមានជំងឺគ្រុនចាញ់។ ដោយមិនមានពតិមានលំអិតអំពីទំរង់កោសល្យវិច័យផ្ទាល់មាត់ ដែលអាចជួយបញ្ជាក់ពីជំងឺគ្រុនចាញ់ ឬមិនរាប់ចូលទំរង់ផ្សេងៗទៀតនៃជំងឺរលាកស្រោមខួរ ចំណេះដឹងរបស់គ្រូពេទ្យ បទពិសោធន៏នៅនឹងកន្លែង និងពតិមានអំពីអេពីដេមីសាស្ត្រពាសពេញ ត្រូវប្រើយ៉ាងប្រុងប្រយត្ន័ក្នុងការវាយតំលៃពតិមានអំពីការស្លាប់ សំរាប់គោលបំណងធ្វើរោគវិនិច្ឆ័យ។

នៅក្នុង ICD-10 ចំណាត់ថ្នាក់ "គ្រុនចាញ់ខួរក្បាល" ស្ថិតនៅក្នុងប្រភេទគ្រុនចាញ់ដែលបង្កដោយផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម : B50.0 (ជំងឺគ្រុនចាញ់ដោយផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម ជាមួយនឹងផលវិបាកលើខួរក្បាល)។ ដោយហេតុថា ក៏រិតនៃការលំអិតនេះ (កញ្ចក់ឈាមបង្ហាញពីប្រភេទផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម) គឺមិនទំនងជារកឃើញនៅក្នុងកោសល្យវិច័យផ្ទាល់មាត់ឡើយ (ឬបើទោះជានៅក្នុងឯកសារពេទ្យ) ការដាក់កូដរោគវិនិច្ឆ័យឬមូលហេតុស្លាប់ ជាគ្រុនចាញ់ខួរក្បាល (និងទំរង់ផ្សេងៗភាគច្រើននៃជំងឺគ្រុនចាញ់) មិនអាច និយាយយ៉ាងម៉ឺងម៉ាត់ ធ្វើឡើងដោយយោងទៅលើរោគសញ្ញានិងបណ្តុំរោគសញ្ញាឡើយ។ ដូចនេះមូលហេតុស្លាប់ដែលអាចកើតឡើងពីជំងឺគ្រុនចាញ់នៅក្នុងកោសល្យវិច័យផ្ទាល់មាត់ អាចដាក់ជា B54 (ជំងឺគ្រុនចាញ់ដោយមិនបញ្ជាក់) ឬ B50.0 (ផ្លាស់ស្មូដ្យូមហ្វាល់ស៊ី ប៉ារ៉ូម ដោយមានផលវិបាកខួរក្បាល) តែប៉ុណ្ណោះ។

ដូច្នេះនៅក្នុងកោសល្យវិច័យផ្ទាល់មាត់ វាមិនអាចប្រើកូដដូចតទៅនេះឡើយសំរាប់ជំងឺគ្រុនចាញ់: B51, B52, B53.0 និង B53.1។ កូដទាំងនេះតំរូវអោយមានពតិមានជាក់លាក់អំពីផ្លាស់ស្មូដ្យូម ដែលគេមិនអាចរកឃើញក្នុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់។ ជាលទ្ធផល វាអាចនឹងសមស្របក្នុងការបញ្ជាក់ និងដាក់កូដមរណៈភាពមួយ ពីជំងឺគ្រុនចាញ់ខួរក្បាល នៅពេលអវត្តមាននូវសេចក្តីបញ្ជាក់ពីផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម ថាជា B50.0 (ចូរមើលឧទាហរណ៏ខាងក្រោម)។

ឧទាហរណ៍:

B54 ជំងឺគ្រុនចាញ់មិនបញ្ជាក់
ជំងឺគ្រុនចាញ់ដែលគេធ្វើរោគវិនិច្ឆ័យដោយសញ្ញាគ្លីនិក ពុំមានការបញ្ជាក់ពីប៉ារ៉ាសិត។

B50.0 ជំងឺគ្រុនចាញ់ដោយផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម ដោយមានផលវិបាកខួរក្បាល
គ្រុនចាញ់ខួរក្បាល NOS

នៅក្នុងឧទាហរណ៍នេះ សេចក្តីបញ្ជាក់គឺ "មិនមានបញ្ជាក់ក្រៅពីនេះ" (NOS)

### ៣.៨.២.២ HIV

### HIV និង របេង

នៅក្នុងការអនុវត្តគ្លីនិក វាអាចនឹងពិបាកក្នុងការបែងចែករវាង ការបង្ករោគ HIV និងរបេង (TB)។ វាគ្រាន់តែមានលទ្ធភាពបញ្ជាក់ការពិតអំពីរោគវិនិច្ឆ័យជាមួយនឹងភស្តុតាងពីការធ្វើតេស្តឈាមមេរោគ HIV និង តេស្តកំហាកសំរាប់រកមេរោគរបេង: អ្នកជំងឺម្នាក់ដែលមានរោគសញ្ញាថាជា HIV ឬរបេង តែមានតេស្ត HIVអវិជ្ជមាន និងវិជ្ជមានមេរោគរបេងនៅពេលបណ្តុះកំហាកតែមិនមាន HIV។ ក្នុងករណីជាច្រើន លក្ខខណ្ឌទាំងពីរវាមានជាមួយគ្នា តែវាពិបាកនឹងកំណត់ថាតើលក្ខខណ្ឌណាមួយដែលជាមូលហេតុនៅពីក្រោយការស្លាប់។ ជាមួយនឹងពត៌តិចតួចដែលបានមកពីកោសល្យវិច័យផ្ទាល់មាត់ ស្ថានភាពនេះបង្ហាញពីបញ្ហាដែលត្រូវការគោលការណ៍ណែនាំដែលគេបានព្រមព្រៀងដូចតទៅនេះ។

ជំងឺ HIV អាចមានវត្តមានជាមួយនឹងផលវិបាកជាច្រើន និង ការបង្ករោគ ដែលនិមួយៗមានមូលហេតុស្លាប់មួយផ្ទាល់របស់វា ពី B20 (ជំងឺ HIV ដែលបណ្តាលអោយមានការបង្ករោគ និងជំងឺប៉ារ៉ាសិត) ទៅ B24 (ជំងឺ HIV មិនកំណត់ជាក់លាក់)។ ទោះបីជានៅក្នុង ICD-10អក្សរទី៤អនុប្រភេទនៃ B20-B23 ដែលគេផ្តល់អោយសំរាប់ជាជំរើសប្រើប្រាស់ក៏ដោយ វាមានសារៈសំខាន់ណាស់ សំរាប់បែងចែករវាងរបេងជាមួយHIV និង HIVតែឯង នៅពេលណាដែលអាចធ្វើទៅបាន។

ការធ្វើរោគវិនិច្ឆ័យរបេងពីកោសល្យវិច័យផ្ទាល់មាត់ អាចនឹងមានបញ្ហាប្រឈមជាច្រើន។ រោគវិនិច្ឆ័យសំរេចមួយនៃជំងឺរបេងអាចនឹងធ្វើឡើងតែនៅពេលណាដែលគេបញ្ជាក់ឃើញមេរោគនៅក្នុងភ្នាសអាស៊ីត-បាស ចំតែម្តងគឺពីកំហាក។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពត៌មានរបៀបនេះកំរនឹងមានណាស់ នៅក្នុងឯកសារពេទ្យរបស់អ្នកស្លាប់។ នៅពេលដែលគេសំរេចថា របេងជារោគវិនិច្ឆ័យមួយសមស្របហើយនោះ ចូរបកស្រាយនូវរោគសញ្ញាគ្លីនិក និងប្រវត្តិដោយប្រុងប្រយត្ន័ និងចូរព្យាយាមស្វែងរកក្រែងលោអ្នកស្លាប់ :

- មានកំហាកវិជ្ជមាន នូវមេរោគរបេង
- មានរូបថតដើមទ្រូងដោយកាំរស្មី X ដែលណែនាំពីរបេងសួត
- បាន និងកំពុងប្រើថ្នាំរបេង
- មានប្រវត្តិដែលប្រាប់យើងអំពីរបេង ឧទាហរណ៍ ក្អកដែលលើសពីមួយខែ ស្គមកំព្រឹង ឬមានគ្រុនក្តៅអូសបន្លាយ (ក្នុងករណីដែលអ្នកស្លាប់មានគ្រុនក្តៅ វាពិបាកនឹងញែកចេញរវាងរបេងនិងHIV)។

ដោយគិតពីសារៈសំខាន់នៃសុខភាពសាធារណៈនៃជំងឺរបេង និងដើម្បីរក្សានូវឯកភាព ក្នុងការចាត់មូលហេតុស្លាប់ ប្រភេទ៤តួអក្សរខាងក្រោមគួរត្រូវប្រើជាមួយនឹងជំងឺHIVរួមនឹងរបេង ក្នុងករណីដែលមិនអាចកំណត់លំដាប់ និងមិនអាចជ្រើសយកមូលហេតុតែមួយ ។

ឧទាហរណ៏ៈ

I（a） ជំងឺរបេង

（b） HIV

（c） ---

（d） ----

II ----

ចូរជ្រើសយក B20.0 ជំងឺ HIV ដែលអោយទៅជាការបង្ករោគដោយមេរោគរបេង（ mycobacterial infection）

ឧទាហរណ៏ៈ

I（a） ជំងឺរបេង

（b） ---

（c） ---

（d） ----

II HIV

ចូរជ្រើសយក A16.9 ជំងឺរបេង NOS ។

## ការប្រើប្រាស់ B22.0 សំរាប់ HIV និងជំងឺបាត់បង់ការចងចាំ (Dementia)

កូដ B22.0 សំរាប់មូលហេតុស្លាប់ត្រូវគេប្រើនៅពេលដែលមានប្រវត្តិវង្វេងវង្វាន់ ភ្លេចការចងចាំ និងបាត់បង់ស្មារតីមានរយៈពេលលើសពី១ថ្ងៃ ឬនៅពេលដែលមានការស្តែងចេញនូវសញ្ញាសរសៃប្រសាទកណ្តាល ដូចជាការដាច់សរសៃឈាមខួរក្បាលទាក់ទងនឹង HIV ។

B22.0 **ជំងឺ HIV ដែលអោយផលជាជំងឺសរសៃប្រសាទខួរក្បាល**

ជំងឺបាត់បង់ការចងចាំដោយសារ HIV

នៅពេលដែលមានករណី HIV ជាមួយនឹងរបេង និងការស្តែងចេញសញ្ញាប្រពន្ធ័សរសៃប្រសាទកណ្តាល B22.0 គួរតែត្រូវប្រើសំរាប់មូលហេតុផ្ទាល់នៃការស្លាប់ ។

### ការប្រើប្រាស់ B20.7 សំរាប់ HIV និងការបង្ករោគច្រើនមុខ

កូដ B20.7សំរាប់មូលហេតុស្លាប់ត្រូវគេប្រើនៅពេលដែលមានភស្តុតាងនៃការបង្ករោគលើសពីមួយ កើតមានឡើងនៅលើអ្នកជំងឺ HIV ។ ការបង្ករោគទាំងនេះអាចរាប់បញ្ចូល ជំងឺផ្សិត (candidasis, mycoses) ឬជំងឺប៉ារ៉ាសិត ។

### B20.7 ជំងឺ HIV ដែលអោយផលជាការបង្ករោគច្រើនមុខ

ការប្រើកូដនេះសំរាប់មូលហេតុស្លាប់ នៅពេលមានការបង្ករោគលើសពី១ ជួយអោយចៀសវាងការចាត់មូលហេតុស្លាប់ពីរបី (មូលហេតុមួយសំរាប់ប្រភេទការបង្ករោគមួយដែលទាក់ទង) បង្កើតឯកភាព និងជួយអោយមានការយល់ស្របជាធ្លុងមួយក្នុងចំណោមអ្នកដាក់កូដ ។

នៅពេលដែលមានភស្តុតាងនៃជំងឺរបេង ឬជំងឺដ៏ទៃទៀតបន្ថែមទៅលើ HIVនោះ មូលហេតុស្លាប់ B20.0 (HIVជាមួយនឹងរបេង) ត្រូវគេប្រើ ។ ក្នុងករណីនៃជំងឺ HIVដែលមានតែការបង្ករោគតែមួយត្រូវគេកំណត់ ដូចជាជំងឺផ្សិតដោយពួកCandidas នោះមូលហេតុស្លាប់ ដែលគេចាត់គឺ B20.4 " HIV ដែលអោយផលជាជំងឺផ្សិត "។ ចូរមើលទៅលើផ្នែកបន្ទាប់សំរាប់ពតិមានអំពីការដាក់កូដសំរាប់ជំងឺ Kaposi sarcoma ។

### ការប្រើប្រាស់ B21.0 សំរាប់ HIV និង Kaposi sarcoma

នៅពេលដែលមាន HIV ជាមួយនឹង Kaposi sarcoma ផលវិបាកនេះមិនត្រូវគេដាក់កូដដាច់ដោយឡែកឡើយ តែត្រូវគេរាប់បញ្ចូលនៅក្នុងប្រភេទការបង្ករោគច្រើនមុខ។ ក្នុងករណីដែល Kaposi sarcoma ជាផលវិបាកតែមួយគត់នៃជំងឺ HIV នោះកូដ ICD-10 សមស្របនឹងត្រូវប្រើ ( B21.0) ។

### B21.0 ជំងឺ HIV ដែលអោយផលជា Kaposi’s sarcoma

កូដនេះត្រូវគេប្រើដោយសារតែ Kaposi sarcoma ជាជំងឺដែលខូចពហុមជ្ឈមណ្ឌល និងត្រូវចាត់ទុកជាភាពដែលអាចបណ្តាលឱ្យស្លាប់ ដែលមានប្រភពចំលងពីវីរុស ។

### គោលការណ៍ណែនាំសំរាប់ HIV នៅលើកុមារ

ICD-10 មិនបានផ្តល់នូវកូដដាក់លាក់សំរាប់ចំណាត់ថ្នាក់មូលហេតុស្លាប់ពីជំងឺ HIV នៅលើកុមារឡើយ ។ ដោយសារតែមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យ HIV នៅលើកុមារ នៅក្នុងការអនុវត្តគ្លីនិក កាន់តែពិបាកទៅទៀតនៅក្នុងអំឡុងកោសល្យវិច័យផ្ទាល់មាត់ សេចក្តីណែនាំតទៅនេះត្រូវគេប្រើ ដើម្បីចាត់មូលហេតុស្លាប់របស់កុមារដែលមានជំងឺ HIV ។

HIV ត្រូវចាត់ជាមូលហេតុស្លាប់ក្នុងករណីដែលមាន:

- រោគសញ្ញាគ្លីនិកដែលផ្តល់ជាពន្លឺថាជាជំងឺ HIVនៅលើកុមារ ដោយមិនមានមូលហេតុច្បាស់លាស់ឯទៀតនៃការចុះខ្សោយភាពស៊ាំ( ឧទាហរណ៏ ជំងឺកង្វះអាហារូបត្ថម្ភ)
- រោគសញ្ញាគ្លីនិកដែលផ្តល់ជាពន្លឺថាជាជំងឺ HIVនិងខ្សែស្រឡាយវា និងប្រវត្តិសង្គមដែលផ្តល់ជាពន្លឺ HIV ( ឧទាហរណ៏ ឪពុក ម្តាយស្លាប់ដោយជំងឺHIV) ដោយរាប់ទាំងករណីដែលម្តាយរបស់កុមារឈឺ នៅពេលដែលកុមារស្លាប់ ។ ឬ
- រោគសញ្ញាគ្លីនិកដែលផ្តល់ជាពន្លឺថាជាជំងឺ HIV ហើយគ្រូពេទ្យដែលពិនិត្យកុមារ បានស្នើសុំតេស្ត ដែលផ្តល់ជាពន្លឺថាជាជំងឺ HIV និងដើម្បីបញ្ជាក់រោគវិនិច្ឆ័យ ។

### ៣.៨.២.៣ មរណះភាពមាតា

ដោយដឹងថាមរណៈភាពមាតាគឺជាមូលហេតុស្លាប់ញឹកញាប់បំផុតក្នុងចំណោមស្រ្តីនៅក្នុងអាយុបន្តពូជ នៅក្នុងបណ្តាប្រទេសដែលក្រីក្របំផុត វាជាការសំខាន់ចំពោះអ្នកដែលបញ្ជាក់ និង ដាក់កូដស្លាប់ មានការយល់ច្បាស់អំពីអ្វីដែលបណ្តាលអោយមានមរណៈមាតា និងអ្វីដែលជាមូលហេតុផ្ទាល់និងមិនផ្ទាល់នៃមរណៈភាព។ និយមន័យដែលទាក់ទងនឹងមរណៈភាពមាតា ត្រូវគេផ្តល់អោយនៅក្នុងភាគទី២ ផ្នែក ៥.៨ នៃ ICD-10 ហើយដើម្បីភាពឯកភាព គួរតែត្រូវប្រើវាជានិច្ចជាកាល ។
មរណៈភាពមួយត្រូវចាត់ថាជា "មរណៈភាពមាតា " ប្រសិនបើស្រ្តីម្នាក់ស្លាប់នៅពេលដែលនាងមានផ្ទៃពោះ ឬនៅក្នុងរយៈ៤២ថ្ងៃនៃការបញ្ចប់ផ្ទៃពោះ ដោយមិនគិតពីរយៈពេល ឬទីតាំងផ្ទៃពោះឡើយ។ មរណៈភាពមាតាអាចបណ្តាលមកពីមូលហេតុណាមួយដែលទាក់ទងនឹងការមានផ្ទៃពោះ តែមិនមែនមកពីមូលហេតុគ្រោះថ្នាក់ ឬឧបទ្ទេវហេតុឡើយ។ "មរណៈភាពមាតាពេលយូរ" យោងទៅលើមរណៈភាពដែលកើតមានឡើង ពី៤២ថ្ងៃទៅ១ឆ្នាំ ក្រោយពីបញ្ចប់ផ្ទៃពោះ។

" មរណៈភាពទាក់ទងនឹងផ្ទៃពោះ " គឺជាមរណៈភាពមួយដែលកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះ ឬក្នុងអំឡុងពេល៤២ថ្ងៃនៃការសំរាល ដោយមិនគិតពីមូលហេតុស្លាប់ ។

មរណៈភាពមាតាអាចផ្ទាល់ឬប្រយោល (គឺថា វាអាចមានមូលហេតុផ្ទាល់ឬប្រយោល)។ **មូលហេតុផ្ទាល់** គឺផលវិបាកសម្ភពនៃផ្ទៃពោះ ពេលសំរាលនិងក្រោយសំរាល។ មូលហេតុផ្ទាល់ក៏យោងផងដែរទៅមរណៈភាពដែលកើតមានឡើងក្រោយផ្ទៃពោះដែលមានធ្លាក់ឈាម ឬស្លាប់ពីការសំរាលមិនរួច ឬពន្យារពេល ក្រលាភ្លើង ឬឆ្លងរោគ។ ផ្ទៃពោះរលូត ឬពហុគភ៌។ ឬកើតឡើងពីផលវិបាកនៃការវះកាត់យកកូន។

ឧទាហរណ៏:

មូលហេតុផ្ទាល់នៃមរណៈភាពមាតា

I(a) ស្លកដោយការហូរឈាម

(b) រហែកស្បូន

(c) សំរាលមិនរួច

ក្នុងករណីនេះ ចូរជ្រើសយក "សំរាលមិនរួច" ជាមូលហេតុនៅពីក្រោយការស្លាប់ ( O66.9;សំរាលមិនរួចដែលមិនបញ្ជាក់)។

**មូលហេតុប្រយោល**នៃមរណៈភាពមាតាគឺមូលហេតុទាំងឡាយដែលបណ្តាលមកពី ជំងឺដែលមានពីមុនមក ឬជំងឺដែលមានក្នុងអំឡុងពេលមានផ្ទៃពោះ តែមិនមែនជាលទ្ធផលផ្ទាល់នៃមូលហេតុសម្ភព។ ជំងឺបែបនេះរួមមានជំងឺលើសឈាមដែលមានពីមុនមក ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ស្ទះសរសៃឈាមវ៉ែនដោយកំណកឈាម ជំងឺស្លេកស្លាំង គ្រុនចាញ់ និងរបេង។

មរណៈភាពមាតាដែលកើតឡើងដោយជំងឺ HIV (B20-B24) ឬមកពីតេតាណុសពេលសម្ភព (A34) ត្រូវតែកូដនៅក្នុងជំពូក១ នៃ ICD-10 និងគួរយកចិត្តទុកដាក់ ក្នុងការបញ្ចូលពួកវាទៅក្នុង**អត្រាមរណៈភាពមាតា**។ ដូចនេះ វាជាការសំខាន់ក្នុងការបញ្ជាក់ ថាតើភាគយកនៅក្នុងអត្រាមរណៈភាពមាតា មានរាប់មូលហេតុផ្ទាល់ ឬប្រយោល ឬទាំងពីរ។

### ៣.៨.២.៤ ស្លាប់កើត ឬមរណៈភាពកូនខ្ចី (Stillbirth or Fetal death)

ពាក្យ "ស្លាប់កើត" ឬ "មរណៈភាពកូនខ្ចី" ត្រូវតែប្រើ (មិនមែនស្លាប់ទារកនៅក្នុងស្បូន) នៅពេលដែលស្លាប់ ត្រូវតែកត់ត្រាក្រោយពេលដែលកើតនូវទារកដែលស្លាប់ និងមិនមែននៅពេលដែលទារកនៅក្នុងស្បូន។

មិនមានការខុសគ្នានៅក្នុងមូលហេតុស្លាប់រវាងស្លាប់កើតដែលគេកត់ត្រាថា "ស្រស់" ឬ "ត្រាំ"។ នៅពេលដែលមានទារកស្លាប់ ឬស្លាប់កើតដែលបណ្តាលមកពីមូលហេតុពិសេសណាមួយ (ឧទាហរណ៍ ធ្លាក់ឈាមមុនសំរាល ការបង្ករោគ ក្រលាភ្លើង) មូលហេតុស្លាប់ដែលគេកត់ត្រា គឺ "ស្លាប់កើត" (មរណៈភាពកូនខ្ចី) ដែលបណ្តាលមកពីមូលហេតុសម្ភពណាមួយដែលសមស្រប។

នៅពេលដែលមិនមានមូលហេតុដែលអាចបញ្ជាក់បានសំរាប់ស្លាប់កើតអំពីប្រវត្តិ មូលហេតុស្លាប់សមស្របគឺ P95 "ស្លាប់កើត ដែលបណ្តាលមកពីមូលហេតុមិនជាក់លាក់"។

### ៣.៨.២.៥ មរណៈភាពជុំវិញកំណើត (Neonatal death)

មរណៈភាពជុំវិញកំណើត គឺមរណៈភាពដែលកើតឡើងក្នុងចំណោមទារកដែលកើតរស់ ក្នុងអំឡុងពេល២៨ថ្ងៃពេញលេញនៃជីវិត។ ការ បញ្ជាក់ការស្លាប់ជុំវិញកំណើត ជាធម្មតាតំរូវនូវពត៌មានទាំងអំពីម្តាយនិងទារក។
ជួនកាលការលំបាកកើតមានក្នុងការបែងចែករវាងស្លាប់កើត និងស្លាប់ជុំវិញកំណើត។ ប្រសិនបើមានភស្តុតាងនៅក្នុងរបាយការណ៍វេជ្ជសាស្ត្រនៃជីវិតក្រោយពេលកើត ជាមួយនឹងការស្លាប់ដែលកើតមានឡើងនៅពេលបន្ទាប់មក មរណៈភាពរបៀបនេះគឺគេចាត់ថ្នាក់ជាមរណៈភាពជុំវិញកំណើត។ នៅក្នុងករណីជាច្រើន វាពិបាកនឹងបញ្ជាក់ច្បាស់ពីអ្នកដែលគេសំភាស ថាតើទារកនៅរស់ក្រោយពេលសំរាលដែរឬទេ ហើយស្លាប់នៅពេលបន្តិចក្រោយមក ឬក៏ជាស្លាប់កើត។ ការនេះបណ្តាលអោយមានមរណៈភាពជុំវិញកំណើតជាច្រើនត្រូវតែដាក់ថាស្លាប់កើត។

ប្រសិនបើស្លាប់ជុំវិញកំណើត អាចបណ្តាលមកពីមូលហេតុពិសេសណាមួយ មូលហេតុស្លាប់គួរត្រូវចាត់ និងកត់ត្រាថាជា "មរណៈភាពជុំវិញកំណើតបណ្តាលមកពី" មូលហេតុណាមួយដែលសមស្រប។

### ៣.៨.២.៦ ជំងឺរាគ

ការលំបាកមួយចំនួនកើតមានឡើង ក្នុងការបែងចែកជំងឺរាគដែលមិនមែនមេរោគ (K52.9) ពីជំងឺរាគ និងការលាកក្រពះពោះវៀនដែលសន្មត់ថាមានប្រភពពីមេរោគ (A09)។ ការបែងចែកនេះសំខាន់ណាស់ ដោយសារតែវាមានតំលៃប្រើប្រាស់សំរាប់សុខភាពសាធារណៈ។ មានសំណំសេចក្តីណែនាំមួយចំនួនមានគោលបំណងកំណត់នូវជំងឺជាក់លាក់ ដូចជាជំងឺអាសន្នរោគ បានត្រូវគេបង្កើតឡើង និងរ៉ាយរ៉ាប់ នៅក្នុងសៀវភៅនៃឧបករណ៍កោសល្យវិច័យផ្ទាល់មាត់នៅលើបុគ្គល។

### ៣.៨.២.៧ មូលហេតុពីក្រៅ

ចេតនារបស់ព្រឹត្តិការណ៍មួយដែលបង្ករបួសស្នាម (ដូចជាគ្រោះថ្នាក់ចរាចរណ៍ របួសដោយសារកាំបិត ឬដាល់) អាចជាដោយចៃដន្យ ចេតនាបង្កដោយខ្លួនឯង ឬដោយចេតនាធ្វើអោយអ្នកដទៃមានរបួសស្នាម (វាយប្រហារ)។ នៅក្នុងករណីដែលចេតនានៅមិនទាន់ច្បាស់លាស់ របៀបពិពណ៌នាព្រឹត្តិការណ៍គឺ"ដោយគ្រោះថ្នាក់"។ នៅពេលដែលការសើបអង្កេតផ្លូវច្បាប់ និង ឯកសារពេទ្យ ត្រូវបានធ្វើឡើងដោយហ្មត់ចត់ តែមិនមានការវិនិច្ឆ័យអំពីចេតនាត្រូវបានធ្វើឡើង នោះលក្ខខណ្ឌនោះត្រូវកូដជា Y10-Y34 "ចេតនាមិនអាចកំណត់បាន"។ លិបិក្រមសំរាប់មូលហេតុពីក្រៅនៅក្នុងភាគទី៣ អាចអោយគេរកឃើញកូដសមស្របបានយ៉ាងលឿន។
ជាចុងក្រោយបំផុត ផ្នែកដែលខុសគ្នាដាច់នៃជំពូកអំពីមូលហេតុពីខាងក្រៅ អាចនឹងប្រើប្រាស់នៅពេលដែលការដាក់កូដសំរាប់យន្តការដែលសំលាប់មនុស្សម្នាក់ ដែលបានប៉ះពាល់ដល់សត្វពាហនៈ - ជាឧទាហរណ៍ ស្លាប់ដោយសារសត្វពស់ អាចនឹងត្រូវដាក់កូដ ក្នុងរបៀបផ្សេងៗ:

រូបរិតកំទេចដោយសត្វពោះ ដាក់កូដ W59

ពស់ពិសចឹក X20

លំហាត់

ចូរមើលក្នុងប្លុក W50 – W64 និង X20 – X29 ហើយកំណត់នូវភាពខុសគ្នារវាងពួកវា។

ក្នុងករណី ដែលក្នុងនោះ ម្តាយឬកូនត្រូវរបួសហើយត្រូវសំលាប់ដោយមូលហេតុពីខាងក្រៅ កូដមួយយកមកពីជំពូក XV (ការមានផ្ទៃពោះ ការសំរាល និង ក្រោយការសំរាល) ឬជំពូក XVI (ជំងឺមួយចំនួនដែលមានដើមកំណើតនៅក្នុងរយៈពេលជុំវិញកំណើត) អាចនឹងមានអាទិភាពសំរាប់ការធ្វើតារាងនៃមូលហេតុតែមួយនៃមរណៈភាព (ចូរមើលឧទាហរណ៍ខាងក្រោម)។
ឧទារហរណ៍:

ការដាក់កូដសំរាប់មរណៈភាពម្តាយ និង ទារក

ទារកក្រោយប្រសូត្រ មានកំដៅចុះទាប P80.-។

មនុស្សធំ: ប្រឈមទៅនឹងភាពត្រជាក់ហួសប្រមាណនៃធម្មជាតិ X31។

ម្តាយ: ផលវិបាកនៃការដាក់ថ្នាំសណ្តំ O74.- ឬ 89.-។

លំហាត់

ចូរមើល O74.- និង O89.-។ តើអ្វីដែលជាការខុសគ្នារវាងពួកវា។

### ៣.៨.២.៨ មូលហេតុពីក្រៅ

**ប្រកាច់**

នៅពេលដែលប្រកាច់កើតមានឡើងនៅលើមនុស្សដែលរស់នៅក្នុងតំបន់ដែលមានគ្រុនចាញ់ខ្ពស់ជាប្រចាំ ជាពិសេសពេលដែលវាកើតមាននៅនឹងកុមារ និងមិនមានមូលហេតុលេចចេញមកនោះ គ្រូពេទ្យជាច្រើនចាត់រោគវិនិច្ឆ័យ R56.0 ( ប្រកាច់ដោយកំដៅ) ។ នៅពេលដាក់កូដ គេមិនប្រើ "ប្រកាច់ដោយក្តៅ " ដើម្បីតាងអោយមូលហេតុស្លាប់ ដោយហេតុថានេះជារោគវិនិច្ឆ័យមិនដាក់បញ្ចូល ។ ដោយជំនួសវិញ "ប្រកាច់ " ត្រូវគេប្រើជាពាក្យនាំមុខ ។ ប្រសិនបើមូលហេតុស្លាប់មិនត្រូវគេដឹង ឬមិនអាចកំណត់បាន កូដដែលគេប្រើគេ R99 ( មូលហេតុស្លាប់ដែលគេមិនអាចកំណត់បាន) ជាជាង R69 ( មូលហេតុស្លាប់ដែលគេមិនអាចកំណត់បាន) ។

**ការដាក់កូដនៅពេលមានតែរោគសញ្ញានិងបណ្តុំរោគសញ្ញាដែលគេបានកត់ត្រា**

ICD-10 អាចអោយគេចាត់ថ្នាក់ជំងឺនិងបញ្ហាសុខភាពបើទោះជានៅក្នុងករណីដែលមានតែរោគសញ្ញានិងបណ្តុំរោគសញ្ញាប៉ុណ្ណោះដែលគេបានកត់ត្រា ដោយមិនមានរោគវិនិច្ឆ័យស្ថាពរក៏ដោយ ។ នៅពេលដែលមិនមានរោគវិនិច្ឆ័យស្ថាពរ បណ្តុំរោគសញ្ញាសំខាន់ គំហើញដែលមិនធម្មតា ឬបញ្ហាដែលគេជ្រើសយក គឺជាជំងឺសំខាន់ ។ បណ្តុំរោគសញ្ញាណាដែលមាន (នៅពេលដែលមូលហេតុស្លាប់មិនអាចកំណត់បាន) ដែលគេប្រើសំរាប់ដាក់កូដ ( ឧទាហរណ៍ ឈឺពោះនាំទៅរកជំងឺដែលមិនជាក់លាក់) ។ ដំណើរការនេះក៏រិតជាអប្បបរិមានូវចំនួនស្លាប់ដែលគេចាត់ថ្នាក់ជា R99 ( មូលហេតុស្លាប់ដែលគេមិនអាចកំណត់បាន) ។

## ៣.៩ តារាងទាក់ទងរវាង បញ្ជីកោសល្យវិច័យផ្ទាល់មាត់ខ្លី និង កូដ ICD-10

អង្គការសុខភាពពិភពលោកបានស្នើថា បញ្ជីនៃប្រភេទដែលបង្ហាញនៅក្នុងតារាងទាក់ទងតទៅនេះ នឹងត្រូវគេប្រើក្នុងអំឡុងពេលកោសល្យវិច័យផ្ទាល់មាត់។ តារាងនេះគឺជាលទ្ធផលនៃការវិភាគប្រពន្ធ័កោសល្យវិច័យផ្ទាល់មាត់ដែលកំពុងមាន។ ប្រពន្ធ័និមួយៗនៃកោសល្យវិច័យផ្ទាល់មាត់អាចនឹងប្រើតែអនុប្រភេទដែលស្នើខាងក្រោមនេះតែប៉ុណ្ណោះ។

តារាងឆ្លើយឆ្លងធ្វើអោយមានលទ្ធភាពបញ្ចូលទិន្នន័យពីកោសល្យវិច័យផ្ទាល់មាត់នានា នៅលើវង្វាស់ជាអន្តរជាតិ និង អាចអោយប្រភេទនានាត្រូវគេដាក់កូដដោយប្រើ ICD-10។ ដូចនេះ លទ្ធផលពីប្រពន្ធ័កោសល្យវិច័យផ្ទាល់មាត់នានាអាចនឹងត្រូវគេប្រៀបធៀបជាមួយនឹងទិន្នន័យបានមកពីការចុះបញ្ជីជីវិតពេញលេញ និងប្រពន្ធ័បញ្ជាក់វេជ្ជសាស្ត្រ។

រោគវិនិច្ឆ័យមួយចំនួនដែលរ៉ាយរ៉ាប់នៅក្នុងតារាងឆ្លើយឆ្លង គេមិនអាចនឹងចាត់វាបានដោយប្រើពត៌មានដែលគេប្រមូលក្នុងអំឡុងពេលធ្វើការសំភាសកោសល្យវិច័យផ្ទាល់មាត់ តែគេក៏អាចរកវាឃើញនៅក្នុងឯកសារវេជ្ជសាស្ត្រ ឬប្រភពផ្សេងៗទៀត។

តារាងឆ្លើយឆ្លងផ្ទុកទៅដោយប្រភេទកោសល្យវិច័យផ្ទាល់មាត់ និង កូដ ICD-10 ទាក់ទងរបស់វា។ គេបានចាត់វា ដើម្បីអាចអោយប្រភេទកោសល្យវិច័យផ្ទាល់មាត់ ត្រូវគេប្រើសំរាប់ដាក់កូដ ក៏ដូចជាសំរាប់ធ្វើតារាង។

នៅពេលដែលពត៌មានដែលគេប្រមូលតាមរយៈកោសល្យវិច័យផ្ទាល់មាត់ អាចអោយគេទទួលបានពត៌មានលំអិតជាងអ្វីដែលទទួលបានពីបញ្ជីស្តង់ដារនៃកោសល្យវិច័យផ្ទាល់មាត់ អ្នកដែលចាត់កូដ គួរតែប្រើ ICD-10 ពេញលេញ។ តារាងឆ្លើយឆ្លង អាចអោយគេរក ICD-10 បានយ៉ាងងាយ និងរហ័ស។ ពាក្យគន្លឹះ ("អធិប្បាយ") នៅក្នុងជួរបញ្ឈរខាងស្តាំដៃអាចនឹងជួយអ្នកដាក់កូដអោយចៀសវាងនូវអន្ទាក់ខ្លះៗ។

ប្រសិនបើកូដ ICD ដែលមាន៤តួអក្សរត្រូវគេរ៉ាយរ៉ាប់ នេះមានន័យថា ICD-10 មិនអាចផ្តល់ការលំអិតលើសពីនេះ (ដរាបណា ផ្នែកតូចៗនៃជំពូកខ្លះ ត្រូវគេប្រើដើម្បីដាក់កូដ កន្លែងរបស់ជំងឺ និងសកម្មភាពរបស់មូលហេតុពីក្រៅ)។ ភាគទី១ នៃ ICD-10 គួរតែត្រូវពិគ្រោះជានិច្ចជាកាល ដើម្បីពិនិត្យមើលថាតើវាមានពាក្យជំនួសដែលល្អជាងនេះដែរឬទេ។

ពត៌មាននៅក្នុងតារាងឆ្លើយឆ្លង ដែលទាក់ទងទៅនឹងរោគវិនិច្ឆ័យ គួរត្រូវគេសាកល្បងមើល និង ធ្វើអោយទាន់បច្ចុប្បន្នភាព ទៅតាមការចាំបាច់ ដោយគំរោងកោសល្យវិច័យផ្ទាល់មាត់ ដោយសហការជិតស្និទ្ធជាមួយនឹងអង្គការសុខភាពពិភពលោក។ ពត៌មានរោគវិនិច្ឆ័យអាចនឹងត្រូវគេបញ្ចូលទៅក្នុងកំរងសំណួរ ជាលេខនពន្ធ ឬជាករណីពណិនា ហើយវាអាចនឹងមានប្រយោជន៏ សំរាប់អ្នកដែលចាត់រោគវិនិច្ឆ័យ ឬឧបករណ៏កំណត់រោគវិនិច្ឆ័យថ្មី។ ការដាក់បញ្ចូលពត៌មានរោគវិនិច្ឆ័យធានាថាប្រភេទនានា ត្រូវគេប្រើទៅតាមរបៀបដូចៗគ្នា នៃរាល់គំរោងកោសល្យវិច័យផ្ទាល់មាត់។ ពត៌មានដែលទាក់ទងទៅនឹងរោគវិនិច្ឆ័យ ជាទូទៅគឺមិនទាក់ទងនឹងអ្នកដែលចាត់កូដ ឬការជ្រើសយកមូលហេតុនៅពីក្រោយការស្លាប់ឡើយ (គឺថា ចំពោះអ្នកដាក់កូដ)។

**តារាងទំនាក់ទំនងៈ បញ្ជីមូលហេតុស្លាប់ សំរាប់កោសល្យវិច័យផ្ទាល់មាត់ ជាមួយនឹងតថានុរូបទូលំទូលាយនៃកូដ ICD-10**

| **កូដកោសល្យវិច័យ ផ្ទាល់មាត់** | **ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់** | **កូដ ICD-10** | **ចំណងជើង ICD-10** | **អធិប្បាយ** |
|---|---|---|---|---|
| VA-01 | ជំងឺឆ្លងនិងជំងឺដោយពពួកប៉ារ៉ាសិត | | | ការខុសគ្នាសំខាន់ពី ICD-10<br>នៅក្នុង ICD-10គេឃើញជំងឺរលាកស្រោមខួរស្ថិតនៅក្នុងជំពូកI (ជំងឺ ឆ្លង និងជំងឺប៉ារ៉ាសិតមួយចំនួន) និងនៅក្នុងជំពូក VI (ជំងឺនៃ ប្រពន្ធ័សរសៃប្រសាទ) អាស្រ័យទៅលើ ការបង្ករោគដែលនៅពី ក្រោម។<br>គេចាត់ ការបង្ករោគប្រដាប់ដង្ហើមស្រួចស្រាវ ទៅក្នុងជំពូក X (ជំងឺនៃប្រពន្ធ័ផ្លូវដង្ហើម)។<br>ជំងឺឆ្លងមួយចំនួនកើតឡើងជាផលវិបាកនៃជំងឺឆ្លងមួយទៀត។ ដើម្បីដាក់រួមគ្នាឱ្យត្រូវ វាមានប្រភេទសមស្របនៅក្នុង ICD-10។ |
| VA-01.01 | ជំងឺឆ្លងលើពោះវៀនតូច (រាប់ទាំងជំងឺរាគ) | A029 | ការបង្ករោគដោយពួក Salmonella មិនជាក់លាក់។ | **ពតិមានដែលទាក់ទងៈ** |
| | | | | កើនភាពទឹកនៃលាមកក្នុងរយៈពេល <៣សប្តាហ៍ |
| | | A039 | Shigellosis មិនជាក់លាក់។ | មានឈាមនៅក្នុងលាមក |
| | | A049 | ការបង្ករោគពោះវៀនតូចដោយបាក់តេរី មិនជាក់លាក់។ | សំបោរនៅក្នុងលាមក |
| | | A059 | ពុលចំណីអាហារដោយបាក់តេរី មិនជាក់លាក់ | គ្រុនក្តៅ |
| | | A069 | ជំងឺពួកអាមីប មិនជាក់លាក់ | ចុកពោះ/ចង់តែជុះ |
| | | A079 | ជំងឺពោះវៀនតូចដោយ Protozoal មិនជាក់លាក់ | ស្រកទំងន់ |
| | | | | ក្អួត |
| | | A084 | ការបង្ករោគពោះវៀនតូចដោយវីរុសមិនជាក់លាក់។ | |

| កូដកោសល្យវិច័យផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-01.02 | | A09 | រាគនិងរលាកក្រពះពោះវៀន ដោយការបង្ករោគដើម។<br>គ្រុនក្ដៅ ដោយ Paratyphoid | ជំងឺនៅក្នុង VA-01.02 អាចនឹងច្រឡំយ៉ាងងាយជាមួយនឹងជំងឺរាគផ្សេងទៀត នៅក្នុង VA-01.0<br>**ពត៌មានដែលទាក់ទង:**<br>លាមកដូច "Puréed peas" |
| VA-01.03 | ជំងឺរបេង | A159<br>A169<br>A179<br>A189<br>A192<br>A199 | របេងផ្លូវដង្ហើម មិនបញ្ជាក់ បានបញ្ជាក់បាក់តេរីនិងប្រវត្តិ<br>របេងផ្លូវដង្ហើម មិនបញ្ជាក់ មិនបាននិយាយពីការបញ្ជាក់បាក់តេរី ឬប្រវត្តិ<br>របេងប្រពន្ធ័សរសៃប្រសាទ មិនបញ្ជាក់<br>របេងដាសស្រួចស្រាវ មិនបញ្ជាក់<br>របេងដាស មិនបញ្ជាក់ | ជំងឺរ៉ាំរ៉ៃជាញឹកញាប់មានលក្ខណៈដូចគ្នាទៅនឹងប្រភេទខ្លះនៃជំងឺមហារីក។ ជាឧទាហរណ៍ មហារីកសួត និងរបេងសួតមានរោគសញ្ញាដូចគ្នាច្រើន។ ការនេះបង្កើននូវគ្រោះថ្នាក់នៃការចាត់ថ្នាក់ខុស ក្នុងអំឡុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់នៃករណីបែបនេះ។ |
| VA-01.04 | ជំងឺតេតាណូស (មិនរាប់ តេតាណូសលើទារកទើបកើត) | A34<br>A35 | តេតាណូសពេលសម្រាល<br>តេតាណូសផ្សេងទៀត | តេតាណូសនៅលើទារកទើបនឹងកើត ត្រូវគេចាត់ទោ។ ក្រុមដូចគ្នានេះ គួរត្រូវប្រើសំរាប់ការបង្ករោគណាផ្សេងៗទៀត ដែលកើតមាននៅលើទារកទើបនឹងកើត។ |
| VA-01.05 | ក្អកមាន់ | A379 | ក្អកមាន់ មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-01.06 | គ្រុនក្ដៅដោយពួកវីរុសArthropodនិងវិរុសជំងឺគ្រុនឈាម | A90 | គ្រុនក្ដៅដោយវីរុសដាំង (Classical dengue) | |
| | | A91 | គ្រុនឈាមដោយវីរុសដាំង | |
| | | A929 | គ្រុនក្ដៅដោយវីរុស ចំលងដោយមូស មិនបញ្ជាក់ | |
| | | A93 | គ្រុនក្ដៅដោយវីរុស ចំលងដោយពួក Arthropod ផ្សេងទៀត NEC | |
| | | A94 | គ្រុនក្ដៅដោយវីរុសចំលងដោយ Arthropod ដែលគេមិនបញ្ជាក់ | |
| | | A95 | គ្រុន Yellow មិនបញ្ជាក់ | |
| | | A96 | គ្រុនឈាមដោយពួកវីរុស Arenaviral មិនបញ្ជាក់ | |
| | | A98 | គ្រុនឈាមដោយវីរុសពិសេសៗផ្សេងទៀត | |
| | | A99 | ជំងឺគ្រុនឈាមដោយវីរុស ដែលមិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-01.07 | ជំងឺកញ្រ្ជិល | B059 | ជំងឺកញ្រ្ជិល | ជំងឺកញ្រ្ជិល NOS<br>**ពតិមានដែលទាក់ទងះ**<br>ស្បែកកន្ទួលក្រហម (កន្ទួលពងក្រហម ចាប់ផ្ដើមនៅលើមុខ និងបន្តចុះទៅក្រោម និងចេញក្រៅ) ដែលធ្វើអោយគេត្រូវការរោគវិនិច្ឆ័យ<br>គ្រុនក្ដៅ ខ្លាំង<br>ក្អក<br>ភ្នែកហើម ក្រហម<br>មិនបានចាក់ថ្នាំបង្ការជំងឺកញ្រ្ជិល<br>ខ្លាចពន្លឺ |
| VA-01.08 | ពងបែកដោយវីរុស | B159<br>B169<br>B179<br>B189<br>B199 | ជំងឺរលាកថ្លើម A<br>ជំងឺរលាកថ្លើម B ស្រួចស្រាវ<br>ជំងឺរលាកថ្លើមផ្សេងៗទៀតដែលមានបញ្ជាក់<br>រលាកថ្លើមរ៉ាំរ៉ៃដោយវីរុស មិនបញ្ជាក់<br>ជំងឺរលាកថ្លើមដោយវីរុស មិនបញ្ជាក់ | រោគសញ្ញានិងបណ្ដុំរោគសញ្ញារលាកថ្លើមដោយវីរុស គឺវាមិនជាក់លាក់ទេ។ រូបភាពគ្លីនិកមានការប្រែប្រួលខ្លាំងណាស់ ហើយដំរាបណាដែលជំងឺមិនទាន់ផ្ទុះឡើង ជាញឹកញាប់វាមិនមានរោគសញ្ញាទេ ឬរហូតដល់មានផលវិបាកកើតឡើង។ ប្រសិនបើអ្នកដែលគេសំភាស និយាយថាអ្នកជំងឺមានដៃគូដែលមានជំងឺរលាកថ្លើម B វាអាចនឹងជួយអោយយើងឈានដល់រោគវិនិច្ឆ័យ។ |
| VA-01.09 | HIV/AIDS | B209<br><br>B219 | ជំងឺ HIV អោយផលជាការបង្ករោគ ដោយមិនជាក់លាក់ ឬ ជំងឺដោយពពួកប៉ារ៉ាសិត<br><br>ជំងឺ HIV អោយផលជាដុំមហារីក ដោយមិនជាក់លាក់ | ជំងឺ HIV/AIDS អាចបណ្ដាលជាដុំមហារីកជាក់លាក់នានា (ឧទា. Kaposi sarcoma)។ ក្នុងករណីបែបនេះ គេគួរដាក់កូដវានៅទីនេះ និង នៅក្នុង ICD-10 ដោយប្រើប្រាស់ប្រភេទសមស្រប នៅក្នុង B21។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| | | B227 | ជំងឺ HIV អោយផលជាពហុជំងឺដែលគេចាត់ នៅកន្លែងផ្សេង | |
| | | B238 | ជំងឺ HIV អោយផលជាជំងឺនៅក្នុងលក្ខ័ខណ្ឌ័ផ្សេងទៀត | |
| | | B24 | ជំងឺ HIV មិនជាក់លាក់ | |
| VA-01.10 | ជំងឺគ្រុនចាញ់ | B509 | ជំងឺគ្រុនចាញ់ដោយប្លាស់ស្ចូដ្យូមហ្វាល់ស៊ីប៉ារ៉ូម មិនបញ្ជាក់ | **ពតិមានដែលទាក់ទង:**<br>ក្តៅខ្លាំង<br>ក្តៅ ត្រជាក់ៗ<br>សន្លប់<br>ទឹកនោមខ្មៅ<br>ប្រកាច់<br>នោមតិច<br>ចង្អោរ<br>រងាញាក់ |
| | | B50.0<br>B519<br>B529<br>B538<br>B24 | គ្រុនចាញ់ប៉ះពាល់ខួរក្បាល<br>ជំងឺគ្រុនចាញ់ដោយវីវ៉ាក់<br>ជំងឺគ្រុនចាញ់ដោយពួកម៉ាឡារីយ៉ា<br>ជំងឺគ្រុនចាញ់ដោយមានការបញ្ជាក់ប៉ារ៉ាស៊ីត ផ្សេងទៀត<br>ជំងឺគ្រុនចាញ់ដោយមិនបញ្ជាក់ | |
| VA-01.10 | Leishmaniasis | B559 | Leishmaniasis ដែលមិនបញ្ជាក់ | |
| VA-01.11 | រលាកស្រោមខួរ | G009<br>G039 | រលាកស្រោមខួរដោយបាក់តេរី មិនបញ្ជាក់<br>រលាកស្រោមខួរបណ្តាលពីជំងឺផ្សេងទៀត មូលហេតុមិនបញ្ជាក់ | ជំងឺខួរក្បាលផ្សេងទៀតដែលគេឃើញមាននៅក្នុង VA-04.03 និង VA-08 |

| កូដកោសល្យវិច័យផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| | | G049 | រលាកខួរក្បាល រលាកខួរឆ្អឹង និងរលាកខួរក្បាល និងខួរឆ្អឹង មិនបញ្ជាក់ | ការបង្ករោគខ្លះអាចស្តែងឡើងដោយរលាកស្រោមខួរ ឬរលាកខួរក្បាល តែនៅក្នុងករណីទាំងនេះ ការនិយាយពីការបង្ករោគគឺវាជាក់លាក់ជាងការនិយាយថារលាកស្រោមខួរ។ សំរាប់បញ្ជីលំអិតនៃជំងឺទាំងនេះ ចូរមើល "កូដរូប កូនកាំបិត" (†) ដែលលើកឡើងនៅក្នុង ICD-10 ក្នុង G02* និង G05*<br>**ពតិមានដែលទាក់ទង:**<br>ឈឺក្បាល<br>រឹងក<br>ឈឺក<br>គ្រុនក្តៅ<br>ក្អួត<br>ប្រកាច់<br>ភ្លឹក<br>មិនមានធ្លាក់ ឬរបួសក្បាលឡើយ |
| VA-01.12 | ជំងឺផ្តាសាយ | J09 | ផ្តាសាយដែលបណ្តាលមកពីវីរុស Avian influenza ដែលគេកំណត់ ឃើញ | |
| | | J109 | ផ្តាសាយដែលបណ្តាលមកពីវីរុសដែលគេកំណត់ឃើញ ផ្សេងៗទៀត | |
| | | J119 | ផ្តាសាយដែលមិនបញ្ជាក់វីរុស | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-01.13 | ការបង្ករោគផ្លូវដង្ហើមខាងក្រោមស្រួចស្រាវ (រាប់ទាំងរលាកសួត និងរលាកទងសួតស្រួចស្រាវ) | J129 | រលាកសួតដោយវីរុស មិនបញ្ជាក់ | ការបង្ករោគផ្លូវដង្ហើមផ្សេងទៀត ត្រូវតែរ៉ាយរ៉ាប់នៅក្នុង VA-05.02 ។<br>**ពតិមានដែលទាក់ទងៈ**<br>ក្អកតិចជាង៣សប្តាហ៍ |
| | | J159 | រលាកសួតដោយបាក់តេរី មិនបញ្ជាក់ | គ្រុនក្តៅ |
| | | J180 | រលាកសួតទងសួតដោយបាក់តេរី មិនបញ្ជាក់ | ពិបាកដកដង្ហើមតិចជាង ៣ សប្តាហ៍ |
| | | J181 | រលាកក្លែបសួត មិនបញ្ជាក់ | កើនកំហាកតិចជាង ៣ សប្តាហ៍ |
| | | J182 | រលាកសួតដោយដេកនៅលើគ្រែយូរ មិនបញ្ជាក់ | កំហាកខ្ទុះតិចជាង ៣ សប្តាហ៍ |
| | | J189 | រលាកសួត មិនបញ្ជាក់ | ឈឺទ្រូង<br>ហើម |
| VA-01.98 | ជំងឺឆ្លងនិងប៉ារ៉ាស៊ីត ដែលគេបានបញ្ជាក់ផ្សេងៗទៀត | B889 | ការរំខានស្បែងឡើង មិនបញ្ជាក់ | |
| VA-01.99 | ជំងឺឆ្លង មិនបញ្ជាក់ | B99 | ជំងឺឆ្លងផ្សេងៗទៀត និងមិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02 | ដុំមហារីក | | | |
| VA-02.01 | ដុំមហារីកបបូរមាត់ ក្រអូមមាត់ និងបំពង់ក | C002<br>C005<br>C009<br>C029<br>C039<br>C049<br>C059<br>C069<br>C089<br>C099<br>C109<br>C119 | មហារីក: បបូរមាត់ក្រៅ មិនបញ្ជាក់<br>មហារីក: បបូរមាត់ មិនបញ្ជាក់ ទិដ្ឋភាពខាងក្នុង<br>មហារីក: បបូរមាត់ មិនបញ្ជាក់<br>មហារីក: អណ្តាត មិនបញ្ជាក់<br>មហារីក: អញ្ចាញធ្មេញ មិនបញ្ជាក់<br>មហារីក: បាតមាត់ មិនបញ្ជាក់<br>មហារីក: ក្រអូមលើ មិនបញ្ជាក់<br>មហារីក: មាត់ មិនបញ្ជាក់<br>មហារីក: ក្រពេញទឹកមាត់ មិនបញ្ជាក់<br>មហារីក: អាមីដាល់ មិនបញ្ជាក់<br>មហារីក: មាត់-បំពង់ក មិនបញ្ជាក់<br>មហារីក: ច្រមុះ-បំពង់ក មិនបញ្ជាក់ | ទិដ្ឋភាពជាក់លាក់ដែលត្រូវយកចិត្តទុកដាក់ នៅពេលដាក់កូដមហារីកគឺ:<br>▪ ទីតាំងរបស់ដុំ<br>▪ លក្ខណ:របស់ដុំ<br>តារាងនៃមហារីកមាននៅក្នុងភាគទី៣ នៃ ICD-10 ។ វាមានកូដសំរាប់ទីតាំងកាយវិភាគនិមួយៗនៃដុំ ។ សំរាប់ទីតាំងនិមួយៗ វាអាចមានកូដ៥ ដែលចែកទៅតាមលក្ខណ:របស់ដុំ ។<br>ប្រសិនបើរោគវិនិច្ឆ័យដែលអ្នកដាក់កូដ មិនអាចអោយគេពិពណ៌នាពីលក្ខណ:របស់ដុំបានទេនោះ អ្នកគួរមើលទៅលើការពណ៌នាពីរូបរាង ។ វានឹងផ្តល់ការណែនាំ ថាតើដុំមួយគួរត្រូវដាក់កូដបែបម៉េច (ឧទា. មហារីកប្រដាប់បន្តពូជស្ត្រី (Mesonephroma) ចូរមើល ដុំមហារីក) ។ អ្នកគួរប្រើកូដសំរាប់ដុំមហារីកផ្ទាល់ និងមិនផ្ទាល់ អាស្រយ័ទៅលើរោគវិនិច្ឆ័យ ។<br>ក្នុងពេលកោសល្យវិច័យផ្ទាល់មាត់ ពតិមានអំពីរូបរាង វាប្រហែលជាមិនមានទេ ។ ក្នុងករណីនេះ អ្នកត្រូវចាត់កូដ "មិនប្រាកដ ឬ មិនដឹង" អំពីលក្ខណ:សំរាប់ទីតាំងដែលបានបញ្ជាក់ ។<br>ប្រសិនបើអ្នកដឹងថាដុំនោះជាដុំមហារីក ហើយអ្នកមិនអាចកំណត់ទីតាំង ចូរប្រើកូដ C80 ។<br>ប្រសិនបើអ្នកមិនដឹងទាំងលក្ខណ: និងទាំងទីតាំង ចូរប្រើកូដ D48.9 "មហារីកដែលមិនប្រាកដ ឬមិនដឹងលក្ខណ: មិនជាក់លាក់" ។<br>ដុំខ្លះអាចមើលទៅដូចជាការខុសរូបរាងពីកំណើត ។ រោគសញ្ញាចំមួយចំនួនរបស់ដុំគឺ: ដុះដាល ឬផ្លាស់ប្តូររូបរាងរបស់ដុំ និងស្រកទំងន់ ។ |

| | | | | |
|---|---|---|---|---|
| | | | | HIV/AIDS អាចបណ្ដាលជាមហារីកជាក់លាក់នានា (ឧទា. Kaposi sarcoma) ក្នុងករណីបែបនេះ គេគួរតែកូដវា VA-1.8 និងនៅក្នុង ICD-10 ទៅក្នុងប្រភេទសសមស្រប នៅក្រោម B21 ។ |
| | | C139 | មហារីក: បំពង់ខ្យល់ផ្នែកខាងក្រោម មិនបញ្ជាក់ | |
| | | C140 | មហារីក: បំពង់ខ្យល់ មិនបញ្ជាក់ | |
| VA-02.02 | មហារីកបំពង់ក | C159 | មហារីក: បំពង់ក មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ពិបាកលេបអាហាររឹង<br>ស្រកទំងន់<br>ស្អកៗ<br>អស់កំលាំង |
| VA-02.03 | មហារីកក្រពះ | C165 | មហារីក: កំណាងតូចនៃក្រពះ មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ដុំនៅក្នុងពោះខាងលើ<br>ឈឺនៅពោះខាងលើ លើសពី ៣ សប្ដាហ៍<br>ស្រកទំងន់<br>ក្អួតក្រោយបរិភោគ លើសពី ៣ សប្ដាហ៍<br>ឆាប់ឆ្អែត<br>អស់កំលាំង |
| | | C166 | មហារីក: កំណោងធំនៃក្រពះ មិនបញ្ជាក់ | |
| | | C169 | មហារីក: ក្រពះ មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02.04 | មហារីកពោះវៀនតូច ពោះវៀនធំ | C179 | មហារីក: ពោះវៀនតូច មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ដុំនៅក្នុងពោះ<br>ពិបាកជុះ លើសពីពាសប្តាហ៍<br>ផ្លាស់ប្តូរទំលាប់ជុះ<br>កើនភាពរាវ (ឬចំនួនដង លើសពីពដងក្នុង១ថ្ងៃ) នៃលាមក ក្នុងរយៈលើសពី ពាសប្តាហ៍ ឆ្លាស់គ្នានឹងទល់លាមក<br>លាមកខ្មៅដូចកៅស៊ូថ្នល់<br>ស្រកទំងន់<br>ឈឺពោះ (ចុក)<br>ស្លេកស្លាំង<br>អស់កំលាំង |
| | | C189 | មហារីក: ពោះវៀនធំ មិនបញ្ជាក់ | |
| VA-02.05 | មហារីកចុងពោះវៀនធំ និងរន្ធគូទ | C19 | មហារីកនៃតំណចុងពោះវៀនធំនិងរន្ធគូទ | |
| | | C20 | មហារីកចុងពោះវៀនធំ | |
| | | C210 | មហារីក: រន្ធគូទ មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ដំបៅគូទនៅស្ថិតស្ថេរ<br>ដុំរន្ធគូទ<br>ឈឺរន្ធគូទ<br>ពិបាកជុះ លើសពីពាសប្តាហ៍<br>ស្រកទំងន់ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02.06 | មហារីកថ្លើម និងបំពង់ថ្លើម | C229 | មហារីក: ថ្លើម មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ដុំក្នុងពោះ (ផ្នែកខាងលើ)<br>ដុំក្នុងពោះដុះដាលយ៉ាងរហ័ស (ផ្នែកខាងលើ)<br>ឈឺពោះ (ចំហៀងខាងឆ្វេង) ខ្លាំង ជាប់ជានិច្ច<br>ទាច<br>ស្រកទំងន់<br>អស់កំលាំង<br>ភ្នែកលឿង<br>ស្បែកលឿង<br>រមាស់ស្បែក<br>ឈឺចាប់ (ពោះផ្នែកលើខាងស្តាំ ចាក់ទៅខ្នង) |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02.07 | មហារីក បំពង់ខ្យល់ ទងសួត និង សួត | C33<br><br>C349 | មហារីកបំពង់ខ្យល់<br><br>មហារីកទងសួត ឬសួត មិនបញ្ជាក់ | ដុំត្រូវគេដាក់កូដ ក្រោម VA-02.07 អាចនឹងបណ្តាលអោយមានរោគសញ្ញាដូចគ្នា នឹងការបង្ករោគនៅក្នុងផ្នែកនេះនៃរាង្គកាយ ។<br>រយៈពេលក្អក អាចអោយអ្នកសំភាស បែងចែករវាងការបង្ករោគ និង ដុំ<br>**ពតិមានទាក់ទង:**<br>ក្អកលើស ៤ សប្តាហ៏<br>ពិបាកដងដង្ហើម លើសពី ៤ សប្តាហ៏<br>ស្រកទំងន់<br>ឈាមក្នុងកំហាក<br>ឈឺទ្រូង<br>ប្រវត្តិជក់បារី<br>ស្អក<br>ពិបាកបើកភ្នែកម្ខាង<br>ហើមក្បាល និងក<br>ឈឺក្បាល<br>អស់កំលាំង |

| **កូដកោសល្យវិច័យ ផ្ទាល់មាត់** | **ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់** | **កូដ ICD-10** | **ចំណងជើង ICD-10** | **អធិប្បាយ** |
| --- | --- | --- | --- | --- |
| VA-02.08 | មហារីកដោះ | C509 | មហារីកដោះ មិនបញ្ជាក់ | **ពតិមានទាក់ទងៈ**<br>ដុំដោះ<br>ដំបៅស្បែកដោះ លើសពី ៣ សប្តាហ៏<br>ដំបៅក្បាលដោះ លើសពី ៣ សប្តាហ៏<br>ស្បែកដោះឡើងក្រហម ឈឺ លើសពី ៣ សប្តាហ៏<br>ស្រកទំងន់<br>ប្រទាញស្បែកក្បាលដោះ<br>ហូរទឹកតាមក្បាលដោះ<br>អស់កំលាំង |
| VA-02.09 | មហារីកកស្បូន | C539 | មហារីកកស្បូន មិនបញ្ជាក់ | **ពតិមានទាក់ទងៈ**<br>ធ្លាក់ឈាមតាមទ្វារមិនទៀងទាត់<br>ដុំក្នុងពោះផ្នែកខាងក្រោម<br>ហៀរទឹកតាមទ្វារមាស លើសពី ៣ សប្តាហ៏ (ឈាម/ខ្ទុះ មិនរមាស់)<br>ឈឺពោះផ្នែកខាងក្រោម<br>ស្រកទំងន់<br>ឆាប់រួមភេទ<br>មានដៃគូច្រើន<br>អស់កំលាំង<br>ឈឺខ្នង (ខ្លាំង) |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02.10 | មហារីកសួន (មិនរាប់កសួន) | C55 | មហារីកស្បូន ផ្នែក មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ធ្លាក់ឈាមតាមទ្វារមិនទៀងទាត់<br>ធ្លាក់ឈាមនៅលើស្ត្រីដែលអស់រដូវ<br>ដុំក្នុងពោះផ្នែកខាងក្រោម<br>ឈឺពោះផ្នែកខាងក្រោម<br>ស្រកទំងន់<br>អាយុលើសពី ៤៥ឆ្នាំ<br>មិនទាន់មានកូន<br>អស់កំលាំង |
| VA-02.11 | មហារីកអូវែរ | C56 | មហារីកអូវែរ | **ពតិមានទាក់ទង:**<br>ដុំក្នុងពោះផ្នែកខាងក្រោម<br>ដុំនៅចំហៀងពោះខាងក្រោម<br>ទាច (ទឹកក្នុងពោះ កើនរង្វង់ពោះ)<br>ឈឺពោះផ្នែកខាងក្រោម<br>ស្រកទំងន់<br>តឹងក្នុងអាងត្រគាក<br>អាយុចាស់ |
| VA-02.12 | មហារីកក្រពេញប្រូស្តាត | C61 | | |
| VA-02.13 | មហារីកស្បែក | C43 | | |
| VA-02.14 | មហារីកកូនកណ្តុរ ជាលិកាបង្កើតគ្រាប់ឈាម និងជាលិកាពាក់ពន្ធ័ | C96.9 | មហារីកកូនកណ្តុរ ជាលិកាបង្កើតគ្រាប់ឈាម និងជាលិកាពាក់ពន្ធ័ | |
| VA-02.98 | ដុំមហារីកជាក់លាក់ផ្សេងៗទៀត | | មិនមានប្រភេទនេះនៅក្នុង ICD ឡើយ | ចូរជ្រើសយកកូដសមស្របជាមួយនឹងជំនួយនៃលិបិក្រម ICD |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-02.99 | មហារីកដែលមិនប្រាកដ ឬ មិនដឹងលក្ខណៈ មិនបញ្ជាក់ | D489 | មហារីកដែលមិនប្រាកដ ឬ មិនដឹងលក្ខណៈ នៃទីតាំងដទៃ និង មិនបញ្ជាក់ | |
| VA-03 | វិបល្លាសអាហារូបត្ថម្ភ និង ក្រពេញ អង់ដូគ្រីន | | | វិបល្លាសអង់ដូគ្រីនមានជំងឺផ្សេងៗដែលមួយៗមានកត្តាជាក់លាក់នានា។ ជំងឺដែលទាក់ទងនឹងសារៈសំខាន់នៃសុខភាពសាធារណៈ មានរាយបញ្ជីនៅក្នុងប្រភេទជាក់លាក់នៃប្រពន្ធ័ចំណាត់ថ្នាក់មរណៈភាព របស់ VA (ឧទា.ជំងឺទឹកនោមផ្អែមប្រភេទទី ២)។ ជំងឺអង់ដូគ្រីនផ្សេងទៀតមួយចំនួន អាចនឹងចាត់នៅក្នុង "ជំងឺអង់ដូគ្រីនជាក់លាក់ផ្សេងៗទៀត"។ |
| VA-03.01 | ស្លេកស្លាំងដោយបញ្ហាអាហារូបត្ថម្ភ | D509<br>D519<br>D529<br>D539 | ស្លេកស្លាំងដោយកង្វះជាតិដែក មិនបញ្ជាក់<br>ស្លេកស្លាំងដោយកង្វះវីតាមីន B12 មិនបញ្ជាក់<br>ស្លេកស្លាំងដោយកង្វះជាតិហ្វូលិក មិនបញ្ជាក់<br>ស្លេកស្លាំងដោយអាហារូបត្ថម្ភ មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ស្បែកស្លេក<br>ភ្នាសស្លេក<br>បាតដៃស្លេក<br>ពិបាកដកដង្ហើម<br>វិលមុខ<br>ញ័រទ្រូង<br>ឆាប់អស់កំលាំង |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណាងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-03.02 | កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ | E40<br>E41<br>E42<br>E43 | កង្វះជាតិប្រូតេអ៊ីន (Kwashiorkor)<br>កង្វះកាឡូរី (Nutritional marasmus)<br>កង្វះកាឡូរីប្រូតេអ៊ីន Marasmic kwashiorkor<br>កង្វះកាឡូរីប្រូតេអ៊ីនធ្ងន់ធ្ងរ មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ថយចុះការបរិភោគអាហារ<br>បញ្ឈប់ការបំបៅដោះ<br>ទាច<br>សក់ឡើងក្រហម<br>ហើមជើង<br>របកស្បែក<br>ស្គមខ្លាំងណាស់<br>តូចខ្លាំងណាស់<br>ពិបាកផ្តល់អាហារ |
| VA-03.03 | ជំងឺទឹកនោមផ្អែម mellitus | E10<br>E11<br>E12<br>E13<br>E14 | ទឹកនោមផ្អែម mellitus អាស្រ័យជាតិអាំងស៊ុលីន<br>ទឹកនោមផ្អែម mellitus មិនអាស្រ័យអាំងស៊ុលីន<br>កង្វះអាហារូបត្ថម្ភទាក់ទងនឹងទឹកនោមផ្អែម mellitus<br>ទឹកនោម មលេលិតុស ដែលគេបញ្ជាក់ផ្សេងៗទៀត<br>ទឹកនោមផ្អែម mellitus មិនបញ្ជាក់ | នៅក្នុង ប្លុកជំងឺទឹកនោមផ្អែម mellitus ( E10-E14) ប្រើ ជំងឺទឹកនោមផ្អែម mellitus អាស្រ័យជាតិអាំងស៊ុលីន និងមិនអាស្រ័យជាតិអាំងស៊ុលីន ដែលជាពាក្យដែលគេចូលចិត្ត។ ជាមួយនឹងការវិវឌ្ឍន៍នៃវិទ្យាសាស្រ្តវេជ្ជសាស្រ្ត ការប្រើប្រាស់ពាក្យត្រូវបានផ្លាស់ប្តូរ។ ជំងឺទឹកនោមប្រភេទ១ គឺស្មើនឹងជំងឺទឹកនោមផ្អែម mellitus អាស្រ័យជាតិអាំងស៊ុលីន ហើយប្រភេទ២ គឺស្មើនឹងជំងឺទឹកនោមផ្អែម mellitus មិនអាស្រ័យជាតិអាំងស៊ុលីន។ ផលវិបាកនៃជំងឺទឹកនោមផ្អែម ត្រូវគេកំណត់នៅក៏រិតតួអក្សរទី៤។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-03.98 | វិបល្លាសអង់ដូគ្រីន ដែលគេបញ្ជាក់ផ្សេង ទៀត | E348 | វិបល្លាសអង់ដូគ្រីន ដែលគេបញ្ជាក់ផ្សេង ទៀត | វិបល្លាសមេតាបូលីសផ្សេងៗ ទៀត ត្រូវគេចាត់ទៅក្នុង VA-98 លើកលែងតែ សំរាប់ជំងឺដែលទាក់ទងនឹងផ្ទៃពោះ ( VA-09.-) ឬ វិបល្លាសនៅលើក្មេងទើបនឹងកើត ( VA-10.-) ។<br>វិបល្លាសអង់ដូគ្រីនផ្សេងៗទៀត ត្រូវគេបញ្ជាក់នៅក្នុង នៅប្លុក E20-E35 ។ |
| VA-03.99 | វិបល្លាសអង់ដូគ្រីន មិនបញ្ជាក់ | E349 | វិបល្លាសអង់ដូគ្រីន មិនបញ្ជាក់ | |
| VA-04 | ជំងឺនៃប្រពន្ធ័សរសៃឈាម | | | ក្រុមនេះគ្របដណ្តប់សរីរាង្គ និង ប្រពន្ធ័ដែលទាក់ទងនឹងចរន្តឈាម និង លសិកា (Lymph) តែមិនមែនឈាមខ្លួនវាទេ ។ ជំងឺស្លេកស្លាំងត្រូវគ្របដណ្តប់នៅក្នុងក្រុម VA-3 ។ ជំងឺឈាមភាគច្រើន ត្រូវគេចាត់នៅ VA-98 ។ ដុំឈាម ត្រូវគេចាត់នៅ VA-2 ។ |
| VA-04.01 | ជំងឺលើសឈាម | I10<br>I11.9<br>I12.9<br>I13.9<br>I15.9 | លើសឈាមដោយសារជំងឺបេះដូង និង ជំងឺវក្កំ មិនបញ្ជាក់<br>លើសឈាមដោយជំងឺបេះដូង NOS<br>លើសឈាមដោយជំងឺវក្កំ NOS<br>លើសឈាមដោយសារជំងឺបេះដូង និង ជំងឺវក្កំ មិនបញ្ជាក់<br>លើសឈាមបណ្តាលមកពីជំងឺដំទៃ មិនបញ្ជាក់ | បញ្ជាក់: លើសឈាមទាក់ទងនឹងផ្ទៃពោះ ត្រូវគេកូដនៅក្នុង VA-09.02 ។<br>**ពតិមានទាក់ទង:**<br>ពិបាកដកដង្ហើម លើសពី៤សប្តាហ៍ (ពិបាកដងដង្ហើម)<br>ពិបាកដកដង្ហើម ក្នុងស្ថានភាពដេក<br>ដង្ហើមមានសំលេង<br>ហើមកជើង ឬជើង<br>ប៉ោងសរសៃវ៉ែននៅក<br>ទាចទឹក<br>ក្អក<br>កើននោមពេលយប់<br>អត់ធ្វើលំហាត់ប្រាណ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-04.02 | ជំងឺបេះដូងដោយស្ទះសរសៃឈាម | I209<br>I219<br><br>I249<br>I259 | ចុកទ្រូង មិនបញ្ជាក់<br>រលួយសាច់បេះដូងដោយស្ទះសរសៃឈាម ស្រួចស្រាវ មិនបញ្ជាក់<br>ស្ទះសរសៃឈាម ស្រួចស្រាវ មិនបញ្ជាក់<br>ស្ទះសរសៃឈាម រ៉ាំរ៉ៃ មិនបញ្ជាក់ | VA-04.02 (ឬ I209 នៅក្នុង ICD-10) ប្រើនៅក្នុងទំរង់ដែលគំរាមកំហែងជីវិតនៃការចុកទ្រូង។ |
| VA-04.03 | ជំងឺសរសៃឈាមបេះដូង | I679<br>I607<br><br>I609<br>I612<br><br>I619<br>I629<br>I639<br>I698 | ជំងឺសរសៃឈាមបេះដូង មិនបញ្ជាក់<br>ហូរឈាមស្រទាប់ខួរក្បាល មកពីសរសៃឈាមក្នុងខួរក្បាល មិនបញ្ជាក់<br>ហូរឈាមស្រទាប់ខួរក្បាល មិនបញ្ជាក់<br>ហូរឈាមក្នុងខួរក្បាល ក្នុងប្រអប់ខួរម្ខាង មិនបញ្ជាក់<br>ហូរឈាមក្នុងខួរក្បាល មិនបញ្ជាក់<br>ហូរឈាមក្នុងខួរក្បាល (មិនប៉ះទង្គិច) មិនបញ្ជាក់<br>ស្លាប់កោសិកាខួរក្បាល មិនបញ្ជាក់<br>ជំងឺសរសៃឈាមខួរក្បាល ដោយសំណល់ពីជំងឺដទៃ និងមិនជាក់លាក់ | ជំងឺផ្សេងទៀតនៃខួរក្បាល ត្រូវគេចាត់ទៅក្នុង VA-08.02។<br>**ពតិមានទាក់ទង:**<br>មិនអាចកំរើកដៃបានភ្លាមៗ និង/ឬ ជើង ម្ខាង<br>ដៃខ្សោយកំលាំងភ្លាមៗ និង/ឬ ជើង ម្ខាង<br>ភាពដឹងនៃវិញ្ញាណផ្លាស់ប្តូរភ្លាមៗ<br>ពិការមុខមួយចំហៀងភ្លាមៗ<br>វង្វេង<br>ឈឺក្បាល<br>បាត់សំលេងភ្លាមៗ<br>សន្លប់<br>អាយុលើសពី ៤៥ឆ្នាំ<br>មានលើសឈាម<br>ជាអ្នកជក់បារី<br>ស្រកទំងន់<br>មិនមានរបួសក្បាល (លើកលែងកំណកឈាមនៅបាតក្បាល)។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-04.04 | ជំងឺបេះដូងដោយជំងឺសន្លាក់រ៉ាំរ៉ៃ | I059<br>I069<br>I079<br>I089<br>I099 | ជំងឺសន្ទះមីត្រាលរបស់បេះដូង មិនបញ្ជាក់<br>ជំងឺសន្ទះអាអ័ករបស់បេះដូងដោយឈឺសន្លាក់ មិនបញ្ជាក់<br>ជំងឺសន្ទះជើងបីរបស់បេះដូង មិនបញ្ជាក់<br>ជំងឺសន្ទះច្រើនរបស់បេះដូង មិនបញ្ជាក់<br>ជំងឺបេះដូងដោយជំងឺសន្លាក់រ៉ាំរ៉ៃ មិនបញ្ជាក់ | កូដជំងឺសន្ទះបេះដូងពីកំណើត ឃើញនៅក្នុង VA-98 និង ICD-10ជំពូក XVII (ពិការភាពពីកំណើត ខូចទ្រង់ទ្រាយ និង ភាពមិនប្រក្រតីនៃក្រូម៉ូសូម) កូដសំរាប់ជំងឺបេះដូងដោយសារជំងឺសន្លាក់ រកឃើញនៅក្នុង VA-98 និង ICD-10 ប្រភេទ M053 ។ |
| VA-04.05 | បេះដូងបាក់កំលាំងដោយការជញ់ (Congestive heart failure) | I500 | បេះដូងបាក់កំលាំងដោយការជញ់ | " បេះដូងបាក់កំលាំង" គួរតែប្រើតែពេលណាដែលមានភស្តុតាងច្បាស់ ដែល ថា បញ្ហាបេះដូង គឺជាមូលហេតុស្លាប់ ។ ប្រសិនបើនេះមិនមែនជាករណី ទេ នោះ គេចូលចិត្ត VA-99 ជាង ។ |
| VA-04.98 | ជំងឺដែលគេបញ្ជាក់ផ្សេងទៀតនៃប្រពន្ធ័សរសៃឈាម | | ចូរជ្រើសយកប្រភេទសមស្របចេញពី ICD | " បេះដូងឈប់ដើរ" គួរតែប្រើតែពេលណាដែលមានភស្តុតាងច្បាស់ ដែល ថា បញ្ហាបេះដូង គឺជាមូលហេតុស្លាប់ ។ ប្រសិនបើនេះមិនមែនជាករណី ទេ នោះ គេចូលចិត្ត VA-99 ជាង ។<br>រាល់កិច្ចខឹតខំប្រឹងប្រែងគួរតែធ្វើឡើងដើម្បីកំណត់ហេតុផលសំរាប់គាំងបេះដូង ។ វាជាការសំខាន់ ក្នុងការកត់សំគាល់ថា លក្ខខណ្ឌណាក៏ដោយដែលបណ្តាលអោយស្លាប់ ដែលក្រោយមកជាហេតុនៃការគាំងបេះដូង ។ ការចែងវានៅក្នុងរបាយការណ៍ស្ថិតិ គឺវាជួយបានតិចណាស់ ក្នុងការសំរេចចិត្តលើវិធានការ ក្នុងការធ្វើអោយប្រសើរឡើងនូវសុខភាព ។<br>អ្នកអាចនឹងប្រើប្រភេទនេះ ដើម្បីដាក់កូដជំងឺនៃសរសៃឈាម ។<br>ចូរកត់សំគាល់ថា Dracunculiasis (ជំងឺ Guinea-worm) គួរត្រូវកូដនៅក្រោមជំងឺឆ្លង ។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-04.99 | ជំងឺនៃប្រពន្ធ័ចរន្តឈាម មិនបញ្ជាក់ | I99 | វិបល្លាសផ្សេងទៀត និង មិនបញ្ជាក់ នៃប្រពន្ធ័ចរន្តឈាម | |
| VA-05 | វិបល្លាសប្រពន្ធ័ដង្ហើម | | | ក្រុមនេះសំដៅដល់ជំងឺនិងវិបល្លាសនៃសរីរាង្គដង្ហើម និងភ្នាក់ងារខាងក្រៅមួយចំនួន ដូចជាពួកដែលមកពីការប្រឈមវិជ្ជាជីវៈ ។ |
| VA-05.01 | ជំងឺសួតបណ្តាលមកពីការស្ទះរ៉ាំរ៉ៃ | J40<br>J41<br>J42<br>J439<br>J441<br><br>J449<br>J47 | រលាកសួតទងសួត មិនបញ្ជាក់ថាស្រួចស្រាវឬរ៉ាំរ៉ៃ<br>រលាកទងសួតរ៉ាំរ៉ៃ សាមញ្ញ និងសំបោរខ្ទុះ<br>រលាកទងសួតរ៉ាំរ៉ៃ មិនបញ្ជាក់<br>ជុញខ្យល់ក្នុងសាច់សួត (Emphysema)<br>មិនបញ្ជាក់<br>ជំងឺសួតបណ្តាលមកពីការស្ទះរ៉ាំរ៉ៃ ជាមួយនឹងរើ<br>ឡើងស្រួចស្រាវ មិនបញ្ជាក់<br>ជំងឺសួតបណ្តាលមកពីការស្ទះរ៉ាំរ៉ៃ មិនបញ្ជាក់<br>រីកទងសួត (Bronchiectasis) | ពតិមានទាក់ទងៈ<br>ពិបាកដកដង្ហើមលើសពី ២១ថ្ងៃ<br>ក្អកភាគច្រើននៅពេលវេលានៃឆ្នាំ លើសពី ២ ឆ្នាំ<br>កំហាក<br>ជក់<br>ដកដង្ហើមឮសំលេង<br>រីកទំហំទ្រូង<br>ជំងឺរីរៃវឡ្បដោយយឺតៗ<br>ស្រកទំងន់<br>ស្បែកពណ៌ខៀវព្រឿងៗ |
| VA-05.02 | ហឺត | J45.9<br>J46 | ហឺត មិនបញ្ជាក់<br>សភាពដូចហឺត | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-05.03 | ជំងឺដែលគេបញ្ជាក់ផ្សេងទៀត នៃប្រពន្ធ័ដង្ហើម | J988 | វិបល្លាសដង្ហើម ដែលគេបញ្ជាក់ផ្សេងៗទៀត<br><br>ចូរចាត់កូដដែលកាន់តែជាក់លាក់ នៅពេលដែលមានពតិ មានច្រើន | ការឆ្លងរោគផ្លូវដង្ហើម ត្រូវបានដកចេញពីក្រុមនេះ។ ពួកគេរ៉ាយរ៉ាប់នៅក្នុង VA-1។<br>នៅក្នុង ICD-10 ការឆ្លងរោគផ្លូវដង្ហើមមួយចំនួន ដូចជារលាកសួត គឺជាផ្នែកនៃជំពូក X (ជំងឺនៃប្រពន្ធ័ផ្លូវដង្ហើម)។<br>រលាកសួតត្រូវបានដាក់នៅក្នុងក្រុម VA-01.02។<br>ដុំនៃប្រពន្ធ័ផ្លូវដង្ហើមត្រូវគេចាត់ទៅក្នុងក្រុម VA-2.-។ |
| VA-05.98 | បរាជ័យផ្លូវដង្ហើម មិនបានចាត់នៅកន្លែងដ៏ទៃ | J969 | បរាជ័យផ្លូវដង្ហើម មិនបញ្ជាក់ | កិច្ចខិតខំប្រឹងប្រែងគួរត្រូវធ្វើឡើងដើម្បីបញ្ជាក់ហេតុផលសំរាប់បរាជ័យផ្លូវដង្ហើម។ លក្ខ័ខណ្ឌណាក៏ដោយដែលបណ្តាលការស្លាប់ យូរមកវានឹងបង្កបរាជ័យផ្លូវដង្ហើម។<br>ថប់ដង្ហើមនៃទារកទើបនឹងកើត ត្រូវដាក់ក្នុងក្រុម VA-10.05។<br>ការនេះមិនគួរច្រឡំនឹងកូដ R99 នៃ ICD-10 (មូលហេតុស្លាប់កំណត់មិន ល្អ ដោយរាប់ទាំង ឧទាហរណ៍ ឈប់ដកដង្ហើម) ឬ VA-99។ |
| VA-05.99 | វិបល្លាស ផ្លូវដង្ហើម មិនបញ្ជាក់ | J989 | វិបល្លាស ផ្លូវដង្ហើម មិនបញ្ជាក់ | |
| VA-06 | វិបល្លាសក្រពះពោះវៀន | | | បំពង់ពោះវៀនចាប់ផ្តើមដោយធ្មេញនិងចប់ដោយរន្ធគូទ។ សំរាប់ហេតុផលនេះ បន្ថែមទៅនឹងជំងឺធ្មេញនិងមាត់ ជំងឺទាំងឡាយដែលទាក់ទងទៅនឹងក្រពះ ពោះវៀន និង ថ្លើម ត្រូវគេរៀបរាប់នៅទីនេះ។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-06.01 | ដំបៅក្រពះ និង ឈ្នាប់ក្រពះនឹងពោះវៀន (Gastric and duodenal ulcer) | K259<br>K269<br>K279 | ដំបៅក្រពះ មិនបញ្ជាក់ថាជាស្រួចស្រាវឬរ៉ាំរ៉ៃ គ្មាន ហូរឈាម ឬធ្លាយ<br>ដំបៅ Duodenal មិនបញ្ជាក់ថាជា ស្រួចស្រាវឬរ៉ាំរ៉ៃ គ្មាន ហូរឈាម ឬធ្លាយ<br>ដំបៅ Peptic មិនបញ្ជាក់ថាជា ស្រួចស្រាវឬរ៉ាំរ៉ៃ គ្មា ហូរឈាម ឬធ្លាយ | **ពតិមានទាក់ទង:**<br>ឈឺចាប់នៅចុងដង្ហើម (ក្រពះ)<br>ក្អួតឈាម<br>ក្អួតកំអួតពណ៌កាហ្វេ<br>លាមកភក់ៗពណ៌ខ្មៅ<br>អាចនឹងមានស្រកទំងន់<br>មិនមានដុំអ្វីដែលអាចស្ទាបប៉ះ<br>មិនមានទាច<br>មិនមានកើនការហូរឈាមពីដំបៅតូចៗ |
| VA-06.02 | ជំងឺថ្លើមរ៉ាំរ៉ៃ | K721<br>K739<br><br>K746<br>K769 | ការបាត់បង់មុខងារថ្លើមរ៉ាំរ៉ៃ<br>រលាកថ្លើមរ៉ាំរ៉ៃ មិនបញ្ជាក់<br><br>ជំងឺក្រិនថ្លើមដ៏ទៃទៀត និង មិនបញ្ជាក់<br>ជំងឺថ្លើម មិនបញ្ជាក់ | ជំងឺថ្លើមមួយដែលដូចជាបណ្តាលមកពីរលាកថ្លើមដោយការបង្ករោគ គួរតែត្រូវកូដទៅក្នុង VA-1.7 ។ កូដនៅក្នុង ICD-10 សំរាប់ជំងឺរលាកថ្លើមដោយវីរុស គឺ B18 ។<br><br>សញ្ញាណនៃជំងឺថ្លើមរ៉ាំរ៉ៃមិនបញ្ជាក់ មិនអាចពណ៌នាបាននៅក្នុង ICD-10 ឡើយ ។ តាមរយៈនេះ រាល់ករណីមិនច្បាស់លាស់គួរតែកូដនៅក្នុង K76.9 (ជំងឺថ្លើម មិនបញ្ជាក់) ប្រសិនបើរោគសញ្ញាអនុញ្ញាតអោយគេចាត់ថា ថ្លើម គឺជាមូលហេតុ ។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-06.03 | អចលនា ileus និង ស្ទះពោះវៀនតូច **ដោយមិនមានខ្លួន** | K566<br>K567 | ស្ទះពោះវៀនតូច ដ៏ទៃទៀត និងមិនបញ្ជាក់<br>Ileus មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ឈឺពោះ (ខ្លាំងក្លា)<br>ពោះរឹង<br>ចង្អោរ<br>ក្អួត<br>មិនមានរាគ |
| VA-06.98 | ជំងឺផ្សេងៗទៀតនៃពោះវៀនតូច | K63.8 | ជំងឺជាក់លាក់ផ្សេងៗទៀតនៃពោះវៀនតូច ចូរចាត់កូដដែលកាន់តែជាក់លាក់ នៅពេលមានពតិមានច្រើន ។ | ជំងឺផ្សេងៗណាទៀតក៏ដោយដែលទាក់ទងនឹងធ្មេញ បំពង់អាហារ ក្រពះ ពោះវៀន ថ្លើម ប្រពន្ធ័ទឹកប្រមាត់ និងលំពែង ត្រូវតែកូដនៅទីនេះ ។ |
| VA-06.99 | ជំងឺពោះវៀនតូច មិនបញ្ជាក់ | K639 | ជំងឺពោះវៀនតូច មិនបញ្ជាក់ | |
| VA-07 | វិបល្លាសតំរងនោម | | | ក្រុមរាប់ចូលតែជំងឺតំរងនោំប៉ុណ្ណោះ ។ ការបង្ករោគទឹកនោម និង ជំងឺផ្សេងទៀតនៃបំពង់ទឹកនោម ត្រូវគេចាត់នៅក្នុង VA-98 ។ ដុំតំរងនោម គួរត្រូវចាត់ទៅក្នុង VA-2.- ។ |
| VA-07.01 | អសមត្ថភាពតំរងនោម | N19<br>N179<br>N189 | អសមត្ថភាពតំរងនោម មិនបញ្ជាក់<br>អសមត្ថភាពតំរងនោមស្រួចស្រាវ មិនបញ្ជាក់<br>អសមត្ថភាពតំរងនោមរ៉ាំរ៉ៃ មិនបញ្ជាក់ | វិបល្លាសភាគច្រើនរបស់តំរងនោម និងផ្លូវទឹកនោម មិនស្តែងចេញនូវរូបភាពគ្លីនិកជាក់លាក់ឡើយ ។ ការនេះបង្កើននូវសំណាងនៃការដាក់ចំណាត់ថ្នាក់ ខុសដែលកើតឡើងនៅក្នុងក្រុមនៃជំងឺតំរងនោម ក៏ដូចជាក្នុងចំណោមប្រភេទផ្សេងៗទៀតនៃជំងឺ ។<br>គ្រួសក្នុងតំរងនោម ក៏ត្រូវគេចាត់ដែរ ដោយហេតុថាវាមានរូបភាពគ្លីនិកដាច់ដោយឡែក ហើយវាទំនងជាត្រូវគេធ្វើរោគវិនិច្ឆ័យក្នុងអំឡុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ ។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-07.98 | វិបល្លាសតំរងនោមដែលបញ្ជាក់ផ្សេងទៀត | N288 | វិបល្លាសតំរងនោមផ្សេងទៀត និង បំពង់នោម ចូរចាត់កូដដែលកាន់តែជាក់លាក់នៅពេលមានពតិមានច្រើន។ | |
| VA-07.99 | វិបល្លាសតំរងនោមនិងបំពង់នោម មិនបញ្ជាក់ | N289 | វិបល្លាសតំរងនោមនិងបំពង់នោម មិនបញ្ជាក់ | |
| VA-08 | វិបល្លាសស្មារតី និងប្រពន្ធ័សរសៃប្រសាទ | | | |
| VA-08.01 | ជំងឺខួរក្បាលដែលបណ្តាលអោយជរាភាព Alzheimer'disease | G30.9 | ជំងឺ Alzheimer មិនបញ្ជាក់ | |
| VA-08.02 | ឆ្កួតជ្រូក (Epilepsy) | G406<br><br><br>G407<br><br>G409<br>G419 | ប្រកាច់ភ្លាមៗ យូរ ខ្លាំងក្លា មិនបញ្ជាក់ (មាន ឬ មិនមាន ប្រកាច់មួយភ្លែតៗ) Grand mal seizures, unspecified (with or without petitmal)<br>Petit mal មិនបញ្ជាក់ ដោយគ្មាន Grand mal seizures ។<br>ឆ្កួតជ្រូក មិនបញ្ជាក់ (Epilepsy)<br>សភាពឆ្កួតជ្រូក (Status epilepticus) មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ប្រកាច់ និង/ឬ ខ្សល់គរ<br>បាត់បង់ស្មារតី ជាមួយនឹងដួល<br>គ្មានក្តៅខ្លួន<br>គ្មានរឹងក<br>គ្មានរបួសក្បាលថ្មីៗ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-08.96 | វិបល្លាសប្រពន្ធ័ប្រសាទសរសៃ ដែលបញ្ជាក់ផ្សេងទៀត | G549<br>G589<br>G909<br>G939<br>G959<br>G969 | វិបល្លាសឬសសរសៃប្រសាទនិងប្រពន្ធ័របស់វា មិនបញ្ជាក់<br>ជំងឺសរសៃប្រសាទតែមួយ មិនបញ្ជាក់<br>វិបល្លាសប្រពន្ធ័សរសៃប្រសាទស្វយ័ត មិនបញ្ជាក់<br>វិបល្លាសខួរក្បាល មិនបញ្ជាក់<br>វិបល្លាសខួរឆ្អឹងខ្នង មិនបញ្ជាក់<br>វិបល្លាសប្រពន្ធ័សរសៃប្រសាទកណ្តាល មិនបញ្ជាក់ | ប្រសិនបើមាន ពតិមានច្រើន ចូរប្រើកូដដែលកាន់តែជាក់លាក់នៃ ICD-10 ជំងឺកើតពីប្រពន្ធ័សរសៃឈាមខួរក្បាល ត្រូវតែចាត់នៅក្នុង VA-04.03 ។ ជំងឺខ្វះនៃសាច់ដុំ ត្រូវគេដាក់កូដនៅទីនេះ ( G70-G73) ។ រលាកសាច់ដុំ (myositis) គួរកូដនៅក្នុង VA-12 ។<br>រលាកស្រោមខួរគឺជាវិបល្លាសប្រពន្ធ័សរសៃប្រសាទ ដែលជាទូទៅបណ្តាលមកពីការបង្ករោគ ។ សំរាប់ហេតុផលនេះ វាត្រូវតែចាត់នៅក្នុងក្រុម VA សំរាប់ជំងឺឆ្លង ។<br>នៅក្នុង ICD-10 រលាកស្រោមខួរអាចរកឃើញនៅក្នុងជំពូកI (ជំងឺឆ្លង និង ប៉ារ៉ាស៊ីត មួយចំនួន) និងនៅក្នុងជំពូកVI ជំងឺនៃប្រពន្ធ័សរសៃប្រសាទ (អាស្រ័យទៅលើការបង្ករោគដែលនៅពីក្រោយ) ។ |
| VA-08.97 | វិបល្លាសប្រពន្ធ័សរសៃប្រសាទ មិនចាត់ផ្សេងពីនេះ | G98 | វិបល្លាសប្រពន្ធ័សរសៃប្រសាទ ផ្សេងៗទៀត ដែល មិនចាត់ផ្សេងពីនេះ | |
| VA-08.98 | វិបល្លាសស្មារតី ដែលបានបញ្ជាក់ | F00 – F98 | មិនមានកូដតែមួយសំរាប់ "វិបល្លាសស្មារតី ដែល បានបញ្ជាក់" មាននៅក្នុង ICD-1ឡើយ ។ កូដសមស្របត្រូវតែជ្រើសចេញពីប្រភេទដែលបាន ចែងនៅក្នុងបន្ទាត់បញ្ឈរខាងស្តាំ ។ | វិបល្លាសស្មារតីមិនអាចវាយតំលៃជាទូទៅដោយប្រើលក្ខ័ខណ្ឌរោគវិនិច្ឆ័យ នៅក្នុងពេលធ្វើកោសល្យវិច័យផ្ទាល់មាត់ ។ យ៉ាងណាក៏ដោយ ប្រសិនបើអ្នកស្លាប់ បានទទួលការព្យាបាលវិបល្លាសស្មារតីនៅក្នុងមន្ទីរពេទ្យ ដូចនេះគេអាចនឹងស្រាវជ្រាវរករោគវិនិច្ឆ័យពីឯកសារវេជ្ជសាស្ត្រនានា ។ នៅក្នុងករណីនេះ ចូរជ្រើសយកកូដសមស្របនៅក្នុង ICD-10ហើយចាត់កូដ VA ។<br>កូដ ICD-10 ដែលទាក់ទង ត្រូវតែរាយនៅខាងក្រោម ។<br>F00-F09 វិបល្លាសស្មារតីមូលហេតុសរីរាង្គ រាប់ទាំងបណ្តុំរោគសញ្ញា<br>F10-F19 វិបល្លាសស្មារតីនិងអាកប្បកិរិយា មូលហេតុប្រើប្រាស់សារធាតុរំញោចស្មារតី |

| | | | | |
|---|---|---|---|---|
| | | | | F20-F29 វិបល្លាសស្មារតីមូលហេតុ schizophrenia, schizotypal, and delusional ។<br>F300-F39 វិបល្លាសអារម្មណ៍ (affective)<br>F40-F48 វិបល្លាសបែបសរសៃប្រសាទ បែបទាក់ទងនឹងអារម្មណ៍តានតឹង និងរូបកាយ<br>F50-F59 បណ្តុំរោគសញ្ញាអាកប្បកិរិយា ទាក់ទងនឹងការរំខានផ្លូវចិត្ត កត្តារូបកាយ<br>F60-F69 វិបល្លាសនៃបុគ្គលិកលក្ខណៈនិងអាកប្បកិរិយាមនុស្សធំ<br>F70-F79 ការយឺតយ៉ាវផ្នែកស្មារតី<br>F80-F89 វិបល្លាសនៃការអភិវឌ្ឍន៍ចិត្តសាស្ត្រ<br>F90-F98 វិបល្លាសអាកប្បកិរិយានិងវេទនារម្មណ៍ ជាមួយនឹងការចាប់ផ្តើមជាទូទៅកើតឡើងក្នុងវ័យកុមារនិងជំទង់ |
| VA-08.99 | វិបល្លាសស្មារតី មិនបញ្ជាក់ | F99 | វិបល្លាសស្មារតី មិនបញ្ជាក់ផ្សេងពីនេះ | វិបល្លាសស្មារតីដែលបានបញ្ជាក់ អាចត្រូវគេដាក់កូដនៅក្នុង VA-12 ។ |
| VA-09 | វិបល្លាសដែលទាក់ទងនឹង ការមានផ្ទៃពោះ ការសំរាល និង ក្រោយការសំរាល | | ចូរចងចាំថាគឺឯកសារម្តាយ ដែលអ្នកកំពុងដាក់កូដ | កូដទាំងនេះគួរត្រូវតែប្រើប្រាស់សំរាប់ម្តាយ ។ វាមានក្រុមដាច់ដោយឡែកសំរាប់ទារកទើបនឹងកើត ( VA-10) ។ ជំងឺឆ្លងមួយចំនួនត្រូវតែកូដទៅ VA1.- ។ នៅពេលដាក់កូដ ចូរចងចាំនិយមន័យសំរាប់មរណៈភាពមាតានៅក្នុងសៀវភៅនេះ ។ |
| VA-09.01 | ការកកំណើតខុសកន្លែង | O009 | ការកកំណើតខុសកន្លែង មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-09.02 | ការរលូតដោយឯកឯង | O019 | កូនពង hydatidiform មិនបញ្ជាក់ | អ្នកដាក់កូដ ICD-10 គួរតែប្រុងប្រយត្ន័អោយមែនទែន ក្នុងការបែងចែក អក្សរ " O " ពីលេខ " 0 " នៅក្នុងជំពូកនេះ។ មុននឹងចាប់ផ្តើមដាក់កូដ ចូរយោងទៅទំព័រចុងក្រោយនៃភាគទី ១ នៅក្នុង ICD-10 សំរាប់និយមន័យទាក់ទងនឹងការស្លាប់សម្ភព។ តាំងពីដើមដល់ចប់នៃជំពូកនេះ នៅក្នុង ICD-10 មានការកត់សំគាល់តិច តួច ដែលមួយចំនួនយោងទៅរកគោលការណ៏ណែនាំអំពីជំងឺឬស្លាប់ នៅក្នុង ភាគទី២។ ចូរអោយច្បាស់ថាអ្នកបានអានគោលការណ៏ទាំងនេះ មុននឹងចាត់ កូដណាមួយពីជំពូកនេះ។ លក្ខខណ្ឌ័ម្តាយដែលបានចាត់ ចំពោះប្រភេទ O96-O99 នៃ ICD-10 មិនរាប់ចូលក្រុម VA នេះទេ។ ពួកវាត្រូវគេដាក់ជាក្រុមក្នុង VA-12។ |
| | | O029 | ការកកំណើតមិនធម្មតា មិនបញ្ជាក់ | |
| | | O033 | រលូតដោយឯកឯង មិនអស់ ជាមួយនឹងផលវិបាក ផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| | | O038 | រលូតដោយឯកឯង អស់ ឬមិនបញ្ជាក់ ជាមួយនឹង ផលវិបាក ផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| VA-09.03 | ការរំលូតមូលហេតុវេជ្ជសាស្ត្រ | O043 | ការរំលូតមូលហេតុវេជ្ជសាស្ត្រ មិនអស់ ជាមួយនឹង ផលវិបាកផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| | | O048 | ការរំលូតមូលហេតុវេជ្ជសាស្ត្រ អស់ ជាមួយនឹង ផលវិបាកផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| VA-09.04 | រលូតផ្សេងៗទៀត និង មិនបញ្ជាក់ | O053 | រលូតផ្សេងៗទៀត មិនអស់ ជាមួយនឹងផលវិបាក ផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| | | O058 | រលូតផ្សេងៗទៀត អស់ ជាមួយនឹងផលវិបាក ផ្សេងៗទៀតនិងមិនបញ្ជាក់ | |
| | | O069 | រលូតមិនបញ្ជាក់ អស់ ឬមិនបញ្ជាក់ មិនមាន ផលវិបាក | |
| | | O079 | ចេតនារំលូតផ្សេងទៀត បរាជ័យ និងមិនបញ្ជាក់ មិនមានផលវិបាក | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-09.05 | វិបល្លាសឡើងសម្ពាធឈាមនៅពេលមានផ្ទៃពោះ | O16<br>O109<br>O11<br>O12<br>O13<br>O149<br>O159 | សំពាធឈាមខ្ពស់របស់ដែលមិនបញ្ជាក់ ផ្ទៃពោះ<br>ការសំរាល និង ក្រោយសំរាល ដែលមានផលវិបាកពីមុនមក ដោយការឡើងសំពាធឈាម<br>វិបល្លាស ដោយសំពាធឈាមខ្ពស់ពីមុនមក ជាមួយនឹងការកើនជាតិប្រូតេអ៊ីនក្នុងទឹកនោម។<br>ហើម និងប្រូតេអ៊ីនក្នុងទឹកនោម ទាក់ទងនឹងការមានគភ៌ [បណ្តាលពីមានគភ៌] មិនមានសំពាធឈាមខ្ពស់។<br>សំពាធឈាមខ្ពស់ ទាក់ទងនឹងការ មានគភ៌ [បណ្តាលពីមានគភ៌] ដោយមិនមានជាតិប្រូតេអ៊ីនក្នុងទឹកនោមច្បាស់លាស់។<br>សំពាធឈាមខ្ពស់ ទាក់ទងនឹងការ មានគភ៌ [បណ្តាលពីមានគភ៌] ដោយមានជាតិប្រូតេអ៊ីនក្នុងទឹកនោមច្បាស់លាស់។<br>ក្រលាភ្លើង មិនបញ្ជាក់ពីពេលវេលា | **ពតិមានទាក់ទង:**<br>ផ្ទៃពោះលើសពី ៥ខែ<br>សំរាលតិចជាង ៦ សប្តាហ៏កន្លងទៅ<br>ហើមនៅចុងដៃ និង/ឬ មុខ<br>ប្រកាច់<br>ស្រវាំងភ្នែក<br>សំពាធឈាមឡើងខ្ពស់<br>សំរាលលើកទី១<br>ឈឺពោះ<br>ឈឺក្បាល<br>គ្មានគ្រុនក្តៅ |
| VA-09.06 | ធ្លាក់ឈាមមុនសំរាល | O441<br>O459<br>O069 | សុកបាំងមាត់ស្បូន ដោយមានធ្លាក់ឈាម<br>ដាច់ធ្លាក់ស្បូនមុនពេលកំណត់ មិនបញ្ជាក់<br>ធ្លាក់ឈាមមុនសំរាល មិនមានចាត់នៅកន្លែងផ្សេង | **ពតិមានទាក់ទង:**<br>ឈឺពោះសំរាល<br>ផ្ទៃពោះលើសពី ៨ ខែ<br>ធ្លាក់ឈាមតាមទ្វារខ្លាំងក្លា មុននឹងការសំរាលចាប់ផ្តើមបន្តិច |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-09.07 | ធ្លាក់ឈាមក្រោយសំរាល | O709<br>O719<br>O72.- | ដាច់សាច់ជុំវិញទ្វារ អំឡុងពេលសំរាល មិនបញ្ជាក់<br>ការប៉ះទង្គិចដោយការសម្អាត មិនបញ្ជាក់<br>ធ្លាក់ឈាមក្រោយសំរាល | **ពតិមានទាក់ទង:**<br>សំរាល តិចជាង៣ថ្ងៃកន្លងទៅ<br>ផ្ទៃពោះលើសពី ៨ ខែ<br>ធ្លាក់ឈាមតាមទ្វារធ្ងន់ធ្ងរ<br>ចូរប្រយត្ន័ប្រយែងក្នុងការធ្វើតារាង: សញ្ញាណនៃការធ្លាក់ឈាមក្រោយសំរាលនៅក្នុង VA គឺមានភាពទូលំទូលាយខ្លាំងជាងនៅក្នុង ICD-10 ។ |
| VA-09.08 | ធ្លាក់ឈាមពេលសំរាល | O679 | ធ្លាក់ឈាមពេលសំរាល មិនបញ្ជាក់ | |
| VA-09.09 | ឧបសគ្គពេលសំរាល | O649<br>O654<br>O659<br>O664<br>O665<br>O669 | ឧបសគ្គសំរាលដោយសារស្ថានភាពមិនល្អ និង ទំរង់កូនមិនល្អ មិនបញ្ជាក់<br>ឧបសគ្គសំរាលដោយសារភាពមិនស្របគ្នារវាងក្បាលកូននិងអាងត្រគាក មិនបញ្ជាក់<br>ឧបសគ្គសំរាលដោយសារ ឆ្អឹងត្រគាកម្តាយមិនធម្មតា មិនបញ្ជាក់<br>បរាជយ័នៃការសាកល្បងសំរាល មិនបញ្ជាក់<br>បរាជយ័នៃការប្រើឧបករណ៏បូម និងដង្កៀបមិនបញ្ជាក់<br>ឧបសគ្គសំរាល មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ស្ត្រីដែលស្លាប់ពេលសំរាល និង ដែលមិនអាចជួយអោយសំរាលបានរយ:ពេលសំរាល លើសពី ២៤ ម៉ោង<br>រោគវិនិច្ឆ័យនេះគឺច្រើនជាធ្វើឡើងក្រោយការសំរាលកូនស្លាប់កើត ។ |

| កូដកោសល្យវិច័យផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-09.10 | ក្លាយរោគក្រោយសំរាល | O85<br>O868 | ក្លាយរោគក្រោយសំរាល<br>ក្លាយរោគក្រោយសំរាល ដែលបញ្ជាក់ផ្សេងទៀត | **ពតិមានទាក់ទង:**<br>សំរាលតាមទ្វារ លើសពី ១ ថ្ងៃកន្លងទៅ<br>សំរាលដោយវះយកកូន លើសពី ១ ថ្ងៃកន្លងទៅ<br>គ្រុនក្តៅខ្លាំង |
| VA-09.98 | មូលហេតុមាតាផ្ទាល់ ដែលបានបញ្ជាក់ផ្សេងៗទៀត | | ចូរជ្រើសយកប្រភេទសមស្របពី ICD-10។ | ប្រភេទនេះរាប់ទាំងជំងឺខ្លះដែលកើតឡើងអំឡុងពេលមានគភ៌ តែជាធម្មតាត្រូវដាក់កូដទៅក្នុងជំពូកផ្សេងទៀត ដូចជាទឹកនោមផ្អែម Melitus និងការបង្ករោគ មួយចំនួន និងលក្ខខណ្ឌម្តាយដែលបណ្តាលមកពីទារក។<br>សូមយោងទៅនិយមន័យនៃ "មូលហេតុម្តាយផ្ទាល់" ដែលមានពីដំបូងនៃសៀវភៅនេះ។ |
| VA-09.99 | មូលហេតុមាតាផ្ទាល់ផ្សេងៗទៀតមិនបញ្ជាក់ | O95 | ស្លាប់ទាក់ទងនឹងសម្ភព ដែលមិនបញ្ជាក់មូលហេតុ | ចូរយោងទៅក្បួនមរណ:ភាព និងមគ្គុទេសណែនាំនានានៅក្នុងភាគទី ២ នៃ ICD-10 ប្រសិនបើអ្នកចង់ចាត់កូដនេះ។ |
| VA-10 | មូលហេតុជុំវិញកំណើតនៃការស្លាប់ | | **ចូរចងចាំថា វាជាឯកសាររបស់ទារកដែលអ្នកកំពុងដាក់កូដ។** | កូដទាំងនេះត្រូវគេប្រើសំរាប់ទារកទើបនឹងកើត។ មានក្រុមដាច់ដោយឡែកសំរាប់ម្តាយ (VA-9)។<br>នៅពេលដាក់កូដ ចូរចងចាំថានិយមន័យនានាសំរាប់មូលហេតុជុំវិញកំណើតនៅក្នុងសៀវភៅនេះ។ |
| VA-10.01 | តេតាណូសលើទារកទើបនឹងកើត | A33 | តេតាណូសលើទារកទើបនឹងកើត | ពតិមានទាក់ទង:<br>ទារកអាចជញ្ជក់បានធម្មតាក្នុងរយ:ពេល២ថ្ងៃនៃជីវិត<br>ឈប់ជញ្ជក់<br>មិនអាចបើកមាត់បាន<br>ប្រកាច់ ឬកន្ត្រាក់ឈឺខ្នង |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.02 | ភាពមិនគ្រប់ខែ (រាប់ទាំងគ្រោះផ្លូវដង្ហើម) | P010<br>P011 | ទារកក្នុងផ្ទៃនិងទារកទើបនឹងកើតទទួលការប៉ះពាល់ដោយអសមត្ថភាពកស្បូន<br>ទារកក្នុងផ្ទៃនិងទារកទើបនឹងកើតទទួលការប៉ះពាល់ដោយការបែកស្រោមទឹកភ្លោះមុនកាលកំណត់ | **ពតិមានទាក់ទង:**<br>គភ៌ស្ថិតនៅតិចជាង៨ខែ<br>កូនតូចមែនទែននៅពេលកើត<br>ស្បែកស្ងួត របក និង បាត់បង់សារធាតុជាលិកាក្រោមស្បែក<br>ពិបាកដកដង្ហើមចាប់ផ្តើមមាននៅថ្ងៃដំបូងនៃជីវិត<br>មិនអាចចិញ្ចឹមបានតាំងពីកើត<br>មានវត្តមានជំងឺម្តាយ (មុនក្រលាភ្លើង ឬក្រលាភ្លើង ទឹកនោមផ្អែម បញ្ហាវេជ្ជសាស្ត្រធ្ងន់ធ្ងរផ្សេងៗទៀត)<br>ម្តាយមានធ្លាក់ឈាមមុនសំរាល |
| | | P07<br>P22-P25<br>P529<br>P590<br>P612<br>P77 | វិបល្លាសទាក់ទងទៅនឹងការពរពោះខ្លី និង ទំងន់ពេលកើតទាប មិនចាត់នៅកន្លែងផ្សេង<br>គ្រោះផ្លូវដង្ហើមនៃទារកទើបនឹងកើត និងលក្ខខណ្ឌជាក់លាក់នានាច្រើនទៀត<br>ហូរឈាមក្នុងខួរក្បាល (មិនមែនប៉ះទង្គិច) នៃទារកក្នុងផ្ទៃនិងទារកទើបនឹងកើត មិនបញ្ជាក់<br>លឿងលើទារកទើបនឹងកើត មិនបញ្ជាក់<br>ស្លេកស្លាំងនៃទារកកើតមិនគ្រប់ខែ<br>រលួយពោះវៀនតូច-ធំ នៃទារកក្នុងផ្ទៃ និងទើបនឹងកើត | |
| VA-10.03 | ទំងន់ពេលកើតទាប | P059 | ការលូតលាស់ទារកក្នុងផ្ទៃយឺត មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.04 | ការប៉ះទង្គិចពេលកើត | P109 | ការដាច់នៅក្នុងលលាដ៏ក្បាលដែលមិនបញ្ជាក់ និង ការហូរឈាមបណ្តាលពីរបួសពេលកើត | |
| | | P119 | របួសពេលកើតចំពោះប្រពន្ធ័សរសៃប្រសាទកណ្តាល មិនបញ្ជាក់ | |
| | | P129 | របួសពេលកើតចំពោះលលាដ៏ក្បាល មិនបញ្ជាក់ | |
| | | P139 | របួសពេលកើតចំពោះគ្រោងឆ្អឹង មិនបញ្ជាក់ | |
| | | P149 | របួសពេលកើតចំពោះប្រពន្ធ័សរសៃប្រសាទខាងៗ មិនបញ្ជាក់ | |
| | | P159 | របួសពេលកើត មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.05 | អត់ដកដង្ហើមពេលកើត និងវិបល្លាសដង្ហើមជុំវិញកំណើត | P021<br>P024<br>P026<br>P029 | ទារកក្នុងផ្ទៃនិងទើបនឹងកើតប៉ះពាល់ដោយផលវិបាកនៃសុក ទងផ្ចិត និងស្រោមទឹកភ្លោះ | **ពតិមានទាក់ទង:**<br>មិនអាចយំ ឬដកដង្ហើមបាន ពេលកើត<br>ត្រូវការជំនួយអោយដកដង្ហើម<br>អាយុពេលស្លាប់តិចជាង៧ថ្ងៃ<br>មិនអាចជញ្ជក់តាំងពីពេលកើត<br>មិនមានគ្រុនក្តៅ<br>ប្រសិនបើស្លាប់កើតមានឡើងក្រោយថ្ងៃទីមួយ មានខ្លះនៃបណ្តុំរោគសញ្ញាតទៅនេះ: ប្រកាច់ មួរមៅ រឹងអវ:យវ: សន្លឹងសន្ធៃ ឬមិនឆ្លើយតប<br>ម្តាយមានហូរឈាមមុនសំរាល<br>ផលវិបាកសម្ភព ( ធ្លាក់ឈាមពេលសំរាល ឧបសគ្គសំរាល កូនបង្ហាញមិនល្អ) |
| | | P039 | ទារកក្នុងផ្ទៃនិងទើបនឹងកើតប៉ះពាល់ដោយផលវិបាកនៃពេលឈឺពោះសំរាល និងសំរាល មិនបញ្ជាក់ | |
| | | P209 | ខ្វះអុកស៊ីសែនក្នុងស្បូន មិនបញ្ជាក់ | |
| | | P219 | អត់ដង្ហើមពេលកើត មិនបញ្ជាក់ | |
| | | P249 | បណ្តុំរោគសញ្ញាដកដង្ហើមនៃទារកទើបនឹងកើត មិនបញ្ជាក់ | |
| | | P509 | បាត់បង់ឈាមទារកក្នុងផ្ទៃ មិនបញ្ជាក់ | |
| | | P90 | ការប្រកាច់នៃទារកទើបនឹងកើត | |
| | | P919 | ភាពរំខានស្ថានភាពខួរក្បាលនៃទារកទើបនឹងកើត មិនបញ្ជាក់ | |
| VA-10.06 | ជំងឺរលាកសួតលើកុមារទើបនឹងកើត | P239 | រលាកសួតពីកំណើត មិនបញ្ជាក់ | |
| VA-10.07 | ជំងឺដោយពួកវីរុស ពីកំណើត | P359 | ជំងឺដោយពួកវីរុស ពីកំណើត មិនបញ្ជាក់ | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.08 | ក្លាយរោគដោយពួកបាក់តេរីនៃទារកទើបនឹងកើត | P369 | ក្លាយរោគដោយពួកបាក់តេរីនៃទារកទើប នឹងកើត មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>អាយុនៅពេលចាប់មានរោគសញ្ញា លើសពី១ថ្ងៃ<br>ដកដង្ហើមញាប់ ទ្រូងផិតផត ឬឮសំលេង ស្ថិតនៅរយ:ពេលយ៉ាងហោច១ថ្ងៃ មុននឹងស្លាប់<br>គ្រុនក្តៅ<br>ខ្លួនប្រាណត្រជាក់ពេលស្លាប<br>សន្ទឹងសន្ទៃ ឬ មិនឆ្លើយតប<br>ឈប់បៅ<br>ចេញខ្ទុះតាមរន្ធផ្ចិត<br>ស្បែកកន្ទួលក្រហម មានខ្ទុះ<br>ប្រកាច់<br>ម្តាយមានគ្រុនក្តៅ និង/ឬ រាគពេលកំពុងសំរាល |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.09 | ខូចទ្រង់ទ្រាយពីកំណើតនៃប្រព័ន្ធសរសៃប្រសាទ | Q00<br>Q019<br>Q02<br>Q039<br>Q049<br>Q059<br>Q069<br>Q079 | អត់ក្បាល និងការខូចរូបរាងប្រហាក់ប្រហែលគ្នា<br>ទឹកក្នុងខួរក្បាល (encephalocele) មិនបញ្ជាក់<br>ក្បាលតូចល្អិត<br>ដក់ទឹកក្នុងខួរក្បាល ពីកំណើត មិនបញ្ជាក់<br>ខូចរូបរាងខួរក្បាលពីកំណើត មិនបញ្ជាក់<br>ខួរឆ្អឹងខ្នងចែកជាពីរ មិនបញ្ជាក់<br>ខូចរូបរាងឆ្អឹងខ្នងពីកំណើត មិនបញ្ជាក់<br>ខូចទ្រង់ទ្រាយពីកំណើតនៃប្រព័ន្ធសរសៃប្រសាទ មិនបញ្ជាក់ | **ពតិមានទាក់ទង:**<br>ការខូចរូបរាងសំខាន់ៗដែលអាចមើលឃើញ នៃក្បាល ឬឆ្អឹងខ្នង ដូចជា ក្បាលមិនបានបង្កើតឡើង ក្បាលតូចខ្លាំង ឬធំខ្លាំង មិនគ្រប់លក្ខណៈឬមានដុំនៅផ្នែកខាងក្រោយនៃក្បាល ឬឆ្អឹងខ្នង<br>ភាពមិនគ្រប់លក្ខណៈសំខាន់ៗពីកំណើតផ្សេងៗទៀត: គ្មានរន្ធគូទ ខូចអវៈយវៈ ខូចពោះឬទ្រូង |
| VA-10.10 | ខូចរូបរាងពីកំណើត ផ្សេងទៀត និង មិនបញ្ជាក់ | Q899<br>Q999 | ខូចរូបរាងពីកំណើត មិនបញ្ជាក់<br>ភាពមិនប្រក្រតីនៃក្រូម៉ូសូម មិនបញ្ជាក់<br>ចូរជ្រើសយកកូដដែលកាន់តែជាក់លាក់ នៅពេលដែលមានពតិមានកាន់តែច្រើន។ | ភាពមិនធម្មតានៃក្រូម៉ូសូមមួយចំនួន ស្តែងឡើងជាការខូចរូបរាង។ ក្នុងអំឡុងពេលកោសល្យវិច័យផ្ទាល់មាត់ មូលហេតុពីក្រោយភាពមិនធម្មតានៃក្រូម៉ូសូម ជាធម្មតាមិនត្រូវបានគេរកឃើញឡើយ។ ជំនួសអោយនេះ ការខូចរូបរាង ត្រូវតែដាក់កូដថាខូចរូបរាង។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-10.97 | ស្លាប់កើត (Stillbirths ) | P95 | ទារកក្នុងផ្ទៃស្លាប់ ដោយមូលហេតុមិនបញ្ជាក់<br>ទារកក្នុងផ្ទៃស្លាប់កើត NOS<br>ស្លាប់កើត NOS | ចូរអោយច្បាស់ថា ការស្លាប់មិនមែនជាលទ្ធផលនៃ បណ្តុំសញ្ញាស្លាប់ភ្លាមៗរបស់កុមារឡើយ (VA10.12) ឬមិនមែនកើតឡើងទៅតាមបែបណាមួយនៃការកើតរស់ឡើយ។<br>**ពតិមានទាក់ទង:**<br>មិនមានដកដង្ហើម យំ ឬកំរើក ទាល់តែសោះ (បើទោះជាតិចតួចក៏ដោយ) ក្រោយពេលកើត<br>ស្លាប់កើត នៅស្រស់ ឬត្រាំយូរ<br>មានវត្តមានខូចរូបរាងពីកំណើត<br>មានវត្តមានជំងឺម្តាយ (មុនក្រលាភ្លើង ឬក្រលាភ្លើង ទឹកនោមផ្អែម បញ្ហាវេជ្ជសាស្ត្រធ្ងន់ធ្ងរផ្សេងៗទៀត)<br>ម្តាយមានធ្លាក់ឈាមមុនសំរាល<br>មានវត្តមានផលវិបាកសម្ភព (ធ្លាក់ឈាមក្នុងពេលសំរាល ឧបសគ្គពេល សំរាល ការបង្ហាញរបស់ទារកមិនល្អ) |
| VA-10.98 | វិបល្លាសដែលបញ្ជាក់ផ្សេងទៀត ដែលទាក់ទងនឹងរយៈពេលជុំវិញកំណើត | P969 | លក្ខខណ្ឌមានប្រភពដើម នៅក្នុងរយៈពេលជុំវិញកំណើត មិនបញ្ជាក់ | |
| VA-11 | មូលហេតុស្លាប់ពីខាងក្រៅ | | | មូលហេតុពីក្រៅដែលមិនមាននៅក្នុងក្រុមនេះ ត្រូវកូដទៅក្នុង VA-12។ |
| VA-11.01 | អ្នកថ្មើរជើងដែលត្រូវរបួសក្នុងគ្រោះថ្នាក់ចរាចរ | V09 | អ្នកថ្មើរជើងត្រូវរបួសក្នុងគ្រោះថ្នាក់ចរាចរ ផ្សេងទៀត និង មិនបញ្ជាក់ | ចូរពិគ្រោះ V01-V08 សំរាប់កូដលំអិត |

| | | | | |
|---|---|---|---|---|
| VA-11.02 | គ្រោះថ្នាក់ចរាចរផ្សេងទៀត | V19 | អ្នកធាក់កង់ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | |
| | | V29 | អ្នកជិះម៉ូតូ ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | កូដដែលប្រហែលជាអាចដាក់បានគឺ V10-V99 ។ |
| | | V39 | អ្នកជិះយានកង់បីត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | របួសគួរត្រូវកត់ត្រាទុក នៅទីណាក៏ដោយដែលអាចធ្វើទៅបាន និងដាក់ជាតារាងជាមួយគ្នា ជាមួយនឹងមូលហេតុខាងក្រៅនានា ។ |
| | | V49 | អ្នកជិះរថយន្ត ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | នៅក្នុងករណីទាំងនេះ ចូរយកចិត្តទុកដាក់រាយការណ៍មូលហេតុខាងក្រៅ និងរបួស នៅក្នុងកន្លែងដាច់ពីគ្នា ដើម្បីចៀសវាងរាប់ការស្លាប់ពីរដង ។ |
| | | V59 | អ្នកជិះយានយន្តដឹងទំនិញ ឬឡានវ៉ែន ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | កូដពី ICD-10ជំពូក XIX (របួស ការពុល និងផលវិបាកផ្សេងទៀតមួយចំនួននៃមូលហេតុពីក្រៅ) មិនគួរប្រើសំរាប់ធ្វើតារាង មូលហេតុទោលនៅពីក្រោយការស្លាប់ឡើយ ។ មូលហេតុរបួសគឺមានអាទិភាព ។ |
| | | V69 | អ្នកជិះយានយន្តធុនធ្ងន់ ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | លក្ខខណ្ឌទាំងឡាយដែលចែងនៅក្នុងជំពូក I-XVIII ថាបណ្តាលមកពីមូលហេតុពីក្រៅនោះ មានអាទិភាពលើមូលហេតុពីក្រៅ ។ |
| | | V79 | អ្នកជិះរថយន្តបឹសត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | |
| | | V80 | អ្នកជិះយាន ឬយានយន្ត ត្រូវរបួសនៅក្នុងគ្រោះថ្នាក់ចរាចរផ្សេងទៀត និង មិនបញ្ជាក់ | |
| | | V90 | គ្រោះថ្នាក់ជលយាន្តបណ្តាលអោយលង់និងលិច | |
| | | V91 | គ្រោះថ្នាក់ជលយានបណ្តាលអោយរបួសផ្សេងទៀត | |
| | | V92 | លង់និងលិចទាក់ទងនឹងការដឹកជញ្ជូនផ្លូវទឹក ដោយមិនទាក់ទងនឹងជលយាន្ត | |
| | | V93 | គ្រោះថ្នាក់នៅលើជលយាន្ត មិនបណ្តាលអោយលង់និងលិច ដោយមិនមានគ្រោះថ្នាក់ចំពោះជលយាន | |

| | |
|---|---|
| V940 | គ្រោះថ្នាក់ចរាចរផ្សេងទៀតនិងមិនបញ្ជាក់ កប៉ាល់ដឹកទំនិញ |
| V941 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ កប៉ាល់ដឹកអ្នកដំណើរ |
| V942 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ទូកនេសាទ |
| V943 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ជលយាន្តថាមពលផ្សេងទៀត |
| V944 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ទូកក្ដោង |
| V945 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ទូកអុំ ឬទូកប្រណាំង |
| V946 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ទូកផ្លុំខ្យល់ ( មិនមែនដោយថាមពល) |
| V947 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ស្គីទឹក |
| V948 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ជលយាន្តមិនដើរដោយថាមពលផ្សេងទៀត |
| V949 | គ្រោះថ្នាក់ចរាចរផ្លូវទឹកផ្សេងទៀតនិងមិនបញ្ជាក់ ជលយាន្តដែលមិនបញ្ជាក់ |
| V95 | គ្រោះថ្នាក់ចំពោះយន្តហោះដើរដោយថាមពល បង្ករបួសដល់អ្នកជិះ |
| V99 | គ្រោះថ្នាក់ចរាចរដែលមិនបញ្ជាក់ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-11.03 | គ្រោះថ្នាក់ធ្លាក់ | W19 | ធ្លាក់ដែលមិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ W00-W19 ។ |
| VA-11.04 | គ្រោះថ្នាក់លង់ និង លិចទឹក | W74 | គ្រោះថ្នាក់លង់ និង លិចទឹក មិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ W65-W74 ។ |
| VA-11.05 | គ្រោះថ្នាក់ ដោយពើបនឹងផ្សែង ភ្លើង និង អណ្តាតភ្លើង | X09 | ពើបនឹងផ្សែង ភ្លើង និង អណ្តាតភ្លើង ដែលមិន បញ្ជាក់ | កូដដែលអាច  នៅក្នុង ICD-10 គឺ X00-X09 ។ |
| VA-11.06 | ប៉ះពាល់នឹងពស់និងរុក្ខជាតិ ពិស | X29 | ប៉ះពាល់នឹងពស់និងរុក្ខជាតិ ពិស ដែលមិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ X20-X29 ។ |
| VA-11.07 | ពើបនឹងកំលាំងធម្មជាតិ | X39 | ពើបនឹងកំលាំងធម្មជាតិផ្សេងទៀត ដែលមិន បញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ X30-X39 ។ |
| VA-11.08 | គ្រោះថ្នាក់ដោយការពុល និងពើបនឹងសារធាតុពុល | X44<br>X49 | គ្រោះថ្នាក់ដោយការពុលដោយ និងពើបនឹងថ្នាំ ឱសថ និងសារធាតុជីវសាស្ត្រ ផ្សេងទៀត និងមិន បញ្ជាក់<br>គ្រោះថ្នាក់ដោយការពុលដោយ និងពើបនឹងជាតិគីមី និងសារធាតុពុលផ្សេងទៀតនិងមិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ X40-X49 ។ |
| VA-11.09 | ខ្វះខាតអាហារ និង/ឬ ទឹក | X53<br>X54 | ខ្វះខាតអាហារ<br>ខ្វះខាតទឹក | |
| VA-11.10 | ចេតនាបង្ករបួសស្នាមដោយខ្លួនឯង | X64<br>X69<br>X74<br>X84 | ចេតនាបំពុលខ្លួនឯងដោយ និងពើបនឹងថ្នាំ ឱសថ និងសារធាតុជីវសាស្ត្រ ផ្សេងទៀតនិងមិនបញ្ជាក់<br>ចេតនាបំពុលខ្លួនឯងដោយ និងពើបនឹង ជាតិគីមី និងសារធាតុពុលផ្សេងទៀតនិងមិនបញ្ជាក់<br>ចេតនាបង្ករបួសខ្លួនឯងដោយការបាញ់ កាំភ្លើង<br>ចេតនាបង្ករបួសខ្លួនឯងដោយមធ្យោបាយមិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ X60-X64 ។ |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-11.11 | ការវាយប្រហារ | X90 | ការវាយប្រហារដោយសារជាតិគីមី ឬសារធាតុពុល ដែលមិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ X85-Y09 ។ |
| | | X92 | ការវាយប្រហារដោយពន្លង់ និងពន្លិច | |
| | | X95 | ការវាយប្រហារដោយការបាញ់កាំភ្លើង ផ្សេងទៀត និងមិនបញ្ជាក់ | |
| | | Y05 | ការវាយប្រហារផ្លូវភេទដោយការចាប់បង្ខំរាងកាយ | |
| | | Y06 | មិនថែទាំ និង បោះបង់ចោល | |
| | | Y07 | រោគសញ្ញានៃការមិនយកចិត្តទុកដាក់ថែទាំ | |
| | | Y09 | ការវាយប្រហារដោយមិនបញ្ជាក់ពីមធ្យោបាយ | |
| VA-11.12 | អន្តរាគមន៍ផ្នែកច្បាប់ | Y357 | អន្តរាគមន៍ផ្នែកច្បាប់ មធ្យោបាយមិនបញ្ជាក់ | |
| VA-11.13 | មរណៈភាពដោយសង្គ្រាម | Y369 | ប្រតិបត្តិការសង្គ្រាម មិនបញ្ជាក់ | |
| VA-11.97 | គ្រោះថ្នាក់មិនបញ្ជាក់ | X599 | ពើបនឹងកត្តាបង្កដែលមិនបញ្ជាក់ បណ្តាលអោយមានរបួសផ្សេងទៀតនិងមិនបញ្ជាក់ | |
| VA-11.98 | ព្រឹត្តិការណ៍ជាក់លាក់ផ្សេងទៀត ដែលមិនកំណត់បំណង | Y33 | ព្រឹត្តិការណ៍ជាក់លាក់ផ្សេងទៀត ដែលមិនកំណត់បំណង | |
| VA-11.99 | ព្រឹត្តិការណ៍មិនជាក់លាក់ផ្សេងទៀត ដែលមិនកំណត់បំណង | Y34 | ព្រឹត្តិការណ៍មិនជាក់លាក់ផ្សេងទៀត ដែលមិនកំណត់បំណង | |

| កូដកោសល្យវិច័យ ផ្ទាល់មាត់ | ចំណងជើងកោសល្យវិច័យ ផ្ទាល់មាត់ | កូដ ICD-10 | ចំណងជើង ICD-10 | អធិប្បាយ |
|---|---|---|---|---|
| VA-12 | ការផ្សងព្រេងខុសចំពោះអ្នកជំងឺ អំឡុងពេលថៃទាំសល្យសាស្ត្រ និងវេជ្ជសាស្ត្រ | Y69 | ការផ្សងព្រេងមិនបញ្ជាក់ អំឡុងពេលថៃទាំសល្យសាស្ត្រនិងវេជ្ជសាស្ត្រ | កូដដែលអាច នៅក្នុង ICD-10 គឺ Y60-Y69 ។ ប្រភេទនេះ មិនរាប់ចូល: ឧបករណ៏វេជ្ជសាស្ត្រខូច ឬដំណើរការមិនល្អ ឡើយ(នៅពេលកំពុងដំណើរការ)(ក្រោយពេលធ្វើការផ្សាំ)(កំពុងប្រើប្រាស់)( Y70-Y82) ។ របៀបរបបសល្យសាស្ត្រ និងវេជ្ជសាស្ត្រ ជាមូលហេតុនៃប្រតិកម្មមិនធម្មតារបស់អ្នកជំងឺ ដោយមិននិយាយពីការផ្សងព្រេងខុស នៅពេលដំណើរការ ( Y83-Y84) ។ |
| VA-13 | ថ្នាំ ឱសថ និងសារធាតុជីវសាស្ត្រ ដែលបង្កផលបញ្ច្រាស ក្នុងការប្រើប្រាស់សំរាប់ការព្យាបាល | Y579<br>Y599 | ថ្នាំ ឬ ឱសថ មិនបញ្ជាក់<br>វ៉ាក់សាំង ឬ សារធាតុជីវសាស្ត្រ មិនបញ្ជាក់ | កូដដែលអាច នៅក្នុង ICD-10 គឺ Y40-Y59 ។ |
| VA-98 | មូលហេតុបញ្ជាក់ផ្សេងទៀត នៃការស្លាប់ | | រូបធាតុនេះនៃឧបករណ៏កោសល្យវិច័យផ្ទាល់មាត់ មិនដៅផែនទីចំពោះរូបធាតុទោលណាមួយនៃ ICD-10 ឡើយ ។ | |
| | | | | ក្រុមនេះគ្របដណ្តប់រាល់ជំងឺដែលមិនអាចចាត់ទៅក្រុមដ៏ទៃ ឬប្រភេទនៅក្នុងឧបករណ៏កោសល្យវិច័យផ្ទាល់មាត់ ។ ចូរកត់សំគាល់ថា កូដ ICD-10 ដែលចាប់ ផ្តើមឡើងដោយអក្សរ A ឬ B ទាំងអស់ត្រូវចាត់ទៅ VA-1 ។ រាល់កូដ ICD-10 ដែលចាប់ផ្តើមដោយអក្សរ C ត្រូវចាត់ទៅ VA-2 ។<br>**ជំងឺនានារបស់ភ្នែក និងបណ្តាញរបស់វា**<br>កូដមួយសំណំ ត្រូវបានផ្តល់អោយដោយ ICD-10 ( H00-H59) ។ H54 ខ្វាក់ និងគំហើញខ្សោយ គឺជាប្រភេទដ៏សំខាន់មួយ ដែលមានតារាងមួយលំអិតពីប្រភេទនៃពិការភាព ។ |

**ជំងឺនានារបស់ត្រចៀក និងឆ្អឹង Mastoid**

កូដមួយសំណំ ត្រូវបានផ្តល់អោយដោយ ICD-10 ( H60-H95) ។

H90 ចាត់ការបាត់បង់ ការនាំ និងវិញ្ញាណនៃការឮ ដោយពិការម្ខាងឬទាំងសងខាង ។

**ជំងឺនានារបស់ស្បែក និងជាលិកាក្រោមស្បែក**

នៅក្នុង ICD-10 ជំពូកដែលទាក់ទងនឹងជំងឺស្បែក និងជាលិកាក្រោមស្បែក មានការមិនរាប់ចូល និង រាប់ចូល ជាច្រើន ។ គេរាយវានៅក្នុងបញ្ជីនាដើមជំពូកនានា បណ្តុំនានា និងប្រភេទនានា ហើយជាទូទៅ អនុវត្តចំពោះរាល់កំរិតនៅខាងក្រោមក្បាលចំណងជើង ។ ចូរចងចាំថា កំណត់សំគាល់នៃការមិនរាប់ចូល កំណត់នូវរូបធាតុ ឬកូដ ដែលចាត់នៅកន្លែងផ្សេង ។

ប្រសិនបើអ្នកត្រូវដាក់កូដជំងឺស្បែកមួយ អ្នកគួរប្រើ ICD-10 ដើម្បីឆែកមើល

ថាតើវាគួរចាត់ទៅក្នុងក្រុមកោសល្យវិច័យផ្ទាល់មាត់ជាក់លាក់ណាមួយ ជាជាងទៅក្នុង VA-98 ។ អារម្ភកថាជំពូក XII (ជំងឺស្បែក និងជាលិកាក្រោមស្បែកនានា) ផ្តល់នូវសេចក្តីសង្ខេបសរុបដ៏ល្អ ។

**ជំងឺនិងលក្ខខណ្ឌនានាទាក់ទងនឹងឆ្អឹងខ្នង សន្លាក់ សាច់ដុំ និងជាលិកាចំណងនៃសរីរាង្គ ដោយរាប់ទាំងការខូចទ្រង់ទ្រាយ ដែលកើតឡើងក្រោយកំណើត ។**

ការខូចទ្រង់ទ្រាយ ឬរូបរាងបង្កើតមកមិនគ្រប់លក្ខណៈពីកំណើត ត្រូវតែកូដនៅក្នុងក្រុម VA-10.- (មូលហេតុស្លាប់ជុំវិញកំណើត) ។ ការដូចគ្នានេះ ប្រើក្នុងការដាក់កូដជាមួយនឹង ICD-10 ជំពូក XII ។

**ប្រពន្ធ័នោម និងប្រពន្ធ័បន្តពូជបុរសស្ត្រី**

សំរាប់គោលបំណងកោសល្យវិច័យផ្ទាល់មាត់ វិបល្លាសតំរងនោម ត្រូវតែកូដទៅក្រុម VA-7.- ។

| | | | | |
|---|---|---|---|---|
| | | | | **ការស្លាប់ទាក់ទងនឹងសម្ភព**<br>លក្ខ័ខណ្ឌ័សម្ភពដែលចាត់ទៅប្រភេទ O96-O99 នៃ ICD-10 ក៏រាប់បញ្ចូលនៅទីនេះដែរ ។ លក្ខ័ខណ្ឌ័ម្តាយផ្សេងទៀត ត្រូវគេដាក់ជាក្រុមនៅ VA-9 ។ មុននឹងចាប់ផ្តើមដាក់កូដ ចូរយោងទៅទំព័រនៅចុងបញ្ចប់នៃភាគទី១នៃ ICD-10សំរាប់និយមន័យដែលទាក់ទងនឹងការស្លាប់ដោយសម្ភព ។<br>បណ្តុំរោគសញ្ញា រោគសញ្ញា និងភាពមិនធម្មតាគ្លីនិក និងគំហើញមន្ទីរពិសោធ ICD-10 ជំពូក XVIII គួរតែប្រើដើម្បីដាក់កូដមូលហេតុនៅពីក្រោយការស្លាប់ ។ ប្រសិនរោគសញ្ញាមួយ គឺជារបស់តែមួយគត់ដែលគេរាយការណ៏ ជាលទ្ធផលនៃការសំភាសកោសល្យវិច័យផ្ទាល់មាត់ គេគួរតែកូដវា ។ យ៉ាងណាក៏ដោយ គេត្រូវប្រើ R-កូដ ។<br>ជាទូទៅគឺពួកទាំងនេះ<br>R-95 សំរាប់សញ្ញាស្លាប់ភ្លាមៗនៃកុមារ ( VA-10.12) និង<br>R99 សំរាប់មូលហេតុស្លាប់ដែលមិនបញ្ជាក់ (VA-13) ។ |
| VA-99 | មូលហេតុស្លាប់ដែលមិនបញ្ជាក់ | R99 | មូលហេតុស្លាប់ដែលអោយនិយមន័យមិនល្អ និង មិនបញ្ជាក់ ផ្សេងទៀត | ចូរប្រើកូដនេះនៅពេលដែលចំលើយដែលផ្តល់អោយ ក្នុងអំឡុងពេលសំភាសមិនអាចអោយអ្នកចាត់កូដជាក់លាក់ណាមួយនៃមូលហេតុស្លាប់ ឬបណ្តុំរោគសញ្ញាបាន (VA-98) ។ ក្នុងខណ:នេះ ចូរកុំទុកលិខិតបញ្ជាក់អោយនៅទទេ: ចូរចាត់កូដនេះ ។ |

VA, verbal autopsy; NEC, not elsewhere classified; NOS, not otherwise specified; HIV, human immuno deficiency virus; AIDS, acquired immunodeficiency syndrom.

VA កោសល្យវិច័យផ្ទាល់មាត់ ។ NEC មិនចាត់នៅកន្លែងណាផ្សេង ។ NOS មិនបញ្ជាក់ខុសពីនេះ ។ HIV វីរុសដែលធ្វើអោយភាពស៊ាំរបស់មនុស្សចុះខ្សោយ ។ AIDS បណ្តុំរោគសញ្ញដែលកើតមកពីការចុះខ្សោយនូវភាពស៊ាំ